**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អនីតិសង្វាសនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ដល់ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **ម៉ាត់ លីសៃយ៉ា**

**យុន ជីហួយ**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ប៊ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ាត់ លីសែយ៉ា** និង **យុន ជីហ្វាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី១៩ ថ្នាក់ L4A5 ឆ្នាំសិក្សា ២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមថ្លែងនូវកតញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

- **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថ្នាក់ថ្នមថែរក្សា តែងតែផ្តល់នូវក្តីស្រឡាញ់ អប់រំទូន្មានប្រៀនប្រដៅប្រកបដោយទំនួលខុសត្រូវខ្ពស់ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ស្មារតី និង ថវិការផ្គត់ផ្គង់ដល់ការសិក្សារបស់កូនៗ ជាពិសេសតែងតែ ផ្តល់នូវកម្លាំងចិត្ត លើកទឹកចិត្ត និងផ្តល់ក្តីសង្ឃឹមដល់កូនៗជានិច្ច។
- ឯកឧត្តម **បណ្ឌិត លុយ ចន្ថា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំទាំងពីរ បានចូលសិក្សានៅសាកលវិទ្យាល័យមួយនេះ និងបានបង្កភាពងាយស្រួយដល់ការសិក្សារបស់យើងខ្ញុំ។
- អ្នកគ្រូសាស្ត្រាចារ្យ **ម៉ួយ ធីតា** ជាសាស្រ្តាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹករបស់ខ្លួនជួយក្នុងការណែនាំ និងរៀបចំនូវសារណាបញ្ចប់ការសិក្សាមួយនេះឡើង។
- ថ្នាក់ដឹកនាំ សាស្រ្តាចារ្យ បុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានបង្ហាត់បង្រៀន និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។
- អ្នកនិពន្ធ ម្ចាស់ឯកសារ និង អ្នកស្រាវជ្រាវនូវប្រធានបទ និងស្នាដៃនានា ដែលបានចូលរួមចំណែកយ៉ាងសំខាន់ដល់យើងខ្ញុំបាទជាទុននៃការសិក្សា និង ការបំពេញនូវកិច្ចការស្រាវជ្រាវកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងជមិនអាចបំភ្លេចបានចំពោះឧបការគុណដ៏ធំធេងពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ សាកលវិទ្យាធិការ និងសាស្រ្តាចារ្យទាំងអស់ សូមឲ្យជួបតែជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទ **ម៉ាត់ លីសែយ៉ា** និង នាងខ្ញុំ **យុន ជីហួយ** សូមគោរពលោកគ្រូអ្នកគ្រូ លោកសាស្ត្រាចារ្យទាំងអស់ ព្រមទាំងស្វាគមន៍ដល់មិត្តៗ អ្នកអាន សិស្ស និស្សិត គ្រប់ៗរូបជាទីរាប់អាន។

ក្នុងនាមយើងខ្ញុំ ជានិស្សិតកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទមួយស្តីអំពី "**អនីតិសង្វាសនៅកម្ពុជាបច្ចុប្បន្ន**" នេះឡើង ដោយសារមើលឃើញថា ប្រជាជនកម្ពុជាមួយចំនួនធំបានបន្ត និងកំពុងរួមរស់នៅជាមួយគ្នាក្រោមរូបភាពអនីតិសង្វាសនេះ ដោយកង្វះខាតការយល់ដឹងពីសារៈប្រយោជន៍នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងកត្តាផ្សេងៗទៀត។ ជាលទ្ធផល វាបានបង្កឲ្យមាននូវបញ្ហា និង ផលវិបាកផ្លូវច្បាប់នៅពេលដែលប្តីប្រពន្ធអនីតិសង្វាសសម្រេចចិត្ត ឬឈានដល់ដំណាក់កាលបែកបាក់គ្នា។ បើក្រលែកមើលទៅលើទិដ្ឋភាពច្បាប់ ពួកគេមិនអាចធ្វើបណ្តឹងលែងលះតាមផ្លូវតុលាការបានទេ ដោយសារចំណងប្តីប្រពន្ធរបស់ពួកគេ ស្ថិតនៅក្រៅច្បាប់ ឬគ្មានលិខិតបទដ្ឋានគតិយុត្តណាមួយគ្រប់គ្រងចំណងអនីតិសង្វាសនោះទេ។ ម្យ៉ាងទៀត បើទោះបីជានៅក្នុងគោលការណ៍ច្បាប់ ពួកគេមិនអាចធ្វើការលែងលះតាមផ្លូវតុលាការដូចសហពទ្ធ័ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលក៏ពិតមែន យ៉ាងណាមិញនៅក្នុងការអនុវត្តជាក់ស្តែង គ្មានការឯកភាពគ្នាចំពោះរឿងក្តីអនីតិសង្វាសនោះទេ ដោយហេតុថា តុលាការមួយចំនួននៅតែធ្វើការសេចក្តីសម្រេចលើរឿងក្តីអនីតិសង្វាស ដោយផ្អែកទៅលើគោលការណ៍ និង ការបកស្រាយផ្សេងៗគ្នា។ ដោយហេតុពុំសូវមានការសិក្សាអំពីអនីតិសង្វាស និង អវត្តមាននៃវិធានគតិយុត្តគ្រប់គ្រងទំនាក់ទំនងមួយនេះ ព្រមទាំងមានការគាំទ្រ លើកទឹកចិត្តពីសំណាក់អ្នកគ្រូសាស្ត្រាចារ្យ **ប៊ួយ ធីតា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផងនោះ យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តក្នុងការរៀបចំសារណាស្តីអំពីប្រធានបទមួយនេះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាក្រោមប្រធានបទថ្មីមួយនេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់មួយ នៅក្នុងការយល់ដឹងអំពីចំណងអនីតិសង្វាស ដោយហេតុថាច្បាប់កម្ពុជាមិនបានទទួលស្គាល់ចំណងមួយប្រភេទនេះ បញ្ហាកង្វះខាតការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋកម្ពុជា និង ការផ្សព្វផ្សាយឲ្យទូលំទូលាយទាក់ទងនឹងផលវិបាកនៃចំណងអនីតិសង្វាសនេះ ដែលបានបង្កជាផលវិបាក និង វិវាទផ្លូវច្បាប់នានានៅពេលមានបណ្តឹងសុំលែងលះចំណងអនីតិសង្វាសទៅកាន់តុលាការជាដើម។ យើងខ្ញុំទាំងពីរសង្ឃឹមទៀតថា សារណាមួយនេះ នឹងក្លាយជាឯកសារបន្ថែម

សម្រាប់កិច្ចការស្រាវជ្រាវក្រោយៗពាក់ពន្ធ័នឹងប្រធានបទដ៏ចម្រូងចម្រាស់មួយនេះ។

យើងខ្ញុំក៏សូមអធ្យាស្រ័យរាល់កង្វះខាត និងកំហុសដោយអចេតនាទាំងឡាយណាដែលមាននៅក្នុងសារណាមួយនេះ ហើយយើងខ្ញុំទាំងពីររង់ចាំទទួលយករាល់មតិរិះគន់ស្ថាបនា ដើម្បីកែលម្អទាំងឡាយពីសំណាក់មិត្តអ្នកអានទាំងអស់គ្នាផងដែរ។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរ សូមជូនពរដល់មិត្តៗអ្នកអានគ្រប់ៗរូបឲ្យជួបប្រទះនូវជ័យជំនះរាល់ភារកិច្ច ភាពសុខដុមរមនា រុងរឿងថ្កុំថ្កើង និងសុភមង្គលជានិរន្តន៍។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**..........1

**ជំពូកទី១ សញ្ញាណនៃអនីតិសន្ធាស និង ទិដ្ឋភាពនៃបទដ្ឋានគតិយុត្ត** ..........2

**១.១. បញ្ហាលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍**..........5

១.១.១ កង្វះលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍..........5

១.១.២ និយ័តកម្មចំពោះអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី..........7

**១.២. លក្ខខណ្ឌសារធាតុនៃអនីតិសន្ធាស**..........9

១.២.១. សមគ្គសង្វាសតាមព្រឹត្តិន័យ..........9

១.២.២. លក្ខខណ្ឌនៃការរស់នៅជាមួយគ្នា..........10

១.២.៣. លក្ខណៈស្ថេរភាព និងនិរន្តរភាព..........11

១.២.៤. ភស្តុតាងនៃលក្ខខណ្ឌសារធាតុ..........12

**ជំពូកទី២ អានុភាពនៃអនីតិសន្ធាស**..........14

**២.១ ការបកស្រាយ ឬអនុវត្តដូចអាពាហ៍ពិពាហ៍**..........15

២.១.១. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក..........15

២.១.២. សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ និងចូលរួមសកម្មភាពសង្គម..........16

២.១.៣. បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍..........16

២.១.៤. ទ្រព្យរួម និងទ្រព្យដោយឡែក ..........17

២.១.៥. កាតព្វកិច្ចសាមគ្គី ..........19

២.១.៦. ការទាមទារសំណងនៃការខូចខាត..........20

២.១.៧. ការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល..........20

**២.២. ការមិនបកស្រាយដូចអាពាហ៍ពិពាហ៍**.........................................................................21

២.២.១. នាមត្រកូលរបស់ប្តីប្រពន្ធ.........................................................................21

២.២.២. ការទទួលបាននីតិភាពដោយអាពាហ៍ពិពាហ៍.........................................................21

២.២.៣. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.........................................................................22

២.២.៤. ការសន្មតបិតុភាព.........................................................................23

២.២.៥. អំណាចមេបាសហការ ឬអំណាចមេបារួម.........................................................................23

២.២.៦. ការបង្កើតចំណងញាតិ.........................................................................24

២.២.៧. សន្តតិកម្ម.........................................................................25

២.២.៨. អាហារកិច្ច ឬអាហារកាតព្វកិច្ច.........................................................................27

២.២.៩. ការចាត់ចែងទ្រព្យរួមរបស់ប្តីប្រពន្ធ.........................................................................28

២.២.១០. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក.........................................................................29

២.២.១១. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ.........................................................................29

២.២.១២. មូលហេតុនៃការលែងលះ.........................................................................31

**២.៣. ភាពស្រពិចស្រពិលក្នុងការបកស្រាយ**.........................................................................32

**ជំពូកទី៣ ការរំលាយអនីតិសង្វាស**.........................................................................33

**៣.១. ការរំលាយអនីតិសង្វាសក្រៅប្រពន្ធ័តុលាការ**.........................................................................33

៣.១.១. ការបែងចែកទ្រព្យសម្បត្តិ.........................................................................35

៣.១.២. ការកំណត់អំណាចមេបា.........................................................................35

**៣.២. ការរំលាយអនីតិសង្វាសក្នុងប្រព័ន្ធតុលាការ**.........................................................................35

**៣.២.១ មូលដ្ឋានគតិយុត្តសម្រាប់ការវិនិច្ឆ័យសេចក្តី និង ការសម្រេចសេចក្តី** .........................................35

**៣.២.១.១ ការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស** .........................................................................35

ក. ករណីមានបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍.........................................35

ខ. ករណីមានបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍..............................37

គ. ករណីមានបណ្ដឹងទាមទារឲ្យលែងលះ..............................38

ឃ. ករណីមានបណ្ដឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍..............................39

ង. ករណីមានបណ្ដឹងទាមទារឲ្យបំបែកអនីតិសង្វាស..............................39

**៣.២.១.២ ការបែងចែកទ្រព្យសម្បត្តិ**..............................40

ក. ករណីមានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ..............................40

ខ. មូលដ្ឋានគតិយុត្តដើម្បីវិនិច្ឆ័យករណីគ្មានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ..........43

**៣.២.១.៣ មូលដ្ឋានគតិយុត្តកំណត់អ្នកមានអំណាចមេបា** ..............................43

ក. ករណីមានបណ្ដឹងទាមទារអ្នកមានអំណាចមេបា..............................43

ខ. មូលដ្ឋានគតិយុត្តដើម្បីវិនិច្ឆ័យករណីគ្មានបណ្ដឹងទាមទារអ្នកមានអំណាចមេបា......44

**៣.២.២ ការអនុវត្តជាក់ស្ដែងលើការសម្រេចសេចក្ដី**..............................45

**៣.២.២.១ មូលដ្ឋានគតិយុត្តសម្រាប់ការវិនិច្ឆ័យសេចក្ដី** ..............................45

**៣.២.២.១.១ ការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស** ..............................45

ក. ករណីមានបណ្ដឹងទាមទារឲ្យលែងលះ..............................45

ខ. ករណីមានបណ្ដឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍..............................46

គ. ករណីមានបណ្ដឹងទាមទារឲ្យបំបែកអនីតិសង្វាស..............................47

**៣.២.២.១.២ ការបែងចែកទ្រព្យសម្បត្តិ** ..............................48

ក. ករណីមានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ..............................48

ខ. ករណីគ្មានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ..............................48

**៣.២.២.១.៣ ការកំណត់អ្នកមានអំណាចមេបា**..............................49

ក. ការសម្រេចសេចក្ដីលើបណ្ដឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា............49

ខ.ការសម្រេចសេចក្ដីករណីគ្មានបណ្ដឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា.....49

៣.២.២.២ ការអនុវត្តជាក់ស្តែងលើសេចក្តីសម្រេច ....................................................49

៣.២.២.២.១ ការសម្រេចសេចក្តីលើការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស..........................49

ក. បណ្តឹងទាមទារឲ្យបញ្ឈប់ការរួមរស់ជាអនីតិសង្វាស.........................................49

ខ. បណ្តឹងទាមទារឲ្យបញ្ជាក់នត្តិភាពនៃអាពាហ៍ពិពាហ៍.........................................50

គ. ករណីមានបណ្តឹងទាមទារឲ្យលែងលះ..................................................52

៣.២.២.២.២ ការសម្រេចសេចក្តីលើការបែងចែកទ្រព្យសម្បត្តិ .........................................53

ក. ការសម្រេចសេចក្តីករណីមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ......................53

ខ. ការសម្រេចសេចក្តីករណីគ្មានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ......................54

៣.២.២.២.៣ ការសម្រេចសេចក្តីលើការកំណត់អ្នកមានអំណាចមេបា ..............................54

ក. ករណីមានបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា...........................54

ខ. ករណីគ្មានបណ្តឹងកំណត់អ្នកមានអំណាចមេបា..........................................55

**សេចក្តីសន្និដ្ឋាន**.......................................................................................................57

**អនុសាសន៍**..............................................................................................................59

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១**

**ឧបសម្ព័ន្ធទី២**

# សេចក្តីផ្តើម

ស្របទៅតាមការវិវត្តនៃសម័យកាល ជាពិសេសនៅក្រោមការគ្រប់គ្រងរបស់អាណានិគមបារាំង ប្រព័ន្ធច្បាប់បែបបស្ចឹមប្រទេសនានា ត្រូវបានបង្កើតឡើងក្នុងការគ្រប់គ្រងសង្គមកម្ពុជា។ ក្រោយការទទួលឯករាជ្យពីសាធារណៈរដ្ឋបារាំង ប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាបានបន្តវិវត្តន៍ទៅមុខអត់ឈប់ឈរ ។ យ៉ាងណាមិញ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ធនធានមនុស្សផ្នែកច្បាប់ និងប្រព័ន្ធច្បាប់ទាំងឡាយត្រូវបានបាត់បង់ស្ទើរតែទាំងស្រុងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្រោមរបបដ៏ខ្មៅងងឹតនេះ ប្រទេសកម្ពុជាបានជួបប្រទះនូវមហាវិនាសកម្មដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្ររបស់ខ្លួននាប៉ុន្មានទសវត្សចុងក្រោយនេះ។ ក្រៅពីវិនាសកម្មនូវការសម្លាប់រង្គាល និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធច្បាប់នានា របបមួយនេះក៏បានបន្សល់ទុកនូវវិបត្តិផ្នែកមនុស្ស និងគ្រួសារផងដែរ ដោយសារប្រជាជនមួយចំនួនធំ ត្រូវបានបង្ខំឲ្យរៀបការដោយគ្មានវិធានច្បាប់គ្រប់គ្រងឲ្យបានត្រឹមត្រូវ។ អវត្តមាននៃច្បាប់គ្រប់គ្រងលើបញ្ហានេះ បន្តរហូតដល់ឆ្នាំ ១៩៨៩ ទើបមានច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានបង្កើតឡើង។ មកដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ទើបយើងមានវិធានគតិយុត្តថ្មីដែលជាច្បាប់សារធាតុគ្រប់គ្រងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិតាមរយៈច្បាប់ស្តីពីការដាក់ឲ្យអនុវត្តក្រមរដ្ឋប្បវេណី។

ទោះបីជារបបដ៏ខ្មៅងងឹតបានផុតរលត់ជាច្រើនទសវត្ស ជាមួយនឹងការបង្កើតច្បាប់គ្រប់គ្រងអាពាហ៍ពិពាហ៍ និងគ្រួសារយ៉ាងនេះក៏ដោយ ប្តីប្រពន្ធមួយចំនួនបានបន្តរស់នៅ ឬបង្កើតគ្រួសារក្រៅច្បាប់ដោយមិនការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬត្រូវបានស្គាល់ថាជាចំណងអនីតិសង្វាសនេះឯង។ ដោយយល់ឃើញថាអនីតិសង្វាសជាបញ្ហាគតិយុត្តនៅប្រទេសកម្ពុជា ហើយប្រជាជនមួយចំនួនធំបន្តជ្រើសរើសយកការរស់នៅបែបអនីតិសង្វាស ជាមួយនឹងអវត្តមានវិធានគតិយុត្ត និងភាពចម្រូងចម្រាស់ក្នុងការបកស្រាយ និងការយកបទបញ្ញត្តិអាពាហ៍ពិពាហ៍មកដោះស្រាយក្នុងរឿងក្តីអនីតិសង្វាសផងនោះ យើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ **អនីតិសង្វាសនៅកម្ពុជាបច្ចុប្បន្ន** មកធ្វើជាប្រធានបទសម្រាប់សារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

ហើយសារណាមួយនេះនឹងធ្វើការសិក្សា និងបកស្រាយនូវចំណុចសំខាន់នានារួមមាន៖

- ជំពូកទី១ ៖ សញ្ញាណនៃអនីតិសង្វាស និងទិដ្ឋភាពនៃបទដ្ឋានគតិយុត្ត
- ជំពូកទី២ ៖ អានុភាពនៃអនីតិសង្វាស
- ជំពូកទី៣ ៖ ការរំលាយអនីតិសង្វាស។

# ជំពូកទី១

# សញ្ញាណនៃអនីតិសង្វាស និងទិដ្ឋភាពនៃបទដ្ឋានគតិយុត្ត

**អនីតិសង្វាស** គឺជាស្ថានភាពទូទៅនៃការរួមរស់ជាប្តីប្រពន្ធរបស់ប្រជាជនកម្ពុជាជាច្រើន។ ស្ថានភាពនេះត្រូវបានអ្នកច្បាប់ព្យាយាមឲ្យនិយមន័យផ្សេងៗគ្នា។ បើយោងទៅតាមអត្ថន័យរបស់វាពាក្យ អនីតិសង្វាស មានន័យជាសាមញ្ញថា *ការរស់នៅជាមួយគ្នាក្រៅផ្លូវច្បាប់*។

អត្ថិភាពពនៃអនីតិសង្វាស កើតមានឡើងដោយមូលហេតុផ្សេងៗគ្នា។ ដូចក្នុងករណីនៅប្រទេស**ជប៉ុន** អនីតិសង្វាសកើតឡើងដោយមូលហេតុផ្សេងៗដូចជាៈ

- ភាគីម្ខាងនៃអនីតិសង្វាសបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់រួចហើយ
- ភាគីម្ខាងទៀតជាអនីតិសង្វាស
- ភាគីម្ខាងទៀតមិនអាចរៀបការតាមច្បាប់បានដោយសារកត្តាស្ថានភាពផ្លូវចិត្ត ដូចជាការមិនចង់មានចំណងផ្លូវច្បាប់ និងមិនចង់ដូរនាមត្រកូលជាដើម។
- ការយឺតយ៉ាវក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ការយល់ឃើញថាការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទំលាប់ប្រពៃណីមានសារៈសំខាន់ជាងជាដើម[1, 2]។

រីឯនៅប្រទេស**កម្ពុជា**យើងវិញ គេឃើញមានមូលហេតុស្រដៀងនឹងនៅប្រទេសជប៉ុនដែរ។ មូលហេតុផ្សេងៗទៀតរួមមានៈ

- ភាគីនៃអនីតិសង្វាសយល់ឃើញថាការរៀបការតាមច្បាប់មានលក្ខណៈស្មុគស្មាញចំណាយពេលវេលា និងថវិការច្រើន។
- ភាគីនៃអនីតិសង្វាសមិនចង់មានចំណងផ្លូវច្បាប់ដែលត្រូវលែងលះនៅតុលាការ
- កង្វះការផ្សព្វផ្សាយអំពីការចុះបញ្ជីអត្រានុកូលដ្ឋានឲ្យបានទូលំទូលាយ
- អប្រសិទ្ធភាព ឬភាពអសកម្មនៃការចុះអត្រានុកូលដ្ឋាន
- និងកង្វះការយល់ដឹងពីសារៈសំខាន់នៃការទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់ជាដើម[3, 4]។

---

[1] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[2] MIURA YASUKO.២០១៣. សិក្ខាសិលាស្តីពីអនីតិសង្វាស និងសន្តតិកម្ម។

[3] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[4] MIURA YASUKO.២០១៣. សិក្ខាសិលាស្តីពីអនីតិសង្វាស និងសន្តតិកម្ម។

នៅប្រទេសកម្ពុជាបច្ចុប្បន្ន គេមិនឃើញមានការឲ្យនិយមន័យដោយច្បាប់កម្ពុជា ឬមានវត្តមាននិធានគតិយុត្តណាមួយដែលកំណត់ឲ្យច្បាស់លាស់ ឬ គ្រប់គ្រងចំណងអនីតិសង្វាសនេះទេ។ យ៉ាងណាមិញ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ២២២ គេឃើញមានការប្រើប្រាស់ពាក្យ អនីតិសង្វាសជន នៅក្នុងបទ**អំពើហឹង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន**[5]។ សហព័ទ្ធគឺជាប្ដីប្រពន្ធ័ដែលកើតឡើងដោយអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយ **អាពាហ៍ពិពាហ៍** ត្រូវបានឲ្យនិយមន័យយ៉ាងច្បាស់លាស់ក្នុងច្បាប់កម្ពុជាថា ជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាថាខ្លួននឹង**រួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់** ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួននោះទេ[6] [7]។ រីឯនិយមន័យរបស់**អនីតិសង្វាស** មិនត្រូវបានផ្ដល់និយមន័យដោយច្បាប់នៅកម្ពុជានោះទេ យ៉ាងណាមិញវាត្រូវបានគេព្យាយាមឲ្យនិយមន័យថា *ជាស្ថានភាពបុរស និង នារីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា(បានចុះសំបុត្រអាពាហ៍ពិពាហ៍) ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ*[8]។

សរុបមក ក្នុងន័យនេះ សហព័ទ្ធ និងអនីតិសង្វាសជនត្រូវបានកំណត់ដាច់ចេញពីគ្នាក្នុងន័យច្បាប់។ ពោលសហព័ទ្ធសំដៅទៅលើប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ រីឯអនីតិសង្វាសជន សំដៅទៅលើជនដែលរួមរស់ជាមួយគ្នាដោយមិនមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់នេះឯង។ នៅពេលដែលចំណងអាពាហ៍ពិពាហ៍របស់បុរសនារីមិនបានគោរពទៅតាមក្បួនខ្នាត និងច្បាប់ដែលបានចែង ឬក៏បានគោរពទៅតាមលក្ខខណ្ឌសារធាតុនៃអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ ករណីនេះត្រូវបានស្គាល់ថាជា អនីតិសង្វាស ឬ**សមគ្គសង្វាសតាមព្រឹត្តន័យ**[9]។ ហើយ**សមគ្គសង្វាស**ត្រូវបានផ្ដល់និយមន័យក្នុងន័យទូទៅថា ជា***ការនៅរួមព្រមចិត្តព្រមគំនិត ការនៅរួមសុខរួមទុក្ខ*** ជាមួយគ្នា[10]។ ឯក្នុងន័យនីតិសាស្ត្រវិញ សមគ្គសង្វាស គឺ***ជាការរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធដោយមានការដាក់បញ្ចូលគ្នានៃទ្រព្យ*** [11]។ សមគ្គសង្វាសត្រូវបានបែងចែក

---

[5] ក្រមពហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២២២។

[6] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៣។

[7] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣។

[8] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *សន្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*, (ភ្នំពេញ៖ ហ្វូណន ២០០៥), ទំព័រ៧៩។

[9] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[10] សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរភាគទី២ (យ-អ)*, (ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតកម្ពុជា, លេខ ១៦៥, បោះពុម្ពទី៥ ឆ្នាំ១៩៦៨), ទំព័រទី ១២៧៥។

[11] Géralg Cornu, Association Henri Capitant, Vocabulaire Juridique (7éme Édition puf, 2005), page 927, le mot "**Union**".

ជាពីរ គឺ**សមគ្គសង្វាសតាមច្បាប់** ក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍តាមច្បាប់ និង **សមគ្គសង្វាសតាមព្រឹត្តន័យ** ដែលស្ថិតក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬ **អនីតិសង្វាស** នេះឯង[12]។

ម៉្យាងអនីតិសង្វាសអាចបង្កើតឡើងដោយមិនចាំបាច់តម្រូវឲ្យបំពេញនូវលក្ខខណ្ឌមួយចំនួនដូចអាពាហ៍ពិពាហ៍តាមច្បាប់នោះទេ ហើយអនីតិសង្វាសអាចត្រូវបានបង្កើតឡើងក្នុងកំឡុងពេលហាមឃាត់នៃអាពាហ៍ពិពាហ៍ ឬអាចបង្កើតឡើយដោយអនីតិជនក៏បានដែរ។ ក្នុងនោះទៀតសោតអនីតិសង្វាសក៏អាចកើតឡើង ក្នុងករណីភាគីនៃអាពាហ៍ពិពាហ៍ស្របច្បាប់ មានទំនាក់ទំនងជាប្តីប្រពន្ធជាមួយនឹងបុគ្គលម្នាក់ផ្សេងទៀតផងដែរ[13]។

បើតាមអត្ថបទស្រាវជ្រាវមេរៀនរបស់លោកសាស្រ្តាចារ្យ រុន ពុណ្ណារិទ្ធ (ឆ្នាំសិក្សា២០១៤-២០១៥) និង កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លើកទី៦ កាលពីឆ្នាំ២០១៥ បានឲ្យនិយមន័យអនីតិសង្វាសថាជា *ទំនាក់ទំនងដែលមិនត្រូវទទួលស្គាល់ជាសហព័ទ្ធ ឬប្តីប្រពន្ធស្របច្បាប់ ប៉ុន្តែបុគ្គលនេះបានរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ មានជីវភាពរួមគ្នា (សម្ព័ន្ធភាពផ្លូវភេទ ទ្រព្យ និងលំនៅរួម) និងមានឆន្ទៈរៀបអាពាហ៍ពិពាហ៍*[14, 15]។

បើយោងទៅតាមសន្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់វិញ អនីតិសង្វាស (le concubinage) ត្រូវបានគេឲ្យនិយមន័យថាជា *ស្ថានភាពរបស់បុរស និងនារីដែលរួមរស់ជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ*[16]។

រីឯនៅប្រទេសបារាំងវិញ ក្រមរដ្ឋប្បវេណីរបស់បារាំងបានកំណត់ន័យរបស់អនីតិសង្វាស (le concubinage) យ៉ាងច្បាស់លាស់ថាគឺជា *សមគ្គសង្វាសតាមព្រឹត្តិន័យ ដែលមានលក្ខណៈជាការរស់នៅរួមគ្នា ភ្ជាប់ជាមួយនូវលក្ខខណ្ឌស្ថេរភាព និង និរន្តរភាពរវាងបុគ្គលពីរនាក់ដែលមានភេទខុសគ្នា ឬដូចគ្នា ហើយរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ*[17, 18]។

---

[12] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤),៦៩។

[13] អ៊ុំ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[14] ប៊ុនរតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៩។

[15] អ៊ុំ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[16] សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, *សន្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*, (ភ្នំពេញ៖ ហ្វូណាន ២០០៥), ទំព័រទី៧៩។

[17] Code Civil Francais, (DALLOZ, 2014), article 518-8.

[18] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៧។

បើយោងទៅតាមនិយមន័យនៃអនីតិសង្វាស ដែលបានផ្តល់ឲ្យតាមប្រភពផ្សេងៗដូចបានរៀបរាប់ខាងលើ អនីតិសង្វាសកើតឡើងដោយសារ**កង្វះលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍** និងកំណត់ដោយ**លក្ខខណ្ឌសារធាតុរបស់អនីតិសង្វាស**នេះផ្ទាល់។

## ១.១. បញ្ហាលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍

### ១.១.១ កង្វះលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាចំណងគតិយុត្តមួយដែលចងភ្ជាប់ប្តីប្រពន្ធទៅតាមផ្លូវច្បាប់ ហើយវាបង្កើតបានជាសិទ្ធិ និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ ដើម្បីទទួលបានភាពជាប្តីប្រពន្ធស្របច្បាប់ បុគ្គលទាំងពីររូបត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចមានកំណត់នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ រួមជាមួយនឹងបទបញ្ញត្តិនានាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧។

បើយោងតាមមាត្រា៣ នៃច្បាប់ឯកពន្ធភាព និងមាត្រា ៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អាពាហ៍ពិពាហ៍ឆ្នាំ ១៩៨៩ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារឹកមួយធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួននោះទេ។ អាពាហ៍ពិពាហ៍នេះទៀតសោត មានអានុភាពពេញលេញច្បាប់លុះត្រាតែបានធ្វើឡើងស្របទៅតាមក្បួនខ្នាតដែលមានចែងនៅក្នុងច្បាប់។ ក្នុងន័យនេះ ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយមានភាពស្របច្បាប់ ឬមានអានុភាពបាន លុះត្រាតែវាត្រូវបានបំពេញនូវលក្ខខណ្ឌសារធាតុ និង លក្ខខណ្ឌទម្រង់របស់វា។ ចំពោះលក្ខខណ្ឌសារធាតុនៃអាពាហ៍ពិពាហ៍មានដូចជា លក្ខខណ្ឌអាយុ បុគ្គលទាំងពីរត្រូវមានភេទផ្ទុយគ្នាពោលគឺ បុរស និងនារី ជានីតិជន ឬម្ខាងជាអនីតិជនក្នុងករណីលើកលែងជាដើម (មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី) មិនមែនជាអាពាហ៍ពិពាហ៍ដែលបានហាមឃាត់ ឬកើតឡើងក្នុងកំឡុងពេលហាមឃាត់ជាដើម។ រីឯលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍វិញ ដោយអនុលោមតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី មានដូចជា ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការបិទប្រកាសជាសាធារណៈ និងចុងក្រោយ គឺការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ អេតាស៊ីវិល នៅមុខមន្រ្តីអត្រានុកូលដ្ឋានដោយមានសាក្សីពីររូបជាដើម (សមគ្គសង្វាសតាមច្បាប់)[19]។

នៅពេលដែលអាពាហ៍ពិពាហ៍មិនបានគោរពទៅតាមក្បួនខ្នាត និងច្បាប់ដែលបានចែង ឬក៏បានគោរពទៅតាមលក្ខខណ្ឌសារធាតុនៃអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែមិនបានប្រព្រឹត្តទៅតាមលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ពោលគឺមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ អាពាហ៍ពិពាហ៍ស្របច្បាប់

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨-៩៥៥។

មិនបានកើតឡើងនោះទេ ករណីនេះត្រូវបានស្គាល់ថាជា **អនីតិសង្វាស** (សមគ្គសង្វាសតាមព្រឹត្តន័យ)[20]។ ក្នុងករណីផ្សេងទៀត អនីតិសង្វាសក៏អាចត្រូវបានកើតឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីដោយគ្មានការចុះបញ្ជីអាពាហ៍ពិពាហ៍ផងដែរ។

បើយើងពិនិត្យទៅលើ កថាខណ្ឌទី ២ មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី មូលហេតុមួយចំនួនដែលនាំឲ្យអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃៈបាន រួមមាន៖ ការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការមិនបានជូនដំណឹងជាសាធារណៈអំពីអាពាហ៍ពិពាហ៍របស់ខ្លួន និង ការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនេះឯង[21]។ ក៏ប៉ុន្តែ ទោះបីមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬគ្មានក៏ដោយ នៅពេលដែលបុរស និងនារីបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនោះ អនីតិសង្វាសនឹងត្រូវបានបញ្ចប់ ដោយពួកគេនឹងក្លាយជាប្តីប្រពន្ធស្របច្បាប់[22]។

យ៉ាងណាមិញ ទោះបីជាអនីតិសង្វាសកើតមានដោយសារការមិនបានបំពេញលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ការប្រងើយកន្តើយអំពីលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ជាពិសេសការមិនចុះបញ្ជីអាពាហ៍ពិពាហ៍ក៏ពិតមែន ក៏ប៉ុន្តែពួកគេមិនត្រឹមតែត្រូវបានចាត់ទុកគ្រាន់តែជាជនដែលរស់នៅជាមួយគ្នាដូចប្តីប្រពន្ធប៉ុណ្ណោះទេ ដោយហេតុថា ពួកគេត្រូវបានទទួលនូវការគាំពារមួយដោយកំណត់ ដូចក្នុងករណីច្បាប់ទាក់ទងទៅនឹងសុខុមាលភាពសង្គម និងប្រាក់សោធន៍និវត្តន៍ជាដើម ដោយមានចំណុចជាច្រើនដែលប្តីប្រពន្ធនៃអនីតិសង្វាសបានទទួលការអនុវត្តដូចគ្នាតាមច្បាប់ដូចគ្នានឹងសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ផងដែរ[23]។

សរុបសេចក្តីមក អនីតិសង្វាសក្នុងន័យនេះ កើតឡើងដោយសារកង្វះលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ឬ អវត្តមាននៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនេះឯង ក៏ប៉ុន្តែមិនមានន័យថាពួកគេត្រូវបានរើសអើងដោយច្បាប់ ឬមិនត្រូវបានយកចិត្តទុកដាក់ពីសំណាក់រដ្ឋនោះទេ។

- **ឆន្ទៈរៀបអាពាហ៍ពិពាហ៍**

បើយោងតាមកថាខណ្ឌទី២ មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណី ប្រសិនបើអាពាហ៍ពិពាហ៍បានកើតឡើងដោយគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត នោះអាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ។ ត្រង់បញ្ញត្តិនេះ យើង

[20] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

[22] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[23] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, បោះពុម្ពលើកទី៥ (ភ្នំពេញ, ២០១១), ១៩៩។

សង្កេតឃើញថា *ឆន្ទៈរៀបអាពាហ៍ពិពាហ៍* គឺជាមូលហេតុចម្បងមួយដែលនាំឲ្យមានមោឃភាពនៃអាពាហ៍ពិពាហ៍។ ដោយសារតែអាពាហ៍ពិពាហ៍ ត្រូវបានបង្កើតឡើងដោយឆន្ទៈរបស់គូភាគី ឬគោលការណ៍ស្ម័គ្រចិត្តរបស់ភាគីជាប្ដីប្រពន្ធ រីឯអនីតិសង្វាសជាស្ថានភាពប្ដីប្រពន្ធដែលមិនបានបំពេញលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ដូចនេះការបង្កើតអនីតិសង្វាសក៏ត្រូវឈរលើឆន្ទៈរបស់ភាគីផងដែរ។ ពោល គឺប្ដីប្រពន្ធអនីតិសង្វាសត្រូវមានឆន្ទៈក្នុងការរស់នៅជាមួយគ្នាដូចជាប្ដីប្រពន្ធផងដែរ ទោះបីជាចំណងមួយនេះត្រូវចាត់ទុកថាជាចំណងក្រៅផ្លូវច្បាប់ក៏ដោយ។ ហើយឆន្ទៈរៀបអាពាហ៍ពិពាហ៍នេះ ក៏ត្រូវបានចាត់ទុកថាជាលក្ខខណ្ឌមួយនៃអនីតិសង្វាសផងដែរ[24, 25]។

### ១.១.២ និយ័តកម្មចំពោះអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី

វិធានគតិយុត្តសម្រាប់គ្រប់គ្រងអាពាហ៍ពិពាហ៍ និងគ្រួសារទើបតែត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៩ តែប៉ុណ្ណោះ ក្រោយការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩។ ម៉្យាងការបង្កើតច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារក៏បានបង្កជាបញ្ហាគតិយុត្តមួយចំនួន ដោយហេតុថាការងារនៃការចុះបញ្ជីអត្រានុកូលដ្ឋានមិនទាន់ត្រូវបានបង្កើតឡើង ដែលវាតម្រូវទាមទារឲ្យមានការធ្វើនិយ័តកម្មនៃអាពាហ៍ពិពាហ៍ ដែលមិនបានចុះបញ្ជី។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យចំនួន ៥ ចាប់តាំងពីឆ្នាំ ២០០០ មក ក្នុងគោលដៅចំបងកំណត់បែបបទ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។ អនុក្រឹត្យទាំងនោះរួមមាន៍៖

- **អនុក្រឹត្យលេខ ១០៣ អនក្រ.បក** ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋាន

បើយោងតាមមាត្រា ២ នៃអនុក្រឹត្យនេះ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ ការចុះសំបុត្រអត្រានុកូលដ្ឋាន គឺជារឿងសំខាន់ដោយសារ វាជាបង្កើតចំណងរួមភ្ជាប់សញ្ជាតិរបស់បុគ្គលទៅនឹងរដ្ឋ ព្រមទាំងបង្កើតជាសិទ្ធិ និងករណីយកិច្ចដល់បុគ្គលក្នុងគ្រួសារ និងសង្គម។ មាត្រា ៣ នៃអនុក្រឹត្យដដែលនេះ ក៏បានបញ្ជាក់ថាការសុំចុះបញ្ជីអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបផងដែរ។ បើយោងតាមមាត្រា ៤៥ នៃ អនុក្រឹត្យនេះវិញ ពលរដ្ឋខ្មែរដែលបានគ្នាជាប្ដីប្រពន្ធពិតប្រាកដនៅមុនពេលមានអនុក្រឹត្យនេះ (ចូលជាធរមាន) ប្រសិនបើពួកគេគ្មានសំបុត្រអាពាហ៍ពិពាហ៍ ពួកគេអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បាននៅតាមសាលាឃុំសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីពីររូបជានីតិជន ឬអ្នកដែលគួរឲ្យទុកចិត្តបានដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនផ្ទាល់

[24] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[25] ប៊ុនរតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៩។

ថាជាប្ដីប្រពន្ធ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ហើយការសុំចុះបញ្ជីនេះអនុវត្តតែក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានប៉ុណ្ណោះ នេះបើយោងតាមមាត្រា ៣នៃអនុក្រឹត្យនេះ។

- **អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០ ស្ដីពីការកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣**

យោងតាមអនុក្រឹត្យនេះ ការសុំចុះបញ្ជីអត្រានុកូលដ្ឋាន រួមទាំងសំបុត្រអាពាហ៍ពិពាហ៍ត្រូវបានពន្យារហូតដល់ថ្ងៃ ៣១ ខែសីហា ឆ្នាំ ២០០៥ វិញ។

- **អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្ដីពីការកែសម្រួលមាត្រា ៥៩ថ្មីនៃអនុក្រឹត្យលេខ ៦០**

ត្រង់មាត្រា ៥៩ ថ្មីស្ទួន ចំណុច ក បានបញ្ជាក់ថា ការចុះសំបុត្រអត្រានុកូលដ្ឋាន ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥។

- **អនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ ថ្មីស្ទួននៃអនុក្រឹត្យលេខ ១៧**

អនុក្រឹត្យថ្មីនេះ ពន្យាពេលនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ចាប់ពីថ្ងៃ០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហាឆ្នាំ២០០៦ វិញ។

- **អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ ថ្មីស្ទួននៃអនុក្រឹត្យលេខ ១០៦**

អនុក្រឹត្យថ្មីនេះ ពន្យាពេលនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ចាប់ពីថ្ងៃ០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ វិញ។

អនុក្រឹត្យទាំង ៥ ដែលបានរៀបរាប់ខាងលើនេះ ទទួលស្គាល់អាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី ដែលវាហាក់បំពានទៅលើមាត្រា ៣ និងមាត្រា ១៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍នឹងគ្រួសារ ឆ្នាំ១៩៨៩ ដែលកំណត់ពីគោលការណ៍ឱឡារិកភាពនៃអាពាហ៍ពិពាហ៍ដែលមានការចុះបញ្ជី ឬមិនបានគោរពឋានានុក្រមនៃនីតិទៅវិញ[26]។

លើសពីនេះទៅទៀត ក្នុងគោលដៅដើម្បីធ្វើឲ្យអនីតិសង្វាសក្លាយទៅជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះ ក្រសួងមហាផ្ទៃកម្ពុជាក៏បានចេញ **សេចក្ដីណែនាំលេខ ០០៨ សណន** នៅថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០០៧ ស្ដីពីការចុះសៀវភៅអត្រានុកូលដ្ឋានឲ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនា

[26] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៨-១២

ការចុះបញ្ជីអត្រានុកូលដ្ឋានកន្លងមក។ សេចក្តីណែនាំនេះអនុញ្ញាតឲ្យអ្នកដែលរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី តែមិនទាន់មានសំបុត្រអាពាហ៍ពិពាហ៍ត្រូវប្តឹងសុំចុះបញ្ជីអាពាហ៍ពិពាហ៍នៅឃុំសង្កាត់របស់ខ្លួន។ ដើម្បីទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍ប្តីប្រពន្ធអនីតិសង្វាសទាំងពីរត្រូវមានលិខិតស្នាមផ្សេងៗ ដូចជា ពាក្យសុំរៀបអាពាហ៍ពិពាហ៍ លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ សេចក្តីចម្លងសំបុត្រកំណើត (បើមាន) ឬសៀវភៅគ្រួសារ (បើមាន) ឬ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (បើមាន)។ និយាយឲ្យខ្លី ត្រូវបំពេញសំណុំបែបបទ និងដំណើរការទៅដូចជានីតិវិធីដែលប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍ថ្មីថ្មោងដូច្នេះដែរ[27]។

## ១.២. លក្ខខណ្ឌសារធាតុនៃអនីតិសង្វាស

កង្វះនៃលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ មិនមែនជាកត្តាសំខាន់តែមួយ ដែលកំណត់ពីអត្ថិភាពនៃអនីតិសង្វាសនោះទេ ប៉ុន្តែវាក៏ត្រូវបានកំណត់យ៉ាងសំខាន់ដោយលក្ខខណ្ឌសារធាតុនៃអនីតិសង្វាសផងដែរ[28]។ ដោយសារច្បាប់កម្ពុជាមិនមានការចែងឲ្យច្បាស់លាស់អំពីលក្ខខណ្ឌនៃអនីតិសង្វាស ឬមិនមានវិធានគតិយុត្តណាមួយកំណត់ពីទំនាក់ទំនងអនីតិសង្វាស យើងនឹងពិនិត្យទៅលើនិយមន័យដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីបារាំង *អនីតិសង្វាសជាសមគ្គសង្វាសតាមព្រឹត្តិន័យ ដែលមានលក្ខណៈជាការរស់នៅរួមគ្នាភ្ជាប់ជាមួយនូវលក្ខខណ្ឌស្ថេរភាព និងនិរន្តរភាពរវាងបុគ្គលពីរនាក់ដែលមានភេទខុសគ្នា ឬដូចគ្នា ហើយរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ។* និយមន័យខាងលើនេះ បានកំណត់ពីអត្តសញ្ញាណដែលបង្កើតជាចំណងអនីតិសង្វាស ហើយដោយយោងតាមនិយមន័យនេះ លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសអាចត្រូវបានកំណត់ដូចខាងក្រោម[29]។

### ១.២.១. សមគ្គសង្វាសតាមព្រឹត្តិន័យ

សមគ្គសង្វាសតាមព្រឹត្តិន័យ សំដៅទៅលើការរួមរស់ជាមួយគ្នាដោយមិនផ្លូវការ ឬមិនបានបំពេញលក្ខខណ្ឌអាពាហ៍ពិពាហ៍តាមច្បាប់ ដែលស្គាល់ជាទូទៅថា អនីតិសង្វាស[30]។ ស្ថានភាពនេះបានកើតមានឡើងស្ទើរគ្រប់ប្រទេសជុំវិញពិភពលោក រីឯនៅកម្ពុជាវិញវាក៏ជាស្ថានភាពទូទៅមួយរបស់គូស្វាមីភរិយាមួយចំនួនធំ ជាពិសេសនៅទីជនបទដាច់ស្រយាល។ ម្យ៉ាងទៀត សមគ្គសង្វាសតាម ព្រឹត្តិន័យកើតឡើងដោយព្រឹត្តិការណ៍ ពោលគឺបុរស និងនារីបានរស់នៅជាមួយគ្នាដោយគ្មានការរៀបអាពាហ៍ពិពាហ៍ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬបានរៀបអាពាហ៍ពិពាហ៍តាម

---

[27] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៥-១៦។

[28] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៦។

[29] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៧។

[30] សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, *សន្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*, (ភ្នំពេញ៖ ហ្វូណាន ២០០៥), ទំព័រទី៧៩។

ច្បាប់ តែមិនមានការចុះសំបុត្រអាពាហ៍ពិពាហ៍។ អនីតិសង្វាសត្រូវបានបែងចែកដាច់ចេញគ្នាពីអាពាហ៍ពិពាហ៍ ពីព្រោះអាពាហ៍ពិពាហ៍ គឺជាលិខិត ឬ សកម្មភាពគតិយុត្តមួយដែលផ្តល់ភាពស្របច្បាប់ដល់បុរស និងនារី ឬទទួលស្គាល់ពួកគេជាប្តីប្រពន្ធស្របច្បាប់។ ដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់ឯកពន្ធភាព និងមាត្រា ៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ *អាពាហ៍ពិពាហ៍* គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួននោះទេ[31,32]។

ក្នុងន័យនេះ អាពាហ៍ពិពាហ៍មានលក្ខណៈខុសគ្នាពីអនីតិសង្វាស ឬ សមគ្គសង្វាសតាមព្រឹត្តិន័យនេះ ដោយហេតុថាអាពាហ៍ពិពាហ៍អាចរំលាយទៅបានលុះត្រាតែបានឆ្លងកាត់នីតិវិធីច្បាប់ ឬលែងលះនៅតុលាការដោយមានមូលហេតុត្រឹមត្រូវ និងនីតិវិធីមួយច្បាស់លាស់ដែលមានកំណត់នៅក្នុងច្បាប់ដោយមិនអាចរំលាយចោលតាមទំនើងចិត្តនោះឡើង។ ផ្ទុយមកវិញ អនីតិសង្វាស គឺជាសមគ្គសង្វាសសេរី ដែលធ្វើឡើងដោយឆន្ទៈសេរីរបស់គូភាគី ដូចនេះវាក៏ត្រូវបានរំលាយវិញដោយសេរីតាមឆន្ទៈរបស់គូភាគីដូចគ្នានេះដែរ[33]។

### ១.២.២. លក្ខខណ្ឌនៃការរស់នៅជាមួយគ្នា

លក្ខខណ្ឌសារធាតុមួយនៃអនីតិសង្វាស គឺការរួមរស់រវាងបុរស និងនារីដែលមានលក្ខណៈដូចគ្នានឹងសហព័ទ្ធស្របច្បាប់ដែរ ដោយហេតុថាប្តីប្រពន្ធអនីតិសង្វាស រស់នៅក្នុងផ្ទះជាមួយគ្នា និងមានជីវភាពរស់នៅរួមគ្នា។ ការរស់នៅជាមួយគ្នាមិនមែនជាលក្ខខណ្ឌសារវន្តដែលអាចកំណត់ពីលក្ខណៈវិនិច្ឆ័យនៃអនីតិសង្វាសនោះទេ[34] ក៏ប៉ុន្តែការរស់នៅលក្ខខណៈដូចជាប្តីប្រពន្ធទៅវិញទេ ដែលជាធាតុសារវន្តសម្រាប់វិនិច្ឆ័យពីអនីតិសង្វាសនេះ។ ហើយចំណងអនីតិសង្វាសមិនមែនគ្រាន់តែជាការរស់នៅជាមួយគ្នាខាងផ្លូវសម្ភារៈ ឬ ផ្លូវភេទប៉ុណ្ណោះទេ ក៏ប៉ុន្តែ វាគឺជាចំណងដែលបង្កើតអានុភាពគតិយុត្តតាម រយៈព្រឹត្តិការណ៍[35]។

លើសពីនេះទៅទៀត ដើម្បីអាចចាត់ទុកថាជាប្តីប្រពន្ធ អនីតិសង្វាសត្រូវរំលេចឡើងនូវលក្ខណៈខាងក្រៅមួយចំនួនដោយឈរលើទ្រឹស្តីនៃសភាពខាងក្រៅ ពោលគឺចំណងអនីតិសង្វាសរបស់បុរសនារី មិនមែនរំលេចឡើងគ្រាន់តែជាការរួមរស់ជាមួយគ្នាតែក្នុងជីវភាពប្រចាំថ្ងៃប៉ុណ្ណោះទេ តែត្រូវរំលេចស្ថានភាពជាប្តីប្រពន្ធផ្សេងៗទៀត ដូចជាការទៅលំហែកាយជាមួយគ្នាបែបគ្រួសារ

---

[31] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៣។

[32] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣។

[33] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៨។

[34] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៩។

[35] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២៤។

ការចូលរួមក្នុងសង្គមជាមួយគ្នា និងមានកូនជាមួយគ្នាជាដើម[36]។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកស្រឡាញ់ភេទដូចគ្នា នៅតែអាចទទួលបាននូវលិខិតស្នាម និង ឯកសាររដ្ឋបាលផ្សេងៗដោយអាជ្ញាធរមូលដ្ឋានផងដែរ[37]។

❖ **ករណីភេទដូចគ្នា**

នៅប្រទេសបារាំង ដោយមានការទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា អនីតិសង្វាសអាចត្រូវបានបង្កើតឡើងដោយគូភាគីដែលមានភេទដូចគ្នាផងដែរ ដូចមានកំណត់ក្នុងនិយមន័យនៃពាក្យ អនីតិសង្វាសក្នុងក្រមរដ្ឋប្បវេណីបារាំង[38]។ រីឯនៅប្រទេសជប៉ុនវិញ មិនមានការទទួលស្គាល់ភេទដូចគ្នាជាអនីតិសង្វាសនោះទេ ដោយមូលហេតុវាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ និង ប្រពៃណីល្អរបស់សង្គមជប៉ុន។ ដូចគ្នានេះដែរ នៅកម្ពុជា ដោយសារច្បាប់អាពាហ៍ពិពាហ៍បានកំណត់យ៉ាងច្បាស់ និង ទទួលស្គាល់តែ បុរស នារីដែលមានភេទផ្ទុយគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ជាសហព័ទ្ធស្របច្បាប់ ដូចនេះយើងត្រូវពិចារណាថាតើអ្នកស្រឡាញ់ភេទដូចគ្នាដែលរួមរស់ជាមួយគ្នាក្នុងលក្ខខណ្ឌជាអនីតិសង្វាស អាចត្រូវចាត់ទុកជាអនីតិសង្វាសដែរឬទេ?[39]។

ម៉្យាងទៀត នៅពេលដែលមានបណ្តឹងសុំរំលាយអនីតិសង្វាស ក្នុងការអនុវត្តជាក់ស្តែងក្នុងតុលាការកម្ពុជា ភាគច្រើននៃបណ្តឹងទាំងនោះ ត្រូវបានធ្វើឡើងដោយភាគីដែលមានភេទផ្ទុយគ្នាប៉ុណ្ណោះ ដូចនេះអត្ថិភាពនៃអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នា មិនទាន់លេចឡើងជាយុត្តិសាស្ត្រនៅតុលាការនោះទេ។ យ៉ាងណាមិញដោយសារការបើកចំហយ៉ាងទូលំទូលាយដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ជាមួយនឹងការរីកចម្រើននៃសង្គមកម្ពុជា បុគ្គលស្រលាញ់ភេទដូចគ្នា ហាក់មិនស្ពាក់ស្ទើរក្នុងការបង្ហាញពីសមគ្គសង្វាសរបស់ពួកគេជាសាធារណៈនោះទេ[40] រហូតដល់មានការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរយ៉ាងអធិកអធមទៀតផង ទោះបីច្បាប់កម្ពុជាមិនទាន់ទទួលស្គាល់ និងអនុញ្ញាតទំនាក់ទំនងភេទដូចគ្នាក្នុងអាពាហ៍ពិពាហ៍ក៏ដោយ។

### ១.២.៣. លក្ខណៈស្ថេរភាព និងនិរន្តរភាព

ក្រៅពីការរួមរស់ជាមួយគ្នាដូចប្តីប្រពន្ធ អត្ថិភាពនៃអនីតិសង្វាស ក៏ត្រូវបានកំណត់ដោយលក្ខណៈស្ថេរភាព និង និរន្តរភាពផងដែរ។ ទំនាក់ទំនងបែបអនីតិសង្វាស ឬទំនាក់ទំនងក្រៅផ្លូវ

---

[36] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២៤។

[37] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *គ្រួសារឥន្ទធនូនៅកម្ពុជា* (ភ្នំពេញ, ២០១៧)។

[38] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៧។

[39] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[40] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២២-២៣។

ច្បាប់នេះកើតឡើងក្រោមរូបភាពជាច្រើន តួយ៉ាង ទំនាក់ទំនងខ្លះស្ថិតនៅជានិរន្តន៍យូរអង្វែង ខ្លះមានរយៈពេលខ្លី ខ្លះមានលក្ខណៈបិតបាំង ខ្លះបើកចំហជាសាធារណៈ ឬខ្លះទៀតត្រូវបានសង្គមទទួលស្គាល់ ឬមិនទទួលស្គាល់ជាដើម។ អ្វីដែលត្រូវពិចារណានោះថា តើការទាក់ទងគ្នាម្តងម្កាលអាចបង្កើតបានជា អនីតិសង្វាសដែរឬទេ?។ បើតាមលោក Jean Carbonnier *អនីតិសង្វាសខុសពីអាពាហ៍ពិពាហ៍ ហើយទម្រង់នៃសមគ្គសង្វាសក្រៅអាពាហ៍ពិពាហ៍ប្រភេទនេះ គឺមានលក្ខណៈជានិរន្តន៍។ ហើយអនីតិសង្វាស រួមផ្សំដោយ ការរស់នៅជាមួយគ្នា ការងារ ផ្ទះរួមគ្នា*។ ដូចនេះ ការទាក់ទងគ្នាម្តងម្កាល មិនបង្កើតបានជាអនីតិសង្វាសនេះទេ ពោល គឺអនីតិសង្វាសអាចកើតឡើងដោយត្រូវការពេលវេលាដែលមានរយៈពេលយូរអង្វែង ឬជានិរន្តន៍ជាដើម[41]។

### ១.២.៤. ភស្តុតាងនៃលក្ខខណ្ឌសារធាតុ

ខុសគ្នាពីសហព័ទ្ធស្របច្បាប់ដែលសំបុត្រអាពាហ៍ពិពាហ៍ គឺជាភស្តុតាងគតិយុត្តបញ្ជាក់ពីភាពស្របច្បាប់នៃសមគ្គសង្វាសរបស់ពួកគេ ឬ បញ្ជាក់ពីអត្ថិភាពនៃអាពាហ៍ពិពាហ៍របស់ពួកគេ។ ផ្ទុយទៅវិញ ដូចដែលបានពិភាក្សាខាងលើ អវត្តមាននៃសំបុត្រអាពាហ៍ពិពាហ៍ ឬអ៊ីតាស៊ីវិលបានកំណត់ពីអត្ថិភាពនៃអនីតិសង្វាស ទោះបីពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីក៏ដោយ។

នៅកម្ពុជាបច្ចុប្បន្ន ការងារគ្រប់គ្រង និងចុះបញ្ជីអត្រានុកូលដ្ឋាននៅមានកង្វះខាត និងទន់ខ្សោយនៅឡើយ ដែលវាបានបង្កនូវផលអវិជ្ជមានផ្នែកគតិយុត្តជាច្រើន។ ទោះបីអនីតិសង្វាសមិនបានចាត់ទុកជាសហព័ទ្ធស្របច្បាប់ក៏ដោយ ប៉ុន្តែគូស្វាមីអនីតិសង្វាសនៅតែអាចទទួលបានការធ្វើលិខិត ឬផ្តល់ឲ្យនូវលិខិតស្នាម និងឯកសារផ្សេងៗជាច្រើន រួមមានសៀវភៅស្នាក់ ឬបណ្ណ័គ្រួសារជាដើម។ ដោយហេតុនេះ លិខិតស្នាមផ្សេងៗដែលត្រូវបានបង្កើតឡើងដោយចំណងមួយនេះ តាមរយៈសកម្មភាពដែលកើតចេញពីជីវភាពរស់នៅបែបអនីតិសង្វាសរបស់ពួកគេ អាចប្រើប្រាស់ជាភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃអនីតិសង្វាសបាន។ ក៏ប៉ុន្តែ សៀវភៅស្នាក់នៅ ឬ បណ្ណ័គ្រួសារជាដើម មិនអាចយកមកបញ្ជាក់ពីអត្ថិភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់បាននោះទេ ពីព្រោះថា លិខិតទាំងនេះមិនមែនជាលិខិតអត្រានុកូលដ្ឋានដែលធ្វើឡើងដោយមន្ត្រីអត្រានុកូលដ្ឋាននោះទេ។ យ៉ាងណាមិញ ក្នុងភាពជាក់ស្តែងនៅតុលាការពេលមានបណ្តឹងផ្តាច់អនីតិសង្វាស ភស្តុតាងត្រូវបានដាក់ដោយសេរីដោយគូភាគី ព្រោះនៅតុលាការគ្មានការតម្រូវឲ្យគូភាគីដាក់លិខិតទាំងនោះជូនតុលាការនោះទេ[42]។ ក្រៅពីលិខិតស្នាមខាងលើ ដោយសារវាជាសមគ្គសង្វាសសេរី អត្ថិភាពនៃ

---

[41] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ១៩-២០។

[42] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២៦-២៧។

អនីតិសង្វាសអាចត្រូវបានបង្ហាញឡើងតាមរយៈមធ្យោបាយផ្សេងៗជាច្រើនទៀតដូចជា ការដាក់អាស័យដ្ឋានរួមគ្នាក្នុងបណ្ណ័សម្គាល់ម្ចាស់អចលនវត្ថុ ការចុះឈ្មោះរួមគ្នាក្នុងបណ្ណ័សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដូចជា ប្លង់កាន់កាប់ដីធ្លី ផ្ទះ លិខិតប្រកាសអាពាហ៍ពិពាហ៍ រូបថតរៀបអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ លិខិតអញ្ជើញចូលរួមអាពាហ៍ពិពាហ៍ ការបញ្ជាក់សមគ្គសង្វាស ឬភាពរួមរស់ក្នុងលក្ខណៈជាប្តីប្រពន្ធពីអាជ្ញាធរមូលដ្ឋាន (មេឃុំ ឬចៅសង្កាត់) ការដឹងឮពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរបស់ពួកគេជាដើម[43]។ ដោយសារតែគ្មានបទបញ្ញត្តិច្បាប់ដែលកំណត់ អនីតិសង្វាសគ្មានលក្ខខណ្ឌទម្រង់ជាលាយលក្ខណ៍អក្សរនេះទេ ហើយអត្ថិភាពនៃអនីតិសង្វាសអាចត្រូវបានបញ្ជាក់ដោយសេរី និង ប្រើប្រាស់ភស្តុតាង ឬ មធ្យោបាយផ្សេងពីៗគ្នាបាន ដោយហេតុថាអនីតិសង្វាសជាសមគ្គសង្វាសតាមព្រឹត្តិន័យកើតឡើងដោយឆន្ទៈរបស់បុរសនារី[44]។

ទោះបីជាយ៉ាងណាក៏ដោយ ភស្តុតាងដែលបង្ហាញឬដាក់ដោយសេរីរបស់ភាគី អាចត្រូវបានបដិសេធចោលដោយតុលាការក្នុងការអនុវត្តជាក់ស្តែង ដោយសារចៅក្រមមានឆន្ទានុសិទ្ធិសម្រេច និង ពិនិត្យទៅលើលក្ខខណ្ឌសារធាតុផ្សេងៗ ដើម្បីវិនិច្ឆ័យទទួលស្គាល់អត្ថិភាពនៃអនីតិសង្វាសរបស់គូភាគី[45]។

ក្រោយពីបានសិក្សាពីសញ្ញាណនៃអនីតិសង្វាស និងទិដ្ឋភាពគតិយុត្តរបស់ចំណងមួយនេះរួចហើយ យើងនឹងបន្តធ្វើការសិក្សាទៅលើអានុភាពនៃអនីតិសង្វាសបន្តទៀត ថាតើការរួមរស់នៅជាអនីតិសង្វាសនេះនឹងមានអានុភាពយ៉ាងណា? (**ជំពូកទី២**)

[43] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២៧។

[44] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ២៧-២៨។

[45] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៣០។

# ជំពូកទី២
# អានុភាពនៃអនីតិសង្វាស

បើទោះបីជាគ្មានលិខិតបទដ្ឋានគតិយុត្តកំណត់ច្បាស់លាស់មួយ សម្រាប់គ្រប់គ្រងចំណងបែបអនីតិសង្វាស និងគ្មានភាពឯកភាពគ្នាអំពីលក្ខខណ្ឌនៃការបង្កើតអនីតិសង្វាសក៏ដោយ តែក្រុមអ្នកច្បាប់ខ្មែរមានការយល់ឃើញស្រដៀងគ្នាអំពីអានុភាពនៃអនីតិសង្វាស។

បើយោងតាមឯកសាររបស់លោកមេធាវី **អ៊ីវ ប៊ូលី** និង **ចៅ ប៊ុនហួន** ក្នុងកិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍សិក្សាមួយ (២០១៨) របស់លោកប៊ុន រតនៈ ជាសិស្សថៅក្រមជំនាន់ទី៧ នៃរាជបណ្ឌិតសភាជីវៈតុលាការ ក្រោយលក្ខខណ្ឌចំនួន ២ ត្រូវបានបំពេញ គឺ**ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា** និង**ការរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធស្របច្បាប់** នោះករណីមួយចំនួនត្រូវបានបកស្រាយ ឬអនុវត្តដូចនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ផងដែរ។ ការបកស្រាយដូចអាពាហ៍ពិពាហ៍ មានដូចជា៖

- *ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នា*
- *សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ*
- *សិទ្ធិចូលរួមសកម្មភាពសង្គម*
- *បន្ទុកនៃសាហ៊ុយអាពាហ៍ពិពាហ៍*
- *ការគ្រប់គ្រងទ្រព្យសម្បត្តិ (ទ្រព្យរួម ទ្រព្យដោយឡែក និងការបែងចែកទ្រព្យរួម)*
- *ការទាមទារសំណងនៃការខូចខាត*
- *ការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូលជាដើម។*

យ៉ាងណាមិញ ទោះបីបានបំពេញលក្ខខណ្ឌនៃអនីតិសង្វាសក៏ដោយ ករណីមួយចំនួនទៀតមិនត្រូវបានបកស្រាយដូចនឹងអាពាហ៍ពិពាហ៍នោះទេ ដូចជា៖

- *នាមត្រកូលរបស់ប្តីប្រពន្ធ*
- *ការទទួលបាននីតិភាពដោយអាពាហ៍ពិពាហ៍*
- *កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ*
- *ការសន្មតបិតុភាព*
- *សន្តតិកម្ម*
- *អាហារកិច្ច ឬអាហារកាតព្វកិច្ច*
- *ការបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ*
- *ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក*

- *ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ*
- *មូលហេតុនៃការលែងលះជាដើម*[46, 47]។

## ២.១. ការបកស្រាយ ឬអនុវត្តដូចអាពាហ៍ពិពាហ៍

ទោះបីជាទំនាក់ទំនងបែបអនីតិសង្វាសមិនត្រូវបានទទួលស្គាល់ថាជាសហព័ទ្ធ ឬ ប្តីប្រពន្ធស្របច្បាប់ក៏ពិតមែន ក៏ប៉ុន្តែទំនាក់ទំនង និងជីវភាពរស់នៅរបស់ពួកគេ (សម្ព័ន្ធផ្លូវភេទ ទ្រព្យ និងលំនៅរួម) មានលក្ខណៈដូចជាប្តីប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដូច្នេះដែរ។ ខុសគ្នាមួយមានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល រីឯអនីតិសង្វាសគ្មាន[48]។ ដោយសារអវត្តមាននៃវិធានគតិយុត្តស្តីពីអនីតិសង្វាស អានុភាពនៃទំនាក់ទំនងនេះមិនបានកំណត់ក្នុងច្បាប់នោះទេ។

យ៉ាងណាមិញនៅពេលមានបណ្តឹងរំលាយ ឬ ផ្តាច់អនីតិសង្វាសនៅតុលាការ បទបញ្ញត្តិមួយចំនួននៃអាពាហ៍ពិពាហ៍ ត្រូវបានយកមកបកស្រាយលើចំណងអនីតិសង្វាស ឬប្រើប្រាស់ជាយុត្តិសាស្ត្រក្នុងការដោះស្រាយក្តីនៅតុលាការកម្ពុជា។ ដូចនេះ ក្រោយបំពេញតាមលក្ខខណ្ឌនៃអនីតិសង្វាស ករណីមួយចំនួនត្រូវបានបកស្រាយដូចអាពាហ៍ពិពាហ៍ស្របច្បាប់។

### ២.១.១. ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

អនុលោមតាមមាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី *ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។* បទបញ្ញត្តិដែលមានចែងក្នុងមាត្រានេះ គឺជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់ ឬប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់។ ម្យ៉ាងទៀតអាពាហ៍ពិពាហ៍ ឬ ប្តីប្រពន្ធស្របច្បាប់ និងអនីតិសង្វាសខុសគ្នាត្រង់ថាសហព័ទ្ធស្របច្បាប់មានអត្ថិភាពនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ រីឯអនីតិសង្វាសវិញមិនមានការចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ។ យ៉ាងណាមិញ យើងសង្កេតឃើញថា គូស្វាមីអនីតិសង្វាសមានជីវភាពរួម និងរស់នៅដូចគ្នាហ្នឹងប្តីប្រពន្ធស្របច្បាប់ផងដែរ ហើយពេលខ្លះក៏បានរៀបអាពាហ៍ពិពាហ៍ជាផ្លូវការតាមប្រពៃណី ឬមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ គ្រាន់តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។

ដូចនេះប្តីប្រពន្ធអនីតិសង្វាស ក៏មានករណីយកិច្ច រួមរស់ជីវភាពជាមួយគ្នា សហការ និង

---

[46] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៤-៥។

[47] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[48] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ជួយសង្គ្រោះគ្នាទៅវិញទៅមកដូចប្តីប្រពន្ធស្របច្បាប់ផងដែរ[49] ទោះបីគ្មានច្បាប់កំណត់ក៏ដោយ តែវាត្រូវបានមើលឃើញថាជាទំនៀមទំលាប់សង្គម ឬការអនុវត្តជាក់ស្តែងរបស់ប្តីប្រពន្ធទូទៅ។

### ២.១.២. សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ និងចូលរួមសកម្មភាពសង្គម

សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និងចូលរួមសកម្មភាពនយោបាយ វប្បធម៌ សង្គម គឺជាសិទ្ធដែលច្បាប់បានផ្តល់ឲ្យដល់ប្តី និងប្រពន្ធស្របច្បាប់ដែលបានកំណត់ក្នុងមាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា[50]។ ដូចគ្នានេះដែរ បញ្ញត្តិនេះក៏អនុវត្តន៍ចំពោះគូស្វាមីអនីតិសង្វាសផងដែរ ពោលគឺភាគីទាំងសងខាងទទួលបានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង ចូលរួមសកម្មភាពសង្គមនានា ដូចប្តីប្រពន្ធស្របច្បាប់[51]។

ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដោយអនុលោមតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ មិនតែប៉ុណ្ណោះ ប្រជាពលរដ្ឋខ្មែរគ្រប់រូបក៏មានសិទ្ធិជ្រើសរើសមុខរបរសមស្របទៅតាមសមត្ថភាពរបស់ខ្លួនរៀងៗខ្លួនផងដែរ[52]។ មានន័យថា ជាគោលការណ៍ ទោះបីគូស្វាមី អនីតិសង្វាសមិនបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ក៏ដោយ ក៏សិទ្ធិសេរីភាពរបស់ពួកគេត្រូវបានធានា និងផ្តល់ឲ្យយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញកម្ពុជា។ យ៉ាងណាមិញ ក្នុងករណីចំណងអនីតិសង្វាសដែលកើតឡើងដោយភាគីម្ខាងនៅមានចំណងអាពាហ៍ពិពាហ៍ (ការលួចមានប្តី-ប្រពន្ធលួចលាក់) សេរីភាពទាំងនេះអាចត្រូវបានរាំងស្ទះដោយសាធារណៈមតិ ទំនៀមទំលាប់ល្អ និង សីលធម៌របស់សង្គមផងដែរ។

### ២.១.៣. បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

យោងតាមមាត្រា ៩៧១ នៃក្រមរដ្ឋប្បវេណី *ប្តីប្រពន្ធត្រូវមានចំណែកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍។* ការទទួលខុសត្រូវលើបន្ទុកកើតពីអាពាហ៍ពិពាហ៍ ត្រូវអាស្រ័យទៅលើទ្រព្យសម្បត្តិ ប្រាក់ចំនូល និងស្ថានភាពផ្សេងៗ។ តួយ៉ាងនៅពេលរស់នៅបែកគ្នាជាដើម ភាគីដែលមានចំណូលតិចជាង អាចទាមទារឲ្យភាគីម្ខាងទៀតជួយទ្រទ្រង់ជីវភាពរបស់ខ្លួន រហូតដល់លែងលះចប់សព្វគ្រប់ ឬចាប់ផ្តើមរស់នៅជាមួយគ្នាឡើងវិញ។

---

[49] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៧។

[51] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[52] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា៣៥-៣៦។

ដូចគ្នានេះដែរ ចំពោះគូស្វាមីអនីតិសង្វាសវិញ ក៏ត្រូវទទួលស្គាល់ថាភាគីទាំងសងខាងត្រូវទទួលបន្ទុកដែលកើតចេញពីចំណងអនីតិសង្វាសរបស់ខ្លួនផងដែរ។ យ៉ាងណាមិញ ដោយសារការបញ្ចប់អនីតិសង្វាស ខុសគ្នាពីអាពាហ៍ពិពាហ៍ ពេលវេលាដែលតម្រូវឲ្យភាគីម្ខាងដែលមានចំណូលច្រើនជាង ជួយផ្គត់ផ្គង់ទៅដល់ភាគីម្ខាងទៀត មិនមានលក្ខខណៈច្បាស់លាស់ដូចការលែងលះរបស់អាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ដោយវាត្រូវវិនិច្ឆ័យទៅលើស្ថានភាពជាក់ស្តែង ពោលមានសិទ្ធិទាមទារក្នុងថេរវេលាជាក់លាក់ណាមួយ[53]។

### ២.១.៤. ទ្រព្យរួម និងទ្រព្យដោយឡែក

ដោយយោងទៅតាមច្បាប់ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានបែងចែកជាពីរ គឺ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់។ ហើយទ្រព្យសម្បត្តិប្តីប្រព័ន្ធត្រូវបានបែងចែកជាពីរផងដែរ គឺទ្រព្យរួម និងទ្រព្យដោយឡែក។ ទ្រព្យដោយឡែក គឺជាទ្រព្យដែលជាកម្មសិទ្ធរបស់សហព័ទ្ធណាម្នាក់ផ្តាច់មុខ ដូចជាទ្រព្យសម្បត្តិដែលសហទ័្ធទាំងសងខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យដែលភាគីទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទានដែលទទួលបាន ក្នុងកំឡុងពេលពួកគេមានចំណងប្តីប្រពន្ធនឹងគ្នាជាដើម នេះបើយោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី។ រីឯទ្រព្យរួមវិញ សំដៅលើទ្រព្យទាំងឡាយណាដែលសហព័ទ្ធទាំងសងខាង ឬតែម្ខាងរកបាន ឬ ទទួលបានក្នុងកំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍របស់ពួកគេ (លើកលែងប្រទានកម្ម សន្តតិកម្ម ឬ អច្ច័យទាន) នេះបើយោងតាមមាត្រា ៩៧៣ នៃក្រមដដែល។ បន្ថែមពីនេះទៅទៀត សហព័ទ្ធទាំងសងខាងមានសិទ្ធិស្មើៗគ្នា ក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យរួមនេះ ឯការប្រើប្រាស់វិញ ត្រូវស្ថិតនៅក្នុងទំហំចាំបាច់ណាមួយក្នុងជីវភាពជាក់ស្តែង និង គ្រប់គ្រងទ្រព្យរួមដោយសហការគ្នាជាដើម[54]។

ដូចគ្នានឹងអាពាហ៍ពិពាហ៍ដែរ ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ចំណងអនីតិសង្វាសក៏ត្រូវបានទទួលស្គាល់ ឬអនុលោមទៅតាមគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែកផងដែរ។ ជាពិសេសនៅពេលមានបណ្តឹងធ្វើឡើងដោយអនីតិសង្វាសជនទាមទារឲ្យធ្វើការបែងចែកទ្រព្យសម្បត្តិទៅតុលាការ គេឃើញថាគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែកក៏ត្រូវបានយកមកធ្វើជាគោលការណ៍ដើម្បីដោះស្រាយក្តីផងដែរ[55]។ ត្រង់ចំណុចនេះ វានឹងអាចកើតមានជាបញ្ហាចោទឡើងដើម្បី

---

[53] អ៊ុំ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧២-៩៧៤។

[55] អ៊ុំ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

កំណត់ថា តើចំណាងអនីតិសង្វាសត្រូវបានកំណត់នៅពេលជាក់លាក់ណាមួយឲ្យពិតប្រាកដ ដោយហេតុថា ចំពោះអាពាហ៍ពិពាហ៍ ទំនាក់ទំនងទ្រព្យសម្បត្តិកើតឡើងនៅក្រោយការចុះបញ្ជីអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ឬ នៅក្រោយការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយលក្ខណ៍អក្សរជាការចាំបាច់ ក្នុងករណីចង់បានប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ឬតាមកិច្ចសន្យា។ បើគ្មានការចុះបញ្ជីទ្រព្យសម្បត្តិទេ នោះកំណត់ថាប្រព័ន្ធទ្រព្យរបស់ពួកគេជាប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់[56]។ រីឯចំណាងអនីតិសង្វាសវិញ គ្មានទេអត្ថិភាពនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ ឬការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនោះឡើយ ។

សរុបមក ចំណុចដែលអនុវត្តន៍ដូចគ្នានឹងអាពាហ៍ពិពាហ៍ គឺទ្រព្យរួម និងទ្រព្យដោយឡែករបស់ប្តីប្រពន្ធ។ ដោយហេតុថាទ្រព្យដោយឡែក ជាទ្រព្យរបស់សហព័ទ្ធមុនការរៀបអាពាហ៍ពិពាហ៍ (ចុះបញ្ជីអាពាហ៍ពិពាហ៍) ដូចគ្នានេះដែរ ទ្រព្យដោយឡែករបស់អនីតិសង្វាស គឺជាទ្រព្យដែលភាគីនៃអនីតិសង្វាសជនមាន ឬ ទទួលបាននៅមុនពេលដែលចំណាងបែបអនីតិសង្វាសត្រូវបានបង្កើតឡើង។ ចំពោះសហព័ទ្ធស្របច្បាប់ ទ្រព្យរួមកើតឡើងក្រោយមានចំណាងអាពាហ៍ពិពាហ៍ ឬ នៅក្រោយការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ។ ចំពោះអនីតិសង្វាសវិញ ទ្រព្យរួមកើតឡើងនៅក្រោយពេលអនីតិសង្វាសជនមានជីវភាពរួមគ្នា ឬ ចាប់ផ្តើមរស់នៅជាប្តីប្រពន្ធលក្ខណៈជាអនីតិសង្វាសនេះឯង[57]។

❖ **កម្មសិទ្ធអវិភាគ**

បើតាមមតិផ្សេងទៀត ជាគោលការណ៍ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ មិនមានអានុភាពលើចំណាងអនីតិសង្វាសនោះទេ ហើយទ្រព្យរួមក៏មិនអាចកើតឡើងរវាងបុគ្គលនៃចំណាងអនីតិសង្វាសផងដែរ។ ក្នុងករណីចំណែកទ្រព្យសម្បត្តិរបស់អនីតិសង្វាសមិនអាចបែងចែកបាន ឬ មិនមានភាពច្បាស់លាស់ នោះគេអាចកំណត់ថាទ្រព្យទាំងនោះជាទ្រព្យនៃកម្មសិទ្ធអវិភាគ[58, 59]។ ដែលជាគោលការណ៍ បញ្ញត្តិនេះអាចត្រូវយកមកដោះស្រាយក្នុងករណីមានវិវាទក្នុងការប្រើប្រាស់ទ្រព្យ ឬមិនអាចព្រមព្រៀងគ្នាលើការគ្រប់គ្រង ឬថែរក្សាទ្រព្យទាំងនោះ[60]។ ពោលគឺ ទំនាក់ទំនងទ្រព្យសម្បត្តិនៃអនីតិសង្វាសមិនស្ថិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនោះទេ ដោយមូលហេតុថាប្រព័ន្ធទ្រព្យ

---

56 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

57 អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

58 ច្បាប់ភូមិបាល, លេខ នស/រកម/១៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៦៨, ១៦៩។

59 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២០២។

60 ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៥០។

សម្បត្តិប្តីប្រពន្ធ អនុវត្តចំពោះតែសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់តែប៉ុណ្ណោះ ហើយទ្រព្យរួមកើតមានលុះត្រាតែមានអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ។ ដូចនេះ មានន័យថា ទ្រព្យសម្បត្តិនៃអនីតិសង្វាស ស្ថិតនៅក្រោមរបបគតិយុត្តនៃកម្មសិទ្ធអវិភាគ[61]។

ច្បាប់ភូមិបាលបានចែងថា កម្មសិទ្ធិអវិភាគ គឺជាកម្មសិទ្ធលើទ្រព្យតែមួយដែលមានបុគ្គលច្រើននាក់ជាកម្មសិទ្ធិករ។ បុគ្គលទាំងនោះ ជាកម្មសិទ្ធិករអវិភាគនៃទ្រព្យមួយ ឬ ច្រើនរួមគ្នា។ ភាគបែងនៃកម្មសិទ្ធិអវិភាគចាត់ទុកថាស្មើគ្នា ហើយកម្មសិទ្ធករម្នាក់ៗមានសិទ្ធិ និងបន្ទុកសមាមាត្រចំពោះចំណែករបស់ខ្លួន ក្នុងករណីការបែងចែកទ្រព្យមិនស្មើគ្នា[62]។

ដូចគ្នានេះដែល នៅក្នុងក្រមរដ្ឋប្បវេណី កម្មសិទ្ធិអវិភាគត្រូវបានកំណត់ថា ជាស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ។ ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មត់ថាស្មើៗគ្នា ហើយម្ចាស់កម្មសិទ្ធអវិភាគ ម្នាក់ៗ អាចធ្វើអនុប្បទាន ឬដាក់ប្រតិភោគនូវចំណែករបស់ខ្លួនបាន។ ម្យ៉ាងទៀត ម្ចាស់កម្មសិទ្ធអវិភាគ ម្នាក់ៗប្រើប្រាស់កម្មសិទ្ធអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ខ្លួនបាន[63]។ ចំពោះការចាត់ចែងចំណែកទ្រព្យ ការប្រើប្រាស់ ការថែទាំ ការផ្លាស់ប្តូរមុខងារប្រើប្រាស់ ការគ្រប់គ្រងវត្ថុនៃកម្មសិទ្ធអវិភាគ និងសិទ្ធ ឬ បញ្ញត្តិផ្សេងៗទៀត មានកំណត់ក្នុងក្រមរដ្ឋប្បវេណី ពីមាត្រា ២០៤ ដល់មាត្រា ២១៤។

យ៉ាងណាមិញ តើកម្មសិទ្ធិអវិភាគត្រូវបានតុលាការយកមកប្រើដើម្បីបែងចែកទ្រព្យសម្បត្តិក្នុងរឿងក្តី ឬយ៉ាងណា យើងនឹងពិភាក្សានៅក្នុងជំពូកទី៣។

### ២.១.៥. ភាតព្វកិច្ចសាមគ្គី

ដោយយោងតាមមាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចដូចជា សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ពួកគេ សោហ៊ុយដើម្បីការអប់រំ ឬការព្យាបាលថែទាំកូនជាដើម រួមជាមួយកាព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀតដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នា ក្នុងការខ្ចីប្រាក់កាសដោយលិខិតស្នាមជាលាយលក្ខ័ណ៍អក្សរជាមួយម្ចាស់បំណុលក្នុងកំឡុងអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខ័ណ៍អក្សរពីប្រពន្ធ ឬប្តីម្ខាងទៀត។ នេះ គឺជាកាតព្វកិច្ចដែលកើតឡើងពីសកម្មភាពដែលប្តីប្រពន្ធស្របច្បាប់ត្រូវទទួលខុសត្រូវ

[61] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៩), ៣៩។

[62] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៥, ៣០ សីហា ២០០១។

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២០២-២០៥។

ក្នុងកំឡុងអាពាហ៍ពិពាហ៍របស់ខ្លួន។

ដូចគ្នានេះដែល បញ្ញត្តិនេះក៏ត្រូវបានបកស្រាយដូចគ្នាចំពោះចំណាងអនីតិសង្វាសផងដែរ។ រាល់ការចំណាយ និងចំណាងនានាដែលស្វាមីអនីតិសង្វាសបានធ្វើឡើង ដើម្បីទ្រទ្រង់ជីវភាពរួមរបស់ពួកគេ រួមមានការសិក្សារៀនសូត្រ ការថែទាំ ការព្យាបាលជំងឺកូនៗ ឬបំណុលនានាដែលត្រូវបានខ្ចីដោយអនីតិសង្វាស ជាលាយលក្ខណ៍អក្សរដោយមានការព្រមព្រៀងគ្នាពីភាគីទាំងសងខាងនោះ ត្រូវចាត់ទុកជាកាព្វកិច្ចសាមគ្គីរបស់អនីតិសង្វាសជនផងដែរ[64]។

### ២.១.៦. ការទាមទារសំណងនៃការខូចខាត

នៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណីបានចែងអំពីការទាមទារសំណងនៃការខូចខាតដោយការបំពានជីវិត ដោយចែងថា បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យាបានទទួលមរណភាព ដោយសារអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលនោះទទួលជីវព្រឹត្តិលែងបានដោយសារមរណភាពនៃជនរងគ្រោះ និង សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសពជាអាទ៍។

ក្នុងករណីនេះដែរ អនីតិសង្វាសជនដែលទទួលជីវព្រឹត្តិ អាចទាមទារនូវសំណងនៃការខូចខាតលើទ្រព្យសម្បត្តិដែលកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះដោយរាប់បញ្ចូលទាំងប្រាក់ជីវព្រឹត្តិ សោហ៊ុយចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសពជាដើម[65]។

### ២.១.៧. ការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល

ទាក់ទងនឹងការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល ផ្អែកលើកថាខណ្ឌទី៣ មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណី *បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុង១ថ្នាក់ និងញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន។* បញ្ញត្តិនេះ មានអានុភាពទៅលើតែប្តីប្រពន្ធស្របច្បាប់ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ និង ញាតិដែលកើតឡើងដោយច្បាប់តែប៉ុណ្ណោះ។ ជាក់ស្តែង បើពិនិត្យលើបញ្ញត្តិនេះ មានន័យថាអនីតិសង្វាសជនមិន

[64] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[65] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

អាចទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលនោះទេ។

យ៉ាងណាមិញ គេសង្កេតឃើញមានរបបគតិយុត្តថ្មីមួយបានកើតឡើងជាយុត្តិសាស្ត្ររបស់សាលាក្តីខ្មែរក្រហម ពាក់ព័ន្ធនឹងការទាមទារសំណងខូចខាតផ្នែកផ្លូវចិត្តដែលមានលក្ខខណៈជាសម្ភហភាពរបស់គូស្វាមីអនីតិសង្វាសក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម[66] ដោយជាគោលការណ៍អាចបញ្ជាក់បានថា អនីតិសង្វាសជាចំណងពិសេសនៃសេចក្តីស្រលាញ់ និងអនុញ្ញាតឲ្យភាគីនៃអនីតិសង្វាសប្តឹងទាមទារសំណងខូចខាតផ្អែកលើអំពើអនីត្យានុកូលនេះ[67]។ នាពេលខាងមុខ យុត្តិសាស្ត្រថ្មីមួយនេះរបស់តុលាការខ្មែរក្រហម អាចនឹងក្លាយទៅជាយុត្តិសាស្ត្រដើម្បីដោះស្រាយបណ្តឹងទាមទារសំណងខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលលើអនីតិសង្វាសជននៅក្នុងតុលាការកម្ពុជាផ្សេងៗទៀត ។

### ២.២. ការមិនបកស្រាយដូចអាពាហ៍ពិពាហ៍

ទោះបី បុរស និងនារីបានបំពេញលក្ខខណ្ឌនៃអនីតិសង្វាសក៏ដោយ ចំពោះករណីមួយចំនួនមិនត្រូវបានអនុវត្តន៍ ឬ បកស្រាយដូចនឹងអានុភាពរបស់អាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ដោយហេតុថាអនីតិសង្វាសមិនបានបង្កើតអានុភាពតាមផ្លូវច្បាប់នោះទេ បើទោះបីមានការយកបទបញ្ញត្តិមួយចំនួនរបស់អាពាហ៍ពិពាហ៍មកបកស្រាយលើទំនាក់ទំនងអនីតិសង្វាសនេះក៏ដោយ។

#### ២.២.១. នាមត្រកូលរបស់ប្តីប្រពន្ធ

យោងតាមមាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន។ យ៉ាងណាមិញបទបញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តចំពោះចំណងអនីតិសង្វាសនោះទេ ដោយហេតុថាគ្មានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែងអាចមានចន្លោះប្រហោង តាមរយៈការធ្វើសៀវភៅស្នាក់នៅ ឬបណ្ណគ្រួសារដល់ប្តីប្រពន្ធអនីតិសង្វាសដោយអាជ្ញាធរ មូលដ្ឋានជាដើម។

#### ២.២.២. ការទទួលបាននីតិភាពដោយអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍របស់ អនីតិជនអាចកើតឡើងបាន លុះត្រាតែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាទាំងសងខាង ឬម្ខាង ឬអាណាព្យាបាលសម្រាប់អនីតិជននោះ នេះបើអនុលោមតាមកថាខណ្ឌទី១ ទី២ មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី។ បើយោងតាមមាត្រា៩៦៨ នៃ

[66] សាលដីកាតុលាការខ្មែរក្រហម, សំណុំរឿងកាំងហ្គេចអ៊ាវ ហៅឌុច, ចុះថ្ងៃទី30/03/2012, 328-333។

[67] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ក្រមដដែលនេះ នៅពេលដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ។ ដូចនេះមានន័យថា ក្រោយអនីតិជនបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់នោះ ពួកគេនឹងទទួលបានអត្តាធិនភាពតាមរយៈអាពាហ៍ពិពាហ៍នោះដោយស្វ័យប្រវត្តិ ទោះបីបានលែងលះនៅពេលក្រោយក៏ដោយ (មាត្រា ២១ និងមាត្រា ២២ ក្រមរដ្ឋប្បវេណី) ហើយក៏មិនចាំបាច់មានសេចក្តីសម្រេចពីតុលាការក្នុងការផ្តល់អត្តាធិនភាពនោះទេ[68]។

យ៉ាងណាមិញ បញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តន៍ចំពោះអនីតិសង្វាស[69] ដែលរស់នៅជាមួយគ្នាខណៈពួកគេមិនទាន់មានអាយុចាប់ពី១៨ឆ្នាំ ឬដល់នីតិភាពនោះទេ។ ការទទួលបាននីតិភាពក្រោយអាពាហ៍ពិពាហ៍ អនុវត្តន៍តែចំពោះអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់បណ្ណោះ ឬមានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍របស់គូស្វាមីជាអនីតិជនជាដើម។

### ២.២.៣. កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនេះត្រូវបានបែងចែកជាពីរគឺ ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធកំណត់ដោយច្បាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមប្រព័ន្ធកិច្ចសន្យាដោយឡែក[70]។ សហព័ទ្ធទាំងសងខាងអាចជ្រើសរើសនូវប្រព័ន្ធកិច្ចសន្យាណាមួយដើម្បីកំណត់ពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេ ក្នុងកំឡុងនៃចំណងអាពាហ៍ពិពាហ៍របស់ពួកគេ ឬបែងចែកនៅក្រោយពេលលែងលះគ្នា។ ប្រសិនបើគ្មានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះទេ នោះទំនាក់ទំនងទ្រព្យរបស់សហព័ទ្ធក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឬនៅក្រោយពេលលែងលះគ្នានឹងអនុលោមតាមគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែកដែលមានចែងនៅក្នុងច្បាប់ (មាត្រា៩៦៩នៃក្រមរដ្ឋប្បវេណី)។

ខុសគ្នាពីអាពាហ៍ពិពាហ៍ស្របច្បាប់ ចំណងអនីតិសង្វាសមិនមានជម្រើសក្នុងជ្រើសរើសការកំណត់ពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេនោះទេ ដោយហេតុថាមិនមានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងទម្រង់ជាលាយលក្ខណ៍អក្សរនោះឡើង។

យ៉ាងណាមិញ ការកំណត់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធរបស់អនីតិសង្វាសត្រូវបានអនុវត្តន៍ដូចនឹងអាពាហ៍ពិពាហ៍ដែលមិនមានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពោល គឺ

[68] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[69] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[70] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។

ត្រូវបកស្រាយដូចប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់[71]។

### ២.២.៤. ការសន្មតបិតុភាព

ចំពោះការកំណត់មាតុភាព មានភាពងាយស្រួលកំណត់ជាងបិតុភាព។ ដោយហេតុថា ស្ត្រីដែលជាអ្នកពរពោះកូន ឬស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន នេះបើយោងតាមមាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា។ បញ្ញត្តិនេះបញ្ជាក់យ៉ាងច្បាស់ថា មាតុភាពកើតឡើងដោយសារអង្គហេតុនៃការសម្រាលកូននេះ មានន័យអ្នកដែលបង្កើតកូននោះត្រូវសន្មតថាជាម្ដាយរបស់កូន[72]។ យ៉ាងណាមិញ ការកំណត់បិតុភាពមានភាពលំបាកចំពោះចំណងបែបអនីតិសង្វាស។ ប្រសិនបើភាគីជាប្ដីនៃចំណងអនីតិសង្វាសទទួលស្គាល់កូន ឬ ទារកដែលកំពុងពរពោះដោយស្ត្រីដែលជាប្រពន្ធនេះ វាមិនចោទឡើងនូវបញ្ហានោះទេ។ ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់វិញ ការកំណត់បិតុភាពត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុងច្បាប់ ហើយទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវសន្មតថាជាកូនរបស់ប្ដី[73]។

ករណីនេះមិនអាចអនុវត្តចំពោះអនីតិសង្វាសនោះទេ ដោយហេតុថាចំណងអនីតិសង្វាសគ្មានព្រឹត្តការណ៍នៃការសន្មតតាមច្បាប់ដូចអាពាហ៍ពីពាហ៍ស្របច្បាប់ ឬ គ្មានទំនាក់ទំនងជាឪពុក និង កូននោះទេ។ ហេតុនេះកូនដែលកើតពីប្ដីប្រពន្ធអនីតិសង្វាស ភាពជាឪពុក (បិតុភាព) កើតមានឡើង លុះត្រាតែមានការទទួលស្គាល់ពីឪពុកចំពោះកូននោះ[74]។

### ២.២.៥. អំណាចមេបាសហការ ឬអំណាចមេបារួម

អំណាចមេបា គឺជាសិទ្ធិ និង ករណីកិច្ចក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះ។ ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ ប្ដីប្រពន្ធដែលកើតចេញ ពីចំណងអាពាហ៍ពិពាហ៍ស្របច្បាប់នេះ ពួកគេដែលត្រូវជាឪពុកម្ដាយ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាចំពោះកូនដែលជាអនីតិជន ឬប្រសិនបើឪពុក ឬម្ដាយណាម្ខាងមិនអាចប្រើប្រាស់អំណាចមេបាបានទេក្នុងករណីភាគីម្ខាងបាត់បង់សតិ បាត់ខ្លួន ឬមិនអាចទាក់ទងបាន នោះឪពុក ឬម្ដាយម្ខាងទៀតត្រូវប្រើប្រាស់អំណាចមេបានោះ[75, 76]។

---

[71] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[72] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឺទី៧, ០៦ ឧសភា ២០១០, មាត្រា៩៨៧។

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៨។

[74] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៩៣-៩៩៩។

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៦។

[76] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឺទី៧, ០៦ ឧសភា ២០១០, មាត្រា១០៣៦។

យ៉ាងណាមិញចំពោះ ទំនាក់ទំនងបែបអនីតិសង្វាសវិញ អំណាចមេបាសហការគ្នានេះមិនមានឡើយតាមផ្លូវច្បាប់ ទោះបីក្នុងជីវភាពជាក់ស្តែង ពួកគេអនុវត្តអំណាចមេបាដោយសហការគ្នាក៏ដោយ។ បើយើងពិនិត្យមើលការកំណត់ក្នុងកថាខណ្ឌទី១ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណីវិញ *ចំពោះស្ត្រីដែលមិនទាន់រៀបអាពាហ៍ពិពាហ៍(ស្របច្បាប់) ហើយបានផ្តល់កំណើតដល់កូន នោះអ្នកមានអំណាចមេបាលើកូនគឺស្ត្រីដែលជាម្តាយនោះ*[77]។ ក្នុងកថាខណ្ឌទី២នៃមាត្រាដដែល ឪពុកអាចក្លាយជាអ្នកមានអំណាចមេបាទៅលើកូនដែលខ្លួនទទួលស្គាល់បាន លុះត្រាតែមានការពិភាក្សារវាងឪពុកម្តាយទាំងពីរ ហើយបានកំណត់ថាឪពុកនោះជាអ្នកមានអំណាចមេបា[78]។

ក៏ប៉ុន្តែ ចំពោះករណីនេះដដែល ទោះបីឪពុក ឬ ម្តាយនៃចំណងអនីតិសង្វាសត្រូវបានកំណត់ជាអ្នកមានអំណាចមេបាក៏ដោយ ក៏មិនមែនមានន័យថាវាជាអំណាចមេបាសហការគ្នាដូចអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ពោលក្នុងករណីឪពុក និងម្តាយមិនបានរៀបអាពាហ៍ពិពាហ៍ដូចនេះ អំណាចមេបាទៅលើកូននៅតែជា**អំណាចមេបាទោល**ដដែល។ ពោល គឺមានតែភាគីម្ខាងនៃអនីតិសង្វាសទេដែលមានអំណាចមេបាចំពោះកូននោះ។ ក៏ប៉ុន្តែ ប្រសិនបើម្តាយបដិសេធចំពោះសំណើររបស់ឪពុក នោះឪពុករបស់កូនអាចធ្វើការទាមទារតាមផ្លូវតុលាការ នេះបើអនុលោមតាមកថាខណ្ឌបន្ទាប់នៃមាត្រាដដែល[79]។

សរុបសេចក្តីមក អំណាចមេបាសហការ ឬអំណាចមេបារួម គឺជាអានុភាពគតិយុត្តរបស់អាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ ខណៈចំណងអនីតិសង្វាសមិនបង្កើតបានជាអានុភាពដូចគ្នានោះទេ ហើយអំណាចមេបារបស់ចំណងអនីតិសង្វាស ទៅលើកូននៅតែជាអំណាចមេបាទោលដដែល[80]។ យ៉ាងណាមិញនៅក្នុងជីវភាពជាក់ស្តែង ប្តីប្រព័ន្ធអនីតិសង្វាសបានអនុវត្តអំណាចមេបាដោយសហការគ្នាក្នុងការបីបាច់ថែរក្សា ផ្គត់ផ្គង់ និងគ្រប់គ្រងកូនៗរបស់ខ្លួនដែលជាអនីតិជន ដូចគ្នានឹងសហព័ទ្ធដែលមានអាពាហ៍ស្របច្បាប់ផងដែរ ទោះបីគ្មានច្បាប់កំណត់ក៏ដោយ។

### ២.២.៦. ការបង្កើតចំណងញាតិ

បើយោងតាមមាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា ញាតិត្រូវបានកំណត់ចំពោះបុគ្គលៈ ទី១ ញាតិលោហិតក្នុង៦ថ្នាក់ ទី២ សហព័ទ្ធ ទី៣ ញាតិពន្ធក្នុង៣ថ្នាក់។ ញាតិលោហិត សំដៅទៅលើបុគ្គលដែលមានទំនាក់ទំនងសាច់សារលោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (រវាងម្តាយនិងកូន) ឬ បុគ្គលដែលត្រូវចាត់ទុកដោយច្បាប់ថាមានទំនាក់ទំនងសាច់សារលោហិតជាមួយបុគ្គល

[77] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹះទី៧,០៦ ឧសភា ២០១០, មាត្រា១០៣៨។
[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៨។
[79] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹះទី៧,០៦ ឧសភា ២០១០, មាត្រា១០៣៨។
[80] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៤៥។

ជាក់លាក់ម្នាក់ទៀត (ញាតិលោហិតដែលកំណត់ដោយច្បាប់)[81]។

រីឯសហាព័ទ្ធក្នុងបញ្ញត្តិនេះ គឺសំដៅទៅលើប្ដីប្រព័ន្ធដែលបានរៀបអាពាហ៍ពិពាហ៍ចប់ចុងចប់ដើមតាមផ្លូវច្បាប់។ ដូចនេះប្ដីប្រព័ន្ធអនីតិសង្វាសមិនបានបង្កើតនូវចំណងញាតិនៅក្នុងមាត្រានេះទេ ដោយហេតុថាពួកគេមិនត្រូវបានចាត់ទុកជាសហាព័ទ្ធតាមផ្លូវច្បាប់នោះទេ[82]។

ចំពោះញាតិពន្ធវិញ គឺសំដៅទៅលើទំនាក់ទំនងរវាងបុគ្គលម្នាក់ជាមួយនឹងញាតិលោហិតរបស់សហាព័ទ្ធរបស់ខ្លួន ឬរវាងញាតិលោហិតខ្លួនជាមួយនឹងសហាព័ទ្ធរបស់ខ្លួន។ ក្នុងករណីនេះ អនីតិសង្វាសក៏មិនបានបង្កើតឲ្យមានចំណងញាតិពន្ធរវាងប្ដីប្រពន្ធអនីតិសង្វាស ឬ រវាងញាតិលោហិតរបស់ពួកគេជាមួយនឹងសហាព័ទ្ធម្ខាងទៀតនៃអនីតិសង្វាសដូចគ្នា[83]។

យ៉ាងណាមិញ នៅក្នុងជីវភាពជាក់ស្ដែង ការបង្កើតចំណងញាតិក្រៅផ្លូវច្បាប់រវាងប្ដីប្រពន្ធអនីតិសង្វាសហាក់មានភាពទូលំទូលាយ ដោយហេតុថា ចំណងមួយប្រភេទនេះត្រូវបានបង្កើតឡើងជាទូទៅនៅក្នុងសង្គមខ្មែរ។ ម្យ៉ាងបើសង្កេតមើលទៅលើបរិបទសង្គម និង ផ្នត់គំនិតរបស់ប្រជាពលរដ្ឋក្នុងសង្គមបច្ចុប្បន្ន ការបង្កើតចំណងញាតិត្រូវបានចាត់ទុកថាបានបង្កើតឡើងក្រោយពេលដែលបុរស និង នារីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីច្រើនជាង បើទោះបីគ្មានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ ឬចំណងញាតិកើតឡើងនៅពេលដែលបុរស និង នារីបានសម្រេចចិត្តរួមសមគ្គសង្វាសជាមួយគ្នាដោយការព្រមព្រៀង។ ពោល គឺស្ថិតក្រោមរូបនៃអនីតិសង្វាសនេះឯង។ ហើយនៅពេលខ្លះចំណងញាតិដែលអនីតិសង្វាសជនបង្កើតឡើងដោយខ្លួនឯង ហាក់មានទំនាក់ទំនងស្និទ្ធស្នាល និងរឹងមាំជាងចំណងញាតិដែលបង្កើតឡើងតាមផ្លូវច្បាប់ទៀតផង។

យ៉ាងណាមិញ ផលវិបាក និង វិវាទខាងផ្លូវច្បាប់តែងតែកើតមានឡើងនៅពេលដែលមានបណ្ដឹងទាមទារឲ្យរំលាយអនីតិសង្វាស។

### ២.២.៧. សន្តតិកម្ម

ចំពោះសន្តតិកម្ម សហាព័ទ្ធត្រូវបានកំណត់ថាជាសន្តតិជនជានិច្ច ស្របតាមការកំនត់ដោយច្បាប់[84] ។ មានន័យថា ប្ដី ឬ ប្រពន្ធរបស់មរតកជននឹងត្រូវឡើងមកទទួលមរតកដែលបន្សល់ទុកដោយមរតកជន ឬទទួលបានចំណែកចែកទ្រព្យមរតកនោះ។ សហាព័ទ្ធក្នុងន័យនេះសំដៅទៅលើតែប្ដី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់តែប៉ុណ្ណោះ។

---

[81] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹទី៧.០៦ ឧសភា ២០១០, មាត្រា៩៣៨។

[82] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៣១។

[83] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹទី៧.០៦ ឧសភា ២០១០, មាត្រា៩៣៨។

[84] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១។

ដូចនេះ គូភាគីនៃអនីតិសង្វាស មិនត្រូវបានចាត់ទុកជាសន្តតិជនជានិច្ចដែលត្រូវឡើងមកទទួលមរតកដូចសហព័ទ្ធស្របច្បាប់នោះទេ[85] ក៏ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងអាចមានភាពផ្ទុយពីនេះ។

ទោះជាយ៉ាងណាក៏ដោយ ភាគីនៃអនីតិសង្វាសអាចនឹងទទួលបានមរតក ឬមានសិទ្ធិទទួលបានចំណែកមរតកដោយករណី ឬស្ថានភាពពីរ។ ករណីទី១ គឺអនីតិសង្វាសទទួលបានទ្រព្យសម្បត្តិតាមរយៈបណ្តាំ ឬ មតកសាសន៍ដែលធ្វើឡើងដោយមរតកជននោះ។ យ៉ាងណាមិញ ចំណែកទាំងនោះមិនអាចប្រគល់ឲ្យដល់ភាគីអនីតិសង្វាសដោយបំពានលើចំណែកនៃភាគបម្រុងឡើយ[86, 87]។ ករណីទី២ ប្រសិនបើគ្មានបណ្តាំបន្សល់ទុក ឬ ធ្វើឡើងដោយមរតកជននោះទេ នោះអនីតិសង្វាសអាចទទួលបានមរតកដោយបកស្រាយទៅតាមបញ្ញត្តិស្តីពីការបែងចែកមរតកឲ្យទៅជនដែលមាននិស្ស័យពិសេស[88]។

ចំពោះករណីទី១ សហព័ទ្ធម្ខាងនៃអនីតិសង្វាសអាចទទួលបានទ្រព្យសម្បត្តិតាមរយៈបណ្តាំ ឬ មតកសាសន៍ដែលបានបន្សល់ទុក ផ្តល់ឲ្យដោយមរតកជនក្រោមរូបភាពជាអច្ច័យទាន ហើយអនីតិសង្វាសជនទទួលបានទ្រព្យទាំងនោះក្នុងនាមជាអច្ច័យលាភី គឺមិនមែនក្នុងនាមជាសន្តតិជននោះទេ។ អច្ច័យទាន អាចធ្វើឡើងក្រោមរូបភាពពីរ គឺទី១ អច្ច័យទានសកល ដែលជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ។ រីឯអច្ច័យទានមានកំណត់វិញ ជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ណាមួយ (ផ្ទះ ដីធ្លី ចលនវត្ថុ ជាដើម) ទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់តាមរយៈបណ្តាំរបស់ខ្លួន[89, 90]។

ចំពោះករណីទី២ អនីតិសង្វាសអាចទទួលបានមរតកដោយបកស្រាយ តាមមាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណី អំពីការបែងចែកមរតកឲ្យទៅជនដែលមាននិស្ស័យពិសេសបាន។ អនុលោមតាមមាត្រានេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមរតកដែលនៅសល់ក្រោយការជម្រះទៅឲ្យជនដែលមានជីវភាពជាមួយគ្នានឹងមរតកជន ជនដែលបានខិតខំមើលថែទាំថែរក្សាមរតកជន និងជនដែលមាននិស្ស័យផ្សេងទៀត តាមពាក្យសុំរបស់ជននោះ។ ប៉ុន្តែចំនួនសរុបនៃ

---

85 អ៊ីរ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

86 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៨២។

87 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, ជំពូកទី៥។

88 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១២៩៩។

89 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៩៩។

90 បាន លក្ខិណា និង រ៉ាត់ រ៉ាទី, *ទំនាក់ទំនងទ្រព្យសម្បត្តិនៃសហព័ទ្ធ និងអនីតិសង្វាស*. (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ២០១៧) , ៥៥។

តម្លៃទ្រព្យដែលត្រូវចែកទៅឲ្យនោះ មិនត្រូវឲ្យលើសពីចំនួនពាក់កណ្តាលនៃមរតកដែលនៅសេសសល់នោះទេ។ ហើយពាក្យសុំរបស់ជនដែលមាននិស្ស័យពិសេសនេះ ត្រូវធ្វើឡើងនៅក្នុងកំឡុងពេល៣ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនេះឲ្យបានច្បាស់លាស់។ ក្នុងការបែងចែកទ្រព្យនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុ ដោយអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់នៅមូលដ្ឋានបាន។

ចំពោះសហព័ទ្ធនៃអនីតិសង្វាស ពួកគេហាក់បានបំពេញលក្ខខណ្ឌនៃជនដែលមាននិស្ស័យពិសេសដូចបានកំណត់ក្នុងមាត្រាខាងលើ ដោយហេតុថាទំនាក់ទំនងនៃអនីតិសង្វាសជន គឺមានលក្ខណៈស៊ីជម្រៅ ស្និទ្ធស្នាល ឬ មិនខុសគ្នាពីសហព័ទ្ធស្របច្បាប់នោះទេ។ ដូចនេះ ប្រសិនបើអនីតិសង្វាសត្រូវបានទទួលស្គាល់ក្នុងឋានៈជាជនដែលមាននិស្ស័យពិសេសនោះ អនីតិសង្វាសជនអាចទទួលបាននូវចំណែកមរតកពីសហព័ទ្ធរបស់ខ្លួននៃចំណងអនីតិសង្វាសដែលបានទទួលមរណភាព[91]។

### ២.២.៨. អាហារកិច្ច ឬ អាហារកាតព្វកិច្ច

យោងតាមមាត្រា ៧៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ទោះបីប្តីប្រពន្ធបានលែងលះគ្នាក៏ដោយ ហើយភាគីមានកំហុស ភាគីនោះត្រូវទទួលខុសត្រូវចំពោះ**អាហារកិច្ច** ប្រសិនបើមានការស្នើសុំពីសហព័ទ្ធម្ខាងទៀត[92]។ ក្នុងន័យនេះ អាហារកិច្ចកើតឡើងចំពោះតែប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ប៉ុណ្ណោះ ផ្ទុយមកវិញ ករណីនេះមិនត្រូវបានអនុវត្តន៍ឡើយចំពោះចំណងអនីតិសង្វាសនៅពេលមានបណ្តឹងផ្តាច់អនីតិសង្វាស ទោះបីភាគីម្ខាងមានកំហុសក៏ដោយ[93]។ រីឯក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ត្រង់មាត្រា ១១៤០ វិញ បានទទួលស្គាល់**អាហារកាតព្វកិច្ច**រវាងញាតិនឹងញាតិ ។

នៅពេលមានបណ្តឹងផ្តាច់ ឬបញ្ឈប់ការរួមរស់ជាអនីតិសង្វាស អនីតិសង្វាសជនតែងតែទាមទារអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតក្នុងផលប្រយោជន៍ផ្ទាល់ខ្លួន ឬ សម្រាប់ទ្រទ្រង់ចិញ្ចឹមកូន[94]។ នៅក្នុងករណីមួយនេះ ប្រសិនបើតុលាការទទួលស្គាល់ស្គាល់អត្ថិភាពនៃអាហារកិច្ចរវាង

---

[91] បាន លក្ខិណា និង រ៉ាត់ រ៉ាទី, *ទំនាក់ទំនងទ្រព្យសម្បត្តិនៃសហព័ទ្ធ និងអនីតិសង្វាស*. (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧) , ៥៥។

[92] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៧៦។

[93] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[94] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៥៤។

អនីតិសង្វាសទាំងពីរដូចគ្នានឹងអាហារកាតព្វកិច្ចនៃសហព័ទ្ធស្របច្បាប់នោះ វាអាចលេចឡើងជាបញ្ហានៅពេលដែលសេចក្ដីសម្រេចរបស់តុលាការបានបង្គាប់ឲ្យភាគីណាមួយនៃអនីតិសង្វាស ផ្ដល់នូវអាហារកាតព្វកិច្ចដល់ភាគីម្ខាងទៀតក្នុងការទ្រទ្រង់កូន ព្រោះថាការមិនផ្ដល់នូវអាហារកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ គឺចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ (បទមជ្ឈឹម)[95, 96]។

យ៉ាងណាមិញ នៅក្នុងតុលាការមួយចំនួន ភាគីនៃអនីតិសង្វាសនៅតែអាចទាមទារអាហារកាតព្វកិច្ចដោយសាលក្រមរបស់តុលាការ ប៉ុន្តែជំនួសដោយពាក្យ *សោហ៊ុយចាំបាច់សម្រាប់ទទួលបន្ទុកគ្រប់គ្រងថែរក្សាកូន*[97]។

### ២.២.៩. ការចាត់ចែងទ្រព្យរួមរបស់ប្ដីប្រពន្ធ

យោងមាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី ការចាត់ចែងទ្រព្យសម្បត្តិរួម ត្រូវមានការយល់ព្រមពីប្ដីប្រពន្ធទាំងសងខាង ឬ អាចចាត់ចែងបានដោយភាគីណាម្ខាងក្នុងស្ថានភាពពិសេសសម្រាប់ជីវភាពរួមរបស់ប្ដីប្រពន្ធ ដោយមានការអនុញ្ញាតពីតុលាការ បើមិនដូច្នេះទេ សហព័ទ្ធម្ខាងទៀតដែលមិនយល់ព្រមអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការ[98]។ ត្រង់ចំណុចនេះយើងឃើញថា គ្មានទ្រព្យសម្បត្តិរួមណាមួយអាចត្រូវផ្លាស់ប្ដូរ ឬចាត់ចែងដោយគ្មានការយល់ព្រមដោយសហព័ទ្ធម្ខាងទៀតនោះទេ[99]។

យ៉ាងណាមិញ សិទ្ធិទាំងនេះបានផ្ដល់ជូនចំពោះតែសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ប៉ុណ្ណោះ ចំពោះអនីតិសង្វាសវិញ គោលការណ៍នេះមិនត្រូវបានបកស្រាយប្រដូចនឹងអាពាហ៍ពិពាហ៍នោះទេ។ ពោល គឺសិទ្ធិទាមទារចាត់ចែងទ្រព្យសម្បត្តិរួមប្ដីប្រពន្ធមិនបានយកមកអនុវត្តន៍ចំពោះប្ដីប្រពន្ធនីតិសង្វាសនោះទេ។ ម្យ៉ាងទៀត ការចាត់ចែងទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀតដោយគ្មានការយល់ព្រមពីម្ចាស់ទ្រព្យ ភាគីម្ខាងទៀតនៃអនីតិសង្វាសអាចត្រូវប្រឈមមុខនឹងទោសព្រហ្មទណ្ឌផងដែរ តួយ៉ាង ដូចជាករណីលួចជាដើម ព្រោះអភ័យឯកសិទ្ធគ្រួសារគ្មានទេចំពោះចំណងអនីតិសង្វាសនោះទេ ដោយហេតុថាវាអាស្រ័យទៅលើគោលការណ៍ស្មគ្រ័ចិត្ត និងការអធ្យាស្រ័យចំពោះគ្នានឹងគ្នារវាងប្ដីប្រពន្ធអនីតិសង្វាសប៉ុណ្ណោះ។

---

[95] ក្រមពហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៤។
[96] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៥៧។
[97] សាលក្រមរដ្ឋប្បវេណីលេខ ៣៧៤ (ជ) របស់សាលាដំបូងខេត្តបាត់ដំបង ចុះថ្ងៃទី២៨/០៧/២០១៦ នៃសំនុំរឿងរដ្ឋប្បវេណី។
លេខ ១៩៦ ចុះថ្ងៃទី ២៥/០៣/២០១៦។
[98] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
[99] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹទី៧, ០៦ ឧសភា ២០១០, មាត្រា៩៧៦។

### ២.២.១០. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

យោងមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។ ដូចនេះ ទោះបីសហព័ទ្ធម្ខាងបានចាត់ចែងទ្រព្យសម្បត្តិជាអចលនវត្ថុដែលជាទ្រព្យដោយឡែករបស់ខ្លួនក៏ដោយ ក៏សហព័ទ្ធម្ខាងទៀតនៅតែអាចបន្តអាស្រ័យនៅលើអចលនវត្ថុនោះបានដែរ[100]។ ត្រង់ចំណុចនេះ ច្បាប់បានផ្តល់សិទ្ធពិសេសមួយចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍ស្របច្បាប់ ដើម្បីធានានូវសិទ្ធអាស្រ័យនៅរបស់សហព័ទ្ធម្ខាងទៀត ក្នុងករណីដែលទ្រព្យសម្បត្តិដោយឡែកនោះត្រូវបានប្រើប្រាស់ជាអចលនវត្ថុ ដូចជា ផ្ទះសំបែង ជាដើម សម្រាប់ការអាស្រ័យនៅរបស់ប្តីប្រពន្ធ។

ផ្ទុយទៅវិញ សិទ្ធិនេះមិនបានផ្តល់ឲ្យចំពោះចំណងអនីតិសង្វាសនោះទេ ដោយហេតុថាច្បាប់មិនបានទទួលស្គាល់នូវចំណងមួយនេះថាស្របច្បាប់។ ដោយហេតុថា អនីតិសង្វាស កើតឡើងដោយការព្រមព្រៀងគ្នា ដូចនេះ សិទ្ធនេះអាចត្រូវបានអនុវត្តនក្នុងលក្ខណៈជាការអនុគ្រោះយោគយល់អធ្យាស្រ័យរបស់ភាគីម្ខាងនៃអនីតិសង្វាស ដែលជាកម្មសិទ្ធករលើអចលនវត្ថុនោះ ឬការអនុគ្រោះឲ្យអាស្រ័យនៅលើទ្រព្យដោយឡែករបស់ភាគីម្ខាងនៃអនីតិសង្វាសចំពោះភាគីម្ខាងទៀតប៉ុណ្ណោះ។ ដូចនេះ បទបញ្ញត្តិនេះមានអានុភាពចំពោះតែអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ រីឯភាគនៃចំណងបែប អនីតិសង្វាសមិនទទួលបានសិទ្ធិនេះនោះទេ។

### ២.២.១១. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

ចំពោះបទល្មើសព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើដែលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ[101]។ ចំពោះចំណងអនីតិសង្វាស ភាគីអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌក្នុងករណីមួយចំនួន។

ជាក់ស្តែង ក្រមព្រហ្មទណ្ឌកម្ពុជា ត្រង់មាត្រា៣៥៥ បានចែងពីអភ័យឯកសិទ្ធិគ្រួសារដែលអាចឲ្យភាគីដែលប្រព្រឹត្តិអំពើលួចទ្រព្យសម្បត្តិរបស់សហពទ្ធ័រួចផុតពីការទទួលទោសព្រហ្មទណ្ឌបាន[102]។ យ៉ាងណាមិញ យោងតាមមាត្រា ៥ នៃក្រមព្រហ្មទណ្ឌ ជាគោលការណ៍ក្រមព្រហ្មទណ្ឌកំនត់ឲ្យមានការបកស្រាយយ៉ាងតឹងរឹងក្នុងរឿងក្តីព្រហ្មទណ្ឌ ឬមិនអនុញ្ញាតឲ្យចៅក្រមបកស្រាយ

[100] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[101] ក្រមពហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៤។

[102] ក្រមពហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥៥។

ប្រដូច ឬ បកស្រាយលក្ខណៈសទិសន័យនោះទេ។ ដូចនេះ ភាគីនៃអនីតិសង្វាសដែលបានប្រព្រឹត្តិអំពើលួចទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ[103] ដោយហេតុថា សហព័ទ្ធដែលទទួលបានអភ័យឯកសិទ្ធិគ្រួសារ នៅពេលប្រព្រឹត្តិអំពើលួចបានក្នុងន័យនេះសំដៅចំពោះតែប្ដីប្រពន្ធស្របច្បាប់តែប៉ុណ្ណោះ រីឯ អនីតិសង្វាសមិនត្រូវបានទទួលស្គាល់ថាជាប្ដីប្រពន្ធស្របច្បាប់នោះទេ។ យ៉ាងណាមិញ ភាគីនៃចំណងអនីតិសង្វាសដែលបានប្រព្រឹត្តបទល្មើសលួច អាចរួចខ្លួនក្នុងករណីផ្សេងប៉ុណ្ណោះ ដូចជា ការដកពាក្យបណ្ដឹងរបស់គូភាគី ការយោគយល់អធ្យាស្រ័យ ឬ អត់ឱនដោយម្ចាស់ទ្រព្យដែលជាភីនៃចំណង អនីតិសង្វាសប៉ុណ្ណោះ។

ម្យ៉ាងទៀត បើយោងទោតាមច្បាប់ឯកពន្ធភាព និងគ្រួសារ សហព័ទ្ធនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសទាក់ទងនឹងអាពាហ៍ពិពាហ៍មួយចំនួន ដូចជា៖

- បទល្មើសផិត៖ ការរួមសេវនកិច្ចរបស់បុរស ឬ នារីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ពីមុន ជាមួយបុរស ឬនារីដទៃទៀតដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន ខណៈពេលដែលអាពាហ៍ពិពាហ៍ពីមុនមិនទាន់បានរំលាយ។
- ទ្វេរពន្ធភាព៖ ការចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីជាមួយបុរស ឬ នារីម្នាក់ទៀត ខណៈចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ពីមុនមិនទាន់រំលាយ។
- អំពើស្មន់៖ ការរួមសេវនកិច្ចជាមួយគ្នារវាង បុរស ឬនារីដែលជាញាតិលោហិត ឬញាតិពន្ធនឹងគ្នា[104]។

ដោយហេតុថា ក្រមព្រហ្មទណ្ឌតម្រូវឲ្យមានការបកស្រាយយ៉ាងតឹងរឹង ឬ មិនអនុញ្ញាតឲ្យចៅក្រមបកស្រាយប្រដូច ឬបកស្រាយលក្ខណៈសទិសន័យ ដូចនេះភាគីនៃអនីតិសង្វាសដែលបានប្រព្រឹត្តិអំពើខាងលើ រួមមានអំពើផិត និងអំពើស្មន់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដោយហេតុថា បទល្មើសទាំងនោះត្រូវផ្ដន្ទាទោសចំពោះតែប្ដីប្រពន្ធ ឬសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ[105]។ ហើយករណីនេះ អាចជាមូលហេតុមួយដែលសហព័ទ្ធ ជាពិសេសបុរសជ្រើសរើសយកចំណងបែបអនីតិសង្វាសដោយហេតុថាខ្លួននឹងមិនត្រូវបានផ្ដន្ទាទោសក្នុងករណីប្រព្រឹត្តបទល្មើសទាក់ទងនឹងអាពាហ៍ពិពាហ៍ទាំងនោះ។

[103] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

[104] ច្បាប់ស្ដីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/0២៦, ២១ តុលា ២០០៦, មាត្រា៥-៦។

[105] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

### ២.២.១២. មូលហេតុនៃការលែងលះ

បើយោងតាមមាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាព និងមាត្រា ៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួននោះទេ ហើយវាមានអានុភាពពេញច្បាប់ លុះត្រាតែបានធ្វើឡើងស្របទៅតាមក្បួនខ្នាតដែលមានចែងនៅក្នុងច្បាប់ប៉ុណ្ណោះ។ ប្តីប្រពន្ធអាចដាក់ពាក្យបណ្តឹងធ្វើការលែងលះបានដោយមូលហេតុនានា ដូចជា៖

- *ភាគីបានប្រព្រឹត្តិអំពើផិតទៅលើសហព័ទ្ធម្ខាងទៀត*
- *ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ*
- *ករណីមិនដឹងច្បាស់ថាសហព័ទ្ធម្ខាងទៀតស្លាប់ ឬរស់អាស់រយៈពេលជាង១ឆ្នាំ*
- *ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំដែលវាផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ពោលគឺការរួមសមគ្គសង្វាសនឹងគ្នា*
- *និងករណីផ្សេងៗទៀតដែលចំណងអាពាហ៍ពិពាហ៍គ្មានសង្ឃឹមថានឹងអាចបដិទាន(សះជា)ឡើងវិញបាន*[106]*។*

ទាំងអស់នេះ គឺជាមូលហេតុនៃការលែងលះរបស់សហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយវាក៏ជាចំណុចខុសគ្នារវាងអាពាហ៍ពិពាហ៍ស្របច្បាប់ និងអនីតិសង្វាសផងដែរ។

ដោយសារតែអនីសង្វាសជាសមគ្គសង្វាសសេរីដែលកើតឡើងដោយឆន្ទៈរបស់បុរស និងនារីម្នាក់ និង គ្មានការចុះបញ្ជីអាពាហ៍ពិពាហ៍នោះទេ។ ជាគោលការណ៍ មូលហេតុនៃការលែងលះមិនត្រូវយកមកបកស្រាយក្នុងករណីអនីតិសង្វាសនោះទេ ដោយហេតុថាបញ្ញត្តិនេះអនុវត្តន៍ចំពោះតែអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ។ ផ្ទុយទៅវិញអនីតិសង្វាសមិនបានគោរពទៅតាមលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ជាហេតុនាំឲ្យសមគ្គសង្វាសបែបនេះមិនត្រូវបានទទួលស្គាល់ដោយច្បាប់ និងមានអានុភាពតាមច្បាប់ដូចនឹងអាពាហ៍ពិពាហ៍នោះទេ។

យ៉ាងណាមិញ មូលហេតុនៃការលែងលះអាចត្រូវបានយកមកធ្វើជាមូលហេតុនៃការផ្តាច់អនីតិសង្វាសផងដែរ ក្នុងករណីមានដែលបណ្តឹងធ្វើឡើងដោយគូភាគីអនីតិសង្វាស។ ចំពោះការបកស្រាយលម្អិតត្រង់ចំណុចនេះ នឹងត្រូវពិភាក្សានៅក្នុងចំណុចបន្តបន្ទាប់នៅ **ជំពូកទី៣ ការរំលាយអនីតិសង្វាស។**

[106] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨។

## ២.៣. ភាពស្រពិចស្រពិលក្នុងការបកស្រាយ

ដូចដែលបានពិភាក្សានៅចំណុចខាងលើ ទោះបីគ្មានវត្តមានបទបញ្ញត្តិគ្រប់គ្រងចំណងបែបអនីតិសង្វាសក៏ដោយ ក៏អានុភាពនៃអនីតិសង្វាសត្រូវបានបកស្រាយប្រដូចនឹងអាពាហ៍ពិពាហ៍ត្រង់ចំណុចមួយចំនួនដូចជាក្នុងករណី៖ *ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នា សេរីភាពនៃការជ្រើសរើសវិជ្ជាជីវៈ សិទ្ធិចូលរួមសកម្មភាពសង្គម បន្ទុកនៃសាហ៊ុយអាពាហ៍ពិពាហ៍ ការគ្រប់គ្រងទ្រព្យសម្បត្តិ (ទ្រព្យរួម ទ្រព្យដោយឡែក និងការបែងចែកទ្រព្យរួម) ការទាមទារសំណងនៃការខូចខាត ការទាមទារសំណងផ្អែកលើអំពើអនីត្យានុកូលជាដើម។* ហើយចំណុចមួយចំនួនទៀតមិនត្រូវបានបកស្រាយដូចនឹងអាពាហ៍ពិពាហ៍នោះទេ ដូចក្នុងករណី៖ *នាមត្រកូលរបស់ប្ដីប្រពន្ធ ការទទួលបាននីតិភាពដោយអាពាហ៍ពិពាហ៍ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ការសន្មត់បិតុភាព សន្តតិកម្ម អាហារកិច្ច ការបែងចែកទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក ការទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌ មូលហេតុនៃការលែងលះជាដើម។*

យ៉ាងណាមិញ ចំពោះចំណងបែបអនីតិសង្វាស អ្នកច្បាប់ហាក់មានការលំបាកបែងចែកត្រង់ចំណុចមួយចំនួន ថាគួរត្រូវបកស្រាយប្រដូចនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ ឬ យ៉ាងណា។ ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ ក្នុងករណីចាំបាច់ តុលាការអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារមួយចំនួនក្រោយទទួលបណ្ដឹងលែងលះ ដូចជា៖

- ការបំបែកលំនៅសង្វាស
- ការគ្រប់គ្រងថែរក្សាកូន
- ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ
- អាហារកាតព្វកិច្ចរវាងសហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍
- និង សោហ៊ុយចិញ្ចឹមបីបាច់កូន ជាដើម[107]។

ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ យើងនឹងធ្វើការសិក្សាបន្ថែមនៅក្នុងដំណើរការនីតិវិធីក្នុងតុលាការ ឬការអនុវត្តជាក់ស្ដែងក្នុងករណីមានបណ្ដឹងរំលាយអនីតិសង្វាស។

[107] អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. អនីតិសង្វាស. កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៣
# ការរំលាយអនីតិសង្វាស

ចំពោះរឿងក្តីអនីតិសង្វាស តុលាការភាគច្រើនធ្វើដោះស្រាយនូវបញ្ហាសំខាន់៣ ដែលភាគីបណ្តឹងអាចធ្វើការទាមទារដើម្បីឲ្យតុលាការសម្រេចតាមការទាមទាររបស់ខ្លួន។ កម្មវត្ថុទាំងនោះរួមមាន ទី១ ការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស ទី២ ការបែងចែកទ្រព្យសម្បត្តិ និងទី៣ ការកំណត់អំណាចមេបា។ ទោះបីអនីតិសង្វាស មិនត្រូវបានទទួលស្គាល់ថាជាសហព័ទ្ធស្របច្បាប់ក៏ដោយ យ៉ាងណាមិញ ពួកគេនៅតែអាចទទួលបានការសម្រេចសេចក្តីដោយតុលាការ នៅពេលដែលបណ្តឹងទាក់ទងនឹងការរំលាយអនីតិសង្វាសរបស់ពួកគេ ត្រូវបានបញ្ជូនទៅតុលាការ។ ក៏ប៉ុន្តែមិនមានន័យថារាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអនីតិសង្វាស ឬ ធ្វើឡើងដោយអនីតិសង្វាស សុទ្ធតែត្រូវបានទទួលយកចាត់ការ ឬទទួលបានការជំនុំជំរះនោះទេ។ ត្រង់ចំណុចនេះ យើងនឹងធ្វើការសិក្សាពីការជំនុំជំរះបណ្តឹងស្តីពីអនីតិសង្វាសនៅក្នុងតុលាការកម្ពុជាមួយចំនួន។

## ៣.១. ការរំលាយអនីតិសង្វាសក្រៅប្រព័ន្ធតុលាការ

ទោះបីជាការដោះស្រាយតាមប្រព័ន្ធតុលាការ គឺជាវិធីមួយដែលអាចដោះស្រាយវិវាទរបស់គូភាគីឲ្យដាច់ស្រេចតាមផ្លូវច្បាប់យ៉ាងណាក៏ដោយ ក៏ការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការហាក់ទទួលបានការពេញនិយមពីភាគីជំលោះ ដោយហេតុថា វិធីសាស្ត្រនេះចំណាយពេលវេលា និង ថវិកាសមស្រប ឬ តិចជាង ហើយពុំសូវមានភាពស្មុគស្មាញ ប្រសិនបើប្រៀបធៀបជាមួយការដោះស្រាយតាមផ្លូវតុលាការ[108]។

ជាក់ស្តែងនៅប្រទេសកម្ពុជា ដើម្បីជំរុញឲ្យមានដំណើរការប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ លិខិតគតិយុត្តជាច្រើនត្រូវបានអនុម័តជាហូរហែរ។ ជាក់ស្តែង ឃុំសង្កាត់បានបង្កើតឲ្យមាននូវគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដើម្បីផ្សះផ្សារវិវាទ ដែលក្នុងនោះការលែងលះ គឺជាសំនុំរឿងដែលគណៈកម្មាធិការតែងទទួលបានពីគូភាគីដើម្បីដោះស្រាយ[109]។

ជាការពិតណាស់ ការលែងលះក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រដ៏ពេញនិយមមួយដែលប្តីប្រពន្ធក្នុងប្រទេសកម្ពុជា ទាំងប្តីប្រពន្ធដែលមានសំបុត្រអាពាហ៍ពិពាហ៍ និងប្តីប្រពន្ធអនីតិសង្វាសជ្រើសរើសក្នុងការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ឬចំណងអនីតិសង្វាសរបស់ពួកគេ ទោះបីដឹងថា

[108] ស៊ូ សោភា និង ទិត្យ ស៊ីដែត. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ* (ភ្នំពេញ៖ វិទ្យាស្ថានសភាកម្ពុជា,២០១៥), ៩។

[109] ស៊ូ សោភា និង ទិត្យ ស៊ីដែត. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ* (ភ្នំពេញ៖ វិទ្យាស្ថានសភាកម្ពុជា,២០១៥), ១២។

មានតែតុលាការទេដែលអាចសម្រេចការលែងលះដល់គូភាគីតាមផ្លូវច្បាប់ជាស្ថាពរ។ យោងតាមកថាខណ្ឌទី២ មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅដ្ឋាន ឬទីលំនៅរបស់គូភាគី (ក្នុងមាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដែលក្នុងករណីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលភាគីឲ្យសះជាគ្នាវិញក្នុងកំឡុងពេល១៥ថ្ងៃបន្ទាប់ពីបានទទួលពាក្យបណ្ដឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនបណ្ដឹងនោះទៅតុលាការជាបន្ទាន់ ប្រសិនជាមិនអាចបញ្ចុះបញ្ចូលភាគីឲ្យសះជាគ្នាបាន។ ត្រង់មាត្រានេះ យើងសង្កេតឃើញថា ឃុំសង្កាត់បានដើរតួនាទីសំខាន់ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជាពិសេសក្នុងរឿងលែងលះនេះឯង។ យ៉ាងណាមិញ ឃុំសង្កាត់អាចត្រឹមតែធ្វើការផ្សះផ្សាដល់ភាគីតែប៉ុណ្ណោះ ហើយឃុំសង្កាត់ក៏មិនមានសិទ្ធអំណាចណាមួយ ក្នុងការសម្រេចឲ្យប្ដីប្រពន្ធដែលមានសំបុត្រអាពាហ៍ពិពាហ៍លែងលះគ្នានោះទេ ពីព្រោះសិទ្ធិនេះត្រូវបានប្រគល់ឲ្យដល់តុលាការមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ។

ជាក់ស្ដែង ដោយយោងតាមរបាយការណ៍មួយចេញដោយមន្ត្រីក្រសួងយុត្តិធម៌ និងបណ្ឌិតសភាវិជ្ជាជីវៈតុលាការកាលពីឆ្នាំ២០១៤ បានបង្ហាញតួលេខឲ្យដឹងថា ការសម្របសម្រួលក្រៅប្រព័ន្ធតុលាការសម្រាប់ប្ដីប្រពន្ធដែលមានវិវាទមានចំនួនសរុប ៧,០០៦ ករណី។ ក្នុងនោះ ការសម្របសម្រួលក្រៅតុលាការបានសម្រេចលែងលះចំនួន ៤,៤៤៥ ករណី។ ហើយការលែងលះចំនួន ៤,៤៤៥ ករណីដែលបានបង្ហាញខាងលើ គឺជាការលែងលះស្ម័គ្រចិត្តក្រៅប្រព័ន្ធតុលាការពីប្ដីប្រពន្ធដែលគ្មានលិខិតអាពាហ៍ពិពាហ៍ ពោលគឺជាការបញ្ចប់ចំណងអនីតិសង្វាសនេះឯង[110]។ នេះបញ្ជាក់ឲ្យឃើញថា ឃុំសង្កាត់ គឺជាយន្តការដ៏ចម្បងមួយ ដែលប្ដីប្រពន្ធអនីតិសង្វាសជ្រើសយកក្នុងការបញ្ចប់ចំណងប្ដីប្រពន្ធក្រៅផ្លូវច្បាប់របស់ពួកគេ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ចប់ចំណងអនីតិសង្វាសដល់ប្រជាពលរដ្ឋ។

លើសពីនេះទៅទៀត ការលែងលះនៅឃុំសង្កាត់ នៅតែជាមធ្យោបាយដ៏ពេញនិយមដែលប្ដីប្រពន្ធអនីតិសង្វាសប្រើប្រាស់ក្នុងការបញ្ចប់ទំនាក់ទំនងបែបអនីតិសង្វាសរបស់ពួកគេ។ ជាក់ស្ដែងទោះបីជានីតិវិធីក្នុងការបញ្ចប់អនីតិសង្វាសនៅឃុំសង្កាត់ ត្រូវបានយល់ជាទូទៅក្នុងភាសាសាមញ្ញថា ជាការលែងលះគ្នាក៏ពិតមែន ក៏ប៉ុន្តែការបញ្ចប់ការរស់នៅបែបអនីតិសង្វាសនេះត្រូវបានធ្វើឡើងក្រោមរូបភាពជាកិច្ចសន្យាឯកជន ដែលតម្រូវឲ្យភាគីជាប្ដីប្រពន្ធនៃអនីតិសង្វាស ធ្វើការផ្ដិតមេដៃ

110 Sara, "លែងលះប្ដីប្រពន្ធក្នុងសេវាសម្របសម្រួលក្រៅតុលាការវិវាទរួម៧០០៦ករណី សម្រេចលែងលះចំនួន៤៤៤៥ករណី", *កោះសន្តិភាព*, ៣០ ធ្នូ ២០១៦ https://kohsantepheapdaily.com.kh/article/111984.html?fbclid=IwAR11FK__ug8qG9kJr_uh8XROc0X4s-sg0HJLonDfxkbgozFvEo3sQL-GKg8 (បានចូលមើលចុងក្រោយ ១៣ មិថុនា ឆ្នាំ២០១៩)

សន្យាអំពីការបញ្ចប់ការរួមរស់ ឬគ្មានចំណងជាប្តីប្រពន្ធជាមួយគ្នាតទៅទៀតប៉ុណ្ណោះ[111] ព្រោះថាការលែងលះជាផ្លូវការ ឬស្របច្បាប់អាចធ្វើឡើងដោយតុលាការមានសមត្ថកិច្ចប៉ុណ្ណោះ។

**៣.១.១. ការបែងចែកទ្រព្យសម្បត្តិ**

ជាទូទៅ ចំពោះការបញ្ចប់អនីតិសង្វាស ក្នុងករណីដែលពួកគេមានទ្រព្យសម្បត្តិដែលត្រូវបែងចែកនោះ ឃុំសង្កាត់អាចត្រឹមចូលរួមក្នុងការសម្របសម្រួល ឬចរចារជាមួយភាគី រួចបង្គាប់ឲ្យភាគីធ្វើកិច្ចសន្យាប៉ុណ្ណោះ[112]។ ប្រសិនបើការចរចារមិនទទួលបានជោគជ័យ ឬភាគីនៃអនីតិសង្វាសនៅតែមិនព្រមព្រៀងគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិនោះទេ យន្តការបន្ទាប់ គឺមានតែធ្វើការប្តឹងផ្តល់បន្តទៅតុលាការប៉ុណ្ណោះ។ ទោះបីជាចំណងអនីតិសង្វាស មិនត្រូវទទួលស្គាល់ដោយច្បាប់ក៏ពិតមែន ក៏ប៉ុន្តែការបែងចែកទ្រព្យសម្បត្តិចំពោះអនីតិសង្វាសនៅតែទទួលបានការសម្រេចសេចក្តីដោយតុលាការកម្ពុជា ដែលនឹងត្រូវរៀបរាប់នៅចំណុចបន្តបន្ទាប់។

**៣.១.២. ការកំណត់អំណាចមេបា**

ដូចគ្នានឹងការបែងចែកទ្រព្យក្រៅប្រព័ន្ធតុលាការនេះដែរ ចំពោះការបញ្ចប់អនីតិសង្វាស ក្នុងករណីដែលពួកគេមានកូនដែលត្រូវទាមទារសិទ្ធិចិញ្ចឹមបីបាច់ ឬ ទាមទារអំណាចមេបានោះ ឃុំសង្កាត់អាចត្រឹមចូលរួមក្នុងការសម្របសម្រួល ឬចរចារជាមួយភាគី រួចបង្គាប់ឲ្យភាគីធ្វើកិច្ចសន្យាប៉ុណ្ណោះ[113]។ ប្រសិនបើការចរចារមិនទទួលបានជោគជ័យ ឬ ភាគីនៃអនីតិសង្វាសនៅតែមិនព្រមព្រៀងគ្នាក្នុងការប្រគល់អំណាចមេបាទៅលើកូនដល់ភាគីម្ខាងទៀតនៃចំណងអនីតិសង្វាសនោះទេ យន្តការបន្ទាប់គឺមានតែធ្វើការប្តឹងបន្តទៅតុលាការប៉ុណ្ណោះ។

## ៣.២. ការរំលាយអនីតិសង្វាសក្នុងប្រព័ន្ធតុលាការ

### ៣.២.១ មូលដ្ឋានគតិយុត្តសម្រាប់ការវិនិច្ឆ័យសេចក្តី

#### ៣.២.១.១ ការបញ្ចប់ការរួមរស់ជាអនីតិសង្វាស

**ក. ករណីមានបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍**

❖ **មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ**

យោងទៅតាមក្រមរដ្ឋប្បវេណី ចំពោះបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍

---

[111] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ. *បើគ្មានការផ្តន្ទាទោស គឺគ្មានការការពារ៖ ការឆ្លើយតបអំពើហឹង្សាក្នុងគ្រួសារនៅកម្ពុជា* (ភ្នំពេញ, ២០១៧), ១៨។

[112] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ. *បើគ្មានការផ្តន្ទាទោស គឺគ្មានការការពារ៖ ការឆ្លើយតបអំពើហឹង្សាក្នុងគ្រួសារនៅកម្ពុជា* (ភ្នំពេញ, ២០១៧), ១៨។

[113] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ. *បើគ្មានការផ្តន្ទាទោស គឺគ្មានការការពារ៖ ការឆ្លើយតបអំពើហឹង្សាក្នុងគ្រួសារនៅកម្ពុជា* (ភ្នំពេញ, ២០១៧), ១៨។

តុលាការផ្អែកលើមូលហេតុ២ គឺទី១គូភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ការភាន់ច្រឡំលើមនុស្ស ការចាប់បង្ខំ និងមូលហេតុផ្សេងៗទៀត[114]។ ចំពោះមូលហេតុផ្សេងទៀត អាពាពិពាហ៍អាចត្រូវមោឃភាពក្នុងករណីដែលមិនបានបំពេញលក្ខខណ្ឌទម្រង់ ដូចជាការដាក់ពាក្យសុំអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះបញ្ជីអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលជាដើម។ ដូចនេះ អាពាហ៍ពិពាហ៍នឹងត្រូវប្រកាសមោឃភាពដោយតុលាការតាមបណ្តឹងទាមទាររបស់សហព័ទ្ធ ក្នុងករណីអាពាហ៍ពិពាហ៍បានកើតឡើងដោយមូលហេតុទាំងនេះ។

ចំពោះការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស បណ្តឹងរបស់ភាគីទៅកាន់តុលាការទាមទារបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ជាគោលការណ៍ច្បាប់ គឺ មិនអាចត្រូវបានដោះស្រាយដោយអំណាចសាលក្រមរបស់តុលាការនោះទេ ដោយហេតុថា បណ្តឹងបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍អាចធ្វើឡើងចំពោះតែអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ ពោលគឺលុះត្រាតែមានសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) និង មានមូលហេតុសមស្របដូចដែលបានកំណត់ក្នុងច្បាប់។

ដូចនេះចំណងអនីតិសង្វាសមិនបានបំពេញលក្ខខណ្ឌចុះសំបុត្រអាពាហ៍ពិពាហ៍នេះទេ។ ជាគោលការណ៍ ការបំបែកអនីតិសង្វាសដោយឈរលើមោឃភាពនៃអាពាហ៍ពិពាហ៍ គឺមិនអាចធ្វើទៅបាននោះទេ[115]។

❖ **ការសម្រេចសេចក្តី**

ដូចដែលបានពិភាក្សា បកស្រាយនៅចំណុចខាងលើ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍អាចធ្វើទៅបានលុះត្រាណាតែមានមូលហេតុត្រឹមត្រូវដែលកំណត់ដោយច្បាប់ ដោយអនុលោមតាមមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា។

ដោយឡែក ក្នុងករណីអនីតិសង្វាស ចំណងមួយនេះមិនត្រូវបានទទួលស្គាល់ដោយច្បាប់នោះទេ ដោយហេតុថាគ្មានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។ ហេតុដូចនេះ អនុលោមតាមមាត្រា ៧៤ និង មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងលើកបណ្តឹងប្រភេទនេះចោលដោយមូលហេតុថាបណ្តឹងប្រភេទនេះគ្មានផលប្រយោជន៍បណ្តឹង ពោលបណ្តឹងប្រភេទនេះមិនមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និងមិនអាចដោះស្រាយបានតាមសាលក្រមបាន ឬ មិនអាចកែតម្រូវបាន[116]។

[114] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៨។

[115] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៥។

[116] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១១។

### ខ. ករណីមានបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍

#### ❖ មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ

អាពាហ៍ពិពាហ៍អាចត្រូវបានលុបចោលដោយសារមិនគោរពតាមច្បាប់ដែលកំណត់ ដូចជាលក្ខខណ្ឌអាយុ ការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានហាមឃាត់មិនឲ្យមានទ្វេរពន្ធភាព ការរៀបអាពាហ៍ពិពាហ៍ក្នុងកំឡុងពេលហាមឃាត់ ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធ និងការរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគំរាមជាដើម[117]។

មិនខុសគ្នាពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍នោះទេ គូភាគីនៃអនីតិសង្វាសមិនអាចធ្វើបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ទៅតុលាការបានទេ ដោយហេតុថា អនីតិសង្វាសគ្មានទេអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ដូចសហព័ទ្ធស្របច្បាប់នោះទេ។ ម្យ៉ាងទៀត អនីតិសង្វាសអាចត្រូវបានបង្កើតឡើងដោយមិនមានការគោរពលក្ខខណ្ឌ និងការហាមឃាត់នានា ស្របទៅតាមមាត្រា ៩៤៨ ដល់ មាត្រា ៩៥២ ដូចអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ដូចនេះ ជាគោលការណ៍ច្បាប់ ចំណងអនីតិសង្វាសមិនអាចរំលាយដោយឈរលើហេតុផលលុបចោលអាពាហ៍ពិពាហ៍ តាមរយៈការលែងលះបានទេ ដោយហេតុថាចំណងអនីតិសង្វាសមិនបានបំពេញលក្ខខណ្ឌច្បាប់ និង គោរពការហាមឃាត់នានាចំពោះអាពាហ៍ពិពាហ៍ ដូចដែលបានបញ្ញត្តិក្នុងច្បាប់នោះទេ[118]។

#### ❖ ការសម្រេចសេចក្តី

ដូចដែលបានរៀបរាប់ខាងលើ បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ អាចធ្វើឡើងទៅបានលុះត្រាតែអាពាហ៍ពិពាហ៍នោះ ត្រូវបានធ្វើឡើងដោយមិនគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬ មិនបានបំពានការហាមឃាត់ដែលច្បាប់បានចែង ឬ បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍អាចធ្វើឡើងដោយសហព័ទ្ធស្របច្បាប់តែប៉ុណ្ណោះ។ ពោល គឺ មានតែប្តីប្រពន្ធដែលមានសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលប៉ុណ្ណោះ ទើបអាចប្តឹងលែងលះនៅតុលាការបាន។

ដូចនេះ នៅក្នុងករណីដែលអនីតិសង្វាសដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ នោះបណ្តឹងប្រភេទនេះនឹងត្រូវលើកចោលដោយសាលក្រមតុលាការ។ អនុលោមតាមមាត្រា ៧៤ និងមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដដែល តុលាការនឹងលើកបណ្តឹងប្រភេទនេះចោលដោយមូលហេតុថាបណ្តឹងប្រភេទនេះគ្មានផលប្រយោជន៍បណ្តឹង ពោលបណ្តឹងប្រភេទនេះមិនមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង មិនអាចដោះស្រាយដោយតាមសាលក្រមបានទេ ឬ

[117] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨-៩៥២។

[118] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៦។

បណ្តឹងប្រភេទនេះមិនអាចធ្វើការកែតម្រូវបាន[119]។

### គ. ករណីមានបណ្តឹងទាមទារឲ្យលែងលះ

#### ❖ មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ

បើអនុលោមតាមក្រមរដ្ឋប្បវេណី ប្តីប្រពន្ធអាចដាក់ពាក្យបណ្តឹងធ្វើការលែងលះបានដោយមូលហេតុមួយចំនួនដូចជា៖ ភាគីបានប្រព្រឹត្តិអំពើផិតទៅលើសហព័ទ្ធម្ខាងទៀត ការបោះបង់ចោលសហព័ទ្ធម្ខាងទៀតដោយគ្មានមូលហេតុត្រឹមត្រូវ ករណីមិនដឹងច្បាស់ថាសហព័ទ្ធម្ខាងទៀតស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង១ឆ្នាំ ដែលវាផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ពោលគឺការរួមសមគ្គសង្វាសនឹងគ្នា និងករណីផ្សេងៗទៀត ដែលចំណងអាពាហ៍ពិពាហ៍គ្មានសង្ឃឹមថានឹងអាចបដិទាន (សះជា) ឡើងវិញបានជាដើម[120] ។ ប្រសិនបើមានការព្រមព្រៀងគ្នានោះ ភាគីអាចធ្វើពាក្យបណ្តឹងលែងលះទៅតុលាការបាន[121]។ លើសពីនេះទៅទៀត ក្រោយពេលទទួលពាក្យបណ្តឹងលែងលះ តុលាការអាចចេញដីការសម្រេចចាត់ចែងរក្សាការពារនានា ដូចជា ការបំបែកលំនៅសង្វាស ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ ការទទួលខុសត្រូវអាហារកិច្ចរវាងសហព័ទ្ធ បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ សោហ៊ុយចិញ្ចឹមបីបាច់កូនជាដើម តាមរយៈពាក្យសុំរបស់ភាគី ឬដោយឆន្ទានុសិទ្ធិរបស់តុលាការបាន។

ជាគោលការណ៍ច្បាប់ បណ្តឹងលែងលះអាចធ្វើឡើងដោយសហព័ទ្ធស្របច្បាប់ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬ មានអេតាស៊ីវិលប៉ុណ្ណោះ។ ដូចនេះ អនីតិសង្វាសមិនអាចដាក់ពាក្យបណ្តឹងទៅតុលាការក្នុងកម្មវត្ថុទាមទារឲ្យលែងលះបាននោះទេ ពោលគឺមិនអាចដោះស្រាយដោយអំណាចសាលក្រមរបស់តុលាការបាននោះទេ[122]។

#### ❖ ការសម្រេចសេចក្តី

ដូចដែលបានរៀបរាប់នៅចំណុចខាងលើ បណ្តឹងទាមទារឲ្យលែងលះអាចធ្វើឡើងដោយសហព័ទ្ធដែលបានមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់តែប៉ុណ្ណោះ។ ដូចនេះ អនីតិសង្វាស មិនអាចធ្វើការលែងលះដូចសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ព្រោះអនីតិសង្វាសមិនត្រូវបានទទួលស្គាល់ដោយច្បាប់ ឬគ្មានបញ្ញត្តិច្បាប់ដែលចែងអំពីការលែងលះរបស់អនីតិសង្វាសនោះទេ។ ដោយអនុលោមតាមមាត្រា ៧៤ និងមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

---

[119] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១២។

[120] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨។

[121] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

[122] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៧។

តុលាការនឹងលើកបណ្ដឹងប្រភេទនេះចោល ដោយហេតុថាបណ្ដឹងប្រភេទនេះគ្មានផលប្រយោជន៍បណ្ដឹង។ ពោលបណ្ដឹងប្រភេទនេះមិនមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និង មិនអាចដោះស្រាយបានតាមសាលក្រមបាន ឬបណ្ដឹងប្រភេទនេះមិនអាចធ្វើការកែតម្រូវបាន[123]។

### ឃ. ករណីមានបណ្ដឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍

#### ❖ មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ

អនុលោមតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល បានកំណត់បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដូចជាបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍តាមមាត្រា ៩៥៨ បណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍តាមមាត្រា ៩៥៩ ដល់ មាត្រា ៩៦៣ បណ្ដឹងទាមទារឲ្យលែងលះតាមមាត្រា ៩៧៨ និងបណ្ដឹងផ្សេងៗទៀតដែលមានបំណងបង្កើត បញ្ជាក់អត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គលជាដើម[124]។ បណ្ដឹងប្រភេទនេះអាចធ្វើឡើងបាន លុះត្រាតែមានច្បាប់ចែងអំពីទំនាក់ទំនងឋានៈបុគ្គលដែលមានក្នុងបណ្ដឹងទាមទារនោះ។ ម្យ៉ាងទៀត នត្ថិភាព និង អត្ថិភាពនៃអាពាហ៍ពិពាហ៍ គឺមិនមានកំណត់ក្នុងច្បាប់នេះទេ។ រីឯបណ្ដឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ធ្វើឡើងដោយអនីតិសង្វាសជន រឹតតែមិនអាចទៅរួច ឬ មិនអាចត្រូវបានដោះស្រាយដោយអំណាចតុលាការនោះទេ[125]។

#### ❖ ការសម្រេចសេចក្ដី

ដោយសារតែអនីតិសង្វាសមិនមានអត្ថិភាពនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានបណ្ដឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ នោះតុលាការនឹងច្រានចោលការទាមទាររបស់ភាគីដោយអនុលោមតាមតាមមាត្រា ៧៤ និង មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដដែលដោយមូលហេតុថាបណ្ដឹងប្រភេទនេះគ្មានផលប្រយោជន៍ ម្យ៉ាងបណ្ដឹងប្រភេទនេះមិនមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងមិនអាចដោះស្រាយបានតាមសាលក្រមបាន ឬបណ្ដឹងប្រភេទនេះមិនអាចធ្វើការកែតម្រូវបាន[126]។

### ង. ករណីមានបណ្ដឹងទាមទារឲ្យបំបែកអនីតិសង្វាស

#### ❖ មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ

ដូចដែលបានពិភាក្សាពីខាងដើម អនីតិសង្វាសមិនត្រូវបានឲ្យនិយមន័យដោយច្បាប់កម្ពុជានោះទេ ឬ ក៏គ្មានវិធានគតិយុត្តណាមួយត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងចំណងអនីតិសង្វាស

[123] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១២។

[124] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៣។

[125] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៧-៨។

[126] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១២។

ផងដែរ ហើយការទាមទារឲ្យបំបែកអនីតិសង្វាសក៏គ្មានចែងក្នុងច្បាប់កម្ពុជាដូចគ្នាដែរ។ ម្យ៉ាងទៀត ចំពោះពាក្យថា *ការបំបែកលំនៅ* ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី[127] គឺធ្វើឡើងនៅពេលដែលតុលាការទទួលបណ្ដឹងលែងលះរបស់ភាគី ដែលជាសហព័ទ្ធស្របច្បាប់ប៉ុណ្ណោះ ហើយមានតែសហព័ទ្ធស្របច្បាប់ (មានសំបុត្រអាពាហ៍ពិពាហ៍) ប៉ុណ្ណោះ ទើបអាចធ្វើការលែងលះបាន។ ពាក្យបំបែកលំនៅសង្វាស មិនមែនជាការបំបែកអនីតិសង្វាសនោះទេ តែគឺជាការចាត់ចែងរក្សាការពារដែលមានអានុភាពបណ្ដោះអាសន្ន ដើម្បីរង់ចាំដំណើរការរឿងក្ដីបន្តនៅតុលាការសម្រាប់បណ្ដឹងលែងលះរបស់សហព័ទ្ធស្របច្បាប់ប៉ុណ្ណោះ។

ដូចនេះការទាមទារឲ្យបំបែកអនីតិសង្វាស មិនស្ថិតក្នុងវិវាទតាមផ្លូវច្បាប់នោះទេ ហើយក៏មិនអាចត្រូវបានដោះស្រាយដោយសាលក្រមរបស់តុលាការបានដែរ[128]។

❖ **ការសម្រេចសេចក្ដី**

ទោះបីក្រមរដ្ឋប្បវេណីកម្ពុជាបានចែងពីការបំបែកលំនៅសង្វាសក៏ដោយ ក៏ពាក្យ បំបែកលំនៅសង្វាសនៅទីនេះ មិនមែនជាការបំបែកអនីតិសង្វាសនោះទេ ឬជាគោលការណ៍ មិនអនុវត្តចំពោះការបំបែកលំនៅសង្វាសរបស់អនីតិសង្វាសនោះទេនោះទេ តែគឺជាការចាត់ចែងរក្សាការពារដែលមានអានុភាពបណ្ដោះអាសន្ន រង់ចាំដំណើរការរឿងក្ដីបន្តនៅតុលាការសម្រាប់បណ្ដឹងលែងលះរបស់សហព័ទ្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ប៉ុណ្ណោះ[129]។ ហើយតុលាការនឹងចេញសាលក្រមសម្រេចលើកចោលបណ្ដឹងនៃការទាមទារនេះ ដោយមូលហេតុថាបណ្ដឹងគ្មានផលប្រយោជន៍ គ្មានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្ដែងដោយមិនអាចដោះស្រាយដោយសាលក្រមបាន ឬមិនអាចធ្វើការកែតម្រូវឡើងវិញបាន[130, 131]។

### ៣.២.១.២ ការបែងចែកទ្រព្យសម្បត្តិ

#### ក. ករណីមានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ

❖ **មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ**

ជាក់ស្ដែង រឿងសំខាន់ដែលភាគីតែងតែទាមទារនៅពេលផ្ដាច់ចំណងអាពាហ៍ពិពាហ៍ ឬលែងលះនោះគឺការបែងចែកទ្រព្យសម្បត្តិ។ ចំពោះសហព័ទ្ធស្របច្បាប់ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវបានបែងចែកជាពីរប្រភេទ គឺប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាម

[127] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៣។
[128] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៨។
[129] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៣។
[130] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥។
[131] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា81។

កិច្ចសន្យា នេះបើយោងតាមក្រមរដ្ឋប្បវេណីកម្ពុជា[132]។ នៅពេលលែងលះ ចំពោះការបែងចែកទ្រព្យសម្បត្តិ តុលាការនឹងពិនិត្យមើលថា តើសហព័ទ្ធបានជ្រើសរើសនូវប្រព័ន្ធមួយណា ដើម្បីមកធ្វើការសម្រេចក្តី។

ដូចដែលបានសិក្សាពីខាងដើម ប្តីប្រពន្ធអាចកំណត់ពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេមុន ឬក្រោយការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ។ ប្រសិនបើមិនបានចុះកិច្ចសន្យាទ្រព្យសម្បត្តិនោះទេ មានន័យថាទំនាក់ទំនងទ្រព្យសម្បត្តិរបស់ពួកគេ ស្ថិតក្នុងប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់[133]។ បើសិនជាសហព័ទ្ធទាំងសងខាងចង់បានប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ពួកគេត្រូវធ្វើការចុះបញ្ជីកិច្ចសន្យាដោយឡែកនោះ[134] ជាលាយលក្ខណ៍អក្សរ និងស្របទៅតាមទម្រង់ និងនីតិវិធីដែលកំណត់ដោយច្បាប់[135]។ នៅពេលលែងលះ ការបែងចែកទ្រព្យសម្បត្តិត្រូវបានតុលាការវិនិច្ឆ័យដោយពិនិត្យទៅលើឆន្ទៈរបស់ភាគីថាតើមានការព្រមព្រៀងក្នុងការបែងចែកដែរឬទេ។ ប្រសិនបើភាគីមានការព្រមព្រៀងក្នុងការបែងចែកទ្រព្យសម្បត្តិដោយខ្លួនឯង តុលាការនឹងមិនលូកដៃក្នុងការបែងចែកទ្រព្យសម្បត្តិនោះទេ ដោយឡែកប្រសិនបើមានទំនាស់ក្នុងការបែងចែក ឬការពិភាក្សាគ្នាមិនបានសម្រេចនោះទេ តុលាការនឹងធ្វើការបែងចែងទ្រព្យសម្បត្តិរបស់ពួកគេដោយយុត្តិធម៌ ស្របទៅតាមគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែកដែលមានកំណត់ក្នុងច្បាប់។

ក្នុងការបែងចែកទ្រព្យសម្បត្តិ ទស្សនៈមួយយល់ថា គប្បីធ្វើការបែងចែកទ្រព្យសម្បត្តិតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ ជាគោលការណ៍ វាអនុវត្តចំពោះប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ប៉ុណ្ណោះទេ ទើបទ្រព្យរួមកើតមានឡើង ព្រោះតាមនិយមន័យទ្រព្យរួមគឺជាទ្រព្យដែលសហព័ទ្ធទាំងសងខាង ឬ ម្ខាងរកបាន ឬ ទទួលបានក្នុងកំឡុងពេលពួកគេកំពុងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា លើកលែងករណីមួយចំនួនដូចកំណត់ក្នុងច្បាប់[136]។ រីឯទស្សនៈមួយចំនួនទៀតបានលើកឡើងថា ការបញ្ញត្តិស្តីពីទ្រព្យរួមរបស់ប្តីប្រពន្ធក្នុងក្រមរដ្ឋប្បវេណីធ្វើឡើងក្នុងគោលបំណងដោះស្រាយវិវាទទាក់ទិននឹងទំនាក់ទំនងប្តីប្រពន្ធស្របច្បាប់ និងការពារករណីមានការគំរាមកំហែងពីភាគីម្ខាងទៅលើភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍។ ទោះបីជាចំណង

[132] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។
[133] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។
[134] នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទព្យសម្បត្តិប្តីប្រពន្ធ, លេខ កយ.ប្រក/១៣, ០៩ សីហា ២០១៣។
[135] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។
[136] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

អនីតិសង្វាសក៏ដោយ ក៏ត្រូវទទួលស្គាល់គោលការណ៍ទ្រព្យរួមផងដែរ ប្រសិនបើទ្រព្យទាំងអស់នោះ កើតមាន ឬទទួលបានក្រោយមានជីវភាពរួមគ្នាបែបអនីតិសង្វាសផងដែរ[137]។

បើតាមមតិមួយទៀត ទំនាក់ទំនងទ្រព្យសម្បត្តិនៃអនីតិសង្វាសមិនស្ថិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនោះទេ ដោយហេតុថាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធអនុវត្តន៍ចំពោះតែសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ។ ដូចនេះ មានន័យថាទ្រព្យសម្បត្តិនៃអនីតិសង្វាសគឺស្ថិតនៅក្រោមរបបគតិយុត្តនៃកម្មសិទ្ធអវិភាគ[138]។ បើយោងតាមទស្សនៈនេះ ការបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធអនីតិសង្វាសគួរតែផ្អែកលើបញ្ញតិស្តីពីកម្មសិទ្ធអវិភាគ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីពីមាត្រា២០២ ដល់មាត្រា២១៤ ដូចមានកំណត់ក្នុងច្បាប់។

យ៉ាងណាមិញ ចំពោះការអនុវត្តជាក់ស្តែងស្តីពីការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាសក្រោយការរំលាយ ឬបញ្ឈប់ការរួមរស់ជាអនីតិសង្វាសនឹងត្រូវរៀបរាប់នៅចំណុចខាងក្រោយ។

❖ **ការសម្រេចសេចក្តី**

នៅពេលដែលមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យសម្បត្តិ តុលាការនឹងធ្វើការសម្រេចដោយផ្អែកតាមប្រភេទទ្រព្យដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។ ចំពោះការបែងចែកទ្រព្យ សហព័ទ្ធនីមួយៗនឹងទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ពួកគេ ដូចដែលមានកំណត់ក្នុងមាត្រា ៩៧២ នៃក្រមដដែល។ បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកនេះ សហព័ទ្ធទាំងសងខាងមានសិទ្ធិម្នាក់ពាក់កណ្តាល ឬ១ភាគ២ ទៅលើទ្រព្យរួមរបស់ពួកគេ។ ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ភាគីណាម្ខាង តុលាការអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគក្នុងទ្រព្យរួម ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនោះ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងអំឡុងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត ផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម។ ចំណែកឯ ការងារផ្ទះ ឬ គេហកិច្ចរបស់សហព័ទ្ធម្ខាង ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះផងដែរ[139]។

ដើម្បីអាចធ្វើការសម្រេចទៅបានដូចរៀបរាប់ខាងលើ តុលាការត្រូវពិនិត្យលើអង្គហេតុ និងភស្តុតាងតាមការអះអាងរបស់ភាគីនីមួយៗដើម្បីធ្វើការវិនិច្ឆ័យ។ មុននឹងឈានដល់ការកំណត់អំពីការបែងចែកចំណែកនៃទ្រព្យសម្បត្តិដល់ភាគីនីមួយៗ តុលាការនឹងធ្វើការកំណត់នូវមូលដ្ឋាននានា

[137] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ៨-១០។

[138] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៣៩។

[139] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០។

ក្នុងការបែងចែកទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកជាមុនសិន[140]។

**ខ. មូលដ្ឋានគតិយុត្តដើម្បីវិនិច្ឆ័យករណីគ្មានបណ្ដឹងទាមទារឲ្យបែងចែកទ្រព្យ**

❖ **មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ**

បើអនុលោមតាមមាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវតែចេញសាលក្រម ចំពោះការទាមទារទាំងអស់ដែលធ្វើឡើងដោយភាគីដែលបានសុំ។ ដូចនេះតុលាការមិនអាចចេញសាលក្រម ចំពោះចំណុចណាដែលគ្មានការទាមទារដោយភាគីនោះទេ។ ម្យ៉ាងទៀត បើផ្អែកតាមច្បាប់នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល លើកលែងតែតុលាការចេញសាលក្រម ឬសាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះបណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ឬ បណ្ដឹងលែងលះប៉ុណ្ណោះ ទើបតុលាការធ្វើការសម្រេចសេចក្ដីកំណត់ពីអ្នកដែលមានអំណាចមេបាដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ហើយប្រសិនបើមានពាក្យសុំរបស់ភាគីណាម្ខាង តុលាការត្រូវធ្វើការសម្រេចសេចក្ដីទាក់ទិននឹងការចាត់ចែងបីបាច់ថែរក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។

ក្នុងករណីខាងលើនេះ វាហាក់មិនអាចកើតឡើងបានឡើយក្នុងសំនុំរឿងអនីតិសង្វាស[141]។

❖ **ការសម្រេចសេចក្ដី**

ក្នុងករណីគ្មានបណ្ដឹងសុំទាមទារឲ្យបែងចែកទ្រព្យសម្បត្តិនោះទេ តុលាការនឹងមិនធ្វើការសម្រេចលើបញ្ហាដែលមិនបានស្នើទាមទារនោះទេ។ ដូចមានចែងក្នុងច្បាប់ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាមួយដែលភាគីមិនបានសុំ ឬ ទាមទារនោះឡើយ ហើយច្បាប់បានកំណត់ថាតុលាការត្រូវចេញសាលក្រមចំពោះតែការទាមទារទាំងឡាយដែលធ្វើឡើងដោយភាគីតែប៉ុណ្ណោះ។[142]

### ៣.២.៣ មូលដ្ឋានគតិយុត្តកំណត់អ្នកមានអំណាចមេបា

**ក. ករណីមានបណ្ដឹងទាមទារអ្នកមានអំណាចមេបា**

❖ **មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ**

ចំពោះការទាមទារកំណត់អ្នកមានអំណាចមេបាលើកូនក្នុងរឿងក្ដីអនីតិសង្វាស មានភាពខុសប្លែកគ្នាពីបណ្ដឹងទាមទារឲ្យបញ្ឈប់ការរួមរស់ជាអនីតិសង្វាស និង ការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេ ដោយហេតុថា ការទាមទារអំណាចមេបាទៅលើកូនចំពោះទំនាក់ទំនងអនីតិសង្វាស

[140] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១៣។

[141] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១០។

[142] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២។

ត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ បើយោងតាមមាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី អ្នកដែលមានអំណាចមេបាលើកូនដែលម្ដាយមិនបានរៀបអាពាហ៍ពិពាហ៍ គឺម្ដាយ។ហើយស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន ដោយអនុលោមតាមមាត្រា ៩៨៧ នៃក្រមដដែល។ យ៉ាងណាមិញ បើយោងតាមកថាខណ្ឌទី២ និងទី៣នៃមាត្រា ១០៣៨ ដដែលនេះ ឪពុកអាចប្រើប្រាស់អំណាចមេបាចំពោះកូនដែលខ្លួនបានទទួលស្គាល់បានលុះត្រាតែមានការយល់ព្រម និង កំណត់យកឪពុកនោះជាអ្នកមានអំណាចមេបាក្រោយការពិភាក្សារបស់ឪពុកម្ដាយទាំងសងខាង។ ប៉ុន្តែប្រសិនបើពុំអាចសម្រេចបាន ឬមិនអាចធ្វើការពិភាក្សាបាន នោះតុលាការត្រូវកំណត់អ្នកមានអំណាចមេបាតាមការទាមទាររបស់ឪពុក ឬ ម្ដាយរបស់កូន។

❖ **ការសម្រេចសេចក្ដី**

ដូចកំណត់នៅក្នុងច្បាប់ ការកំណត់មាតុភាពគឺមានការងាយស្រួល ព្រោះថាស្ត្រីដែលបានសម្រាលកូនគឺជាម្ដាយរបស់កូន[143]។ ហើយអ្នកដែលមានអំណាចមេបាលើកូនដែលម្ដាយមិនបានរៀបអាពាហ៍ពិពាហ៍បានកើតឡើង គឺម្ដាយ។ យ៉ាងណាមិញ ភាគីឪពុកអាចប្រើប្រាស់អំណាចមេបាចំពោះកូនដែលខ្លួនបានទទួលស្គាល់បានលុះត្រាតែមានការយល់ព្រម និង កំណត់យកឪពុកនោះជាអ្នកមានអំណាចមេបាក្រោយការពិភាក្សារបស់ឪពុកម្ដាយទាំងសងខាង។ ប៉ុន្តែប្រសិនបើពុំអាចសម្រេចបាន ឬមិនអាចធ្វើការពិភាក្សាបាន នោះតុលាការត្រូវកំណត់អ្នកមានអំណាចមេបាតាមការទាមទាររបស់ឪពុក ឬ ម្ដាយរបស់កូន[144]។

ដូចនេះមិនមានបញ្ហាចោទទេ ក្នុងករណីមានបណ្ដឹងទាមទារកំណត់អ្នកមានអំណាចមេបាពីសំណាក់ឪពុករបស់កូន ទោះបីជាវាចំណងអនីតិសង្វាសក៏ដោយ ក៏តុលាការនឹងធ្វើការសម្រេចដូចដែលច្បាប់បានកំណត់[145]។

### ខ. មូលដ្ឋានគតិយុត្តដើម្បីវិនិច្ឆ័យករណីគ្មានបណ្ដឹងទាមទារអ្នកមានអំណាចមេបា

❖ **មូលដ្ឋានគតិយុត្តសម្រាប់វិនិច្ឆ័យ**

នៅក្នុងសំនុំរឿងអនីតិសង្វាស ការកំណត់អំពីអ្នកអំណាចមេបាដោយឆន្ទានុសិទ្ធតុលាការគឺមិនត្រូវបានកំណត់នៅក្នុងបញ្ញត្តិណាមួយនៃច្បាប់កម្ពុជាឡើយ ពោលវាមានភាពខុសគ្នាពីបណ្ដឹងទាមទារឲ្យលុបចោលចំណងអាពាហ៍ពិពាហ៍ ឬបណ្ដឹងលែងលះ ដោយហេតុថាតុលាការត្រូវធ្វើការសម្រេចសេចក្ដីកំណត់អំពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធរបស់តុលាការ។ ម្យ៉ាងវិញទៀត

[143] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៨៧។
[144] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៣៨។
[145] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១៤។

តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាមួយដែលភាគីមិនបានស្នើសុំ ឬ ទាមទារនោះឡើយ ហើយច្បាប់បានកំណត់ថា តុលាការត្រូវចេញសាលក្រមចំពោះតែការទាមទារទាំងឡាយដែលធ្វើឡើងដោយភាគីប៉ុណ្ណោះ[146]។

❖ **ការសម្រេចសេចក្តី**

ដូចមានចែងក្នុងច្បាប់ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាមួយដែលភាគីមិនបានសុំ ឬទាមទារនោះឡើយ ហើយច្បាប់បានកំណត់ថាតុលាការត្រូវចេញសាលក្រមចំពោះតែការទាមទារទាំងឡាយដែលធ្វើឡើងដោយភាគីតែប៉ុណ្ណោះ។[147]

ដូចនេះតុលាការនឹងមិនធ្វើការសម្រេចសេចក្តីនោះទេ ក្នុងករណីដែលគ្មានបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបាលើកូននោះទេ។

### ៣.២.២ ការអនុវត្តជាក់ស្តែងលើការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាសនៅតុលាការ

ចំពោះការអនុវត្តជាក់ស្តែងលើការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាសនៅក្នុងតុលាការដែលនឹងធ្វើការអត្ថាធិប្បាយក្នុងចំណុចនេះ ក្រុមយើងខ្ញុំនឹងផ្អែកទៅលើរបាយការណ៍កម្មសិក្សានៅតុលាការខេត្តព្រៃវែងដែលធ្វើឡើងដោយលោក **ប៊ុន រតនៈ** សិស្សចៅក្រមជំនាន់ទី៧ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ធ្វើជាឯកសារគោលក្នុងការពិភាក្សាអំពីការអនុវត្តជាក់ស្តែងលើការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាសនៅតុលាការ ដោយហេតុថារបាយការណ៍ស្រាវជ្រាវដែលធ្វើឡើយដោយ ប៊ុន រតនៈ គឺមានភាពច្បាស់លាស់ ក្បោះក្បាយ និងមានតម្លៃក្នុងការយកមកសិក្សាពីចំណុចមួយនេះ។

#### ៣.២.២.១ មូលដ្ឋានគតិយុត្តសម្រាប់ការវិនិច្ឆ័យសេចក្តី

##### ៣.២.២.១.១ ការបញ្ចប់ការរួមរស់ជាអនីតិសង្វាស

**ក. ករណីមានបណ្តឹងទាមទារឲ្យលែងលះ**

ទោះបីជាការលែងលះអាចធ្វើឡើង ចំពោះតែសហព័ទ្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ យ៉ាងណាមិញ នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ចៅក្រមបានធ្វើការវិនិច្ឆ័យដោយប្រើប្រាស់ និងយកបញ្ញត្តិរបស់អាពាហ៍ពិពាហ៍ស្តីពីមូលហេតុនៃការលែងលះ មានចែងក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា មកអនុវត្តន៍ចំពោះបណ្តឹងទាមទារឲ្យលែងលះរបស់អនីតិសង្វាស។ នៅក្នុងករណីដែល គូភាគីនៃអនីតិសង្វាសមានការព្រមព្រៀងគ្នា តុលាការសម្រេច

---

[146] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២។

[147] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២។

សេចក្តីដោយអនុលោមតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

បើយើងក្រលែកមើលនៅក្នុងច្បាប់កម្ពុជាវិញ ការលែងលះរបស់អនីតិសង្វាសមិនត្រូវបានកំណត់ដោយច្បាប់នោះទេ។ យ៉ាងណាមិញ បើយើងសង្កេតទៅលើមាត្រា ៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីវិញ ក្រមរដ្ឋប្បវេណីអាចយកមកអនុវត្តន៍ជា**គោលការណ៍សមធម៌**បានក្នុងករណីអវត្តមាននៃច្បាប់ ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គមមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីគ្មានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទំលាប់។ ចំពោះករណីនេះ តុលាការធ្វើការសម្រេចសេចក្តីដោយផ្អែកលើមាត្រាពាក់ព័ន្ធនឹងការលែងលះក្នុងក្រមរដ្ឋប្បវេណីដោយផ្អែកលើគោលការណ៍សមធម៌នេះឯង[148]។

## ខ. ករណីមានបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍

តាមការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ចៅក្រមធ្វើការវិនិច្ឆ័យបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ ដោយអនុលោមតាមមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បានកំណត់អំពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានដូចជាៈ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍តាមមាត្រា ៩៥៨ បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍តាមមាត្រា ៩៥៩ ដល់ មាត្រា ៩៦៣ បណ្តឹងទាមទារឲ្យលែងលះតាមមាត្រា ៩៧៨ និងបណ្តឹងផ្សេងៗទៀតដែលមានបំណងបង្កើត បញ្ជាក់អត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គលជាដើម[149]។ ចំពោះបណ្តឹងផ្សេងទៀតដែលមានបំណងបង្កើត បញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលក្នុងមាត្រា៣ នៃច្បាប់ខាងលើអាចអនុវត្តទៅបានកាលណាមានច្បាប់ចែងអំពីទំនាក់ទំនងឋានៈបុគ្គលដែលមាននៅក្នុងបណ្តឹងទាមទារនោះ។ ក៏ប៉ុន្តែ ការបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍មិនមានចែងនៅក្នុងច្បាប់កម្ពុជានោះទេ។ យ៉ាងណាមិញ បើយោងទៅតាមមាត្រា ៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី គេបានបញ្ជាក់ថា ក្រមរដ្ឋប្បវេណីអាចយកមកអនុវត្តន៍ជាគោលការណ៍សមធម៌បាន ក្នុងករណីអវត្តមាននៃច្បាប់ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គមមុនកាលបរិច្ឆេទនៃការអនុវត្ត ករណីគ្មានបទដ្ឋានគតិយុត្ត ឬបញ្ញត្តិទំនៀមទំលាប់។ បន្ថែមពីនេះទៅទៀត មាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំ អង្គតុលាការបានបញ្ញត្តិថា **តុលាការនៃសាលាដំបូងមានសមត្ថកិច្ចជំនុះជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំងឡាយណាដែលពុំមានបញ្ញត្តិណាមួយប្រគល់សមត្ថកិច្ចឲ្យតុលាការជំនាញផ្សេងៗទៀតដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធី**

[148] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញៈ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១៩-២០។

[149] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៣។

**រដ្ឋប្បវេណី។** ទន្ទឹមគ្នានេះដែរ មាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានបញ្ជាក់ថា **ច្បាប់នេះមានគោលដៅបញ្ញត្តិនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណីចំពោះទំនាក់ទំនងទាក់ទិននឹងឋានៈបុគ្គល។** តួយ៉ាងដូចករណីរឿងក្តីអនីតិសង្វាសនេះ ទោះបីពួកគេមិនមែនជាប្តីប្រពន្ធដែលច្បាប់បានទទួលស្គាល់ ឬ គ្មានឋានៈជាសហព័ទ្ធស្របទៅតាមច្បាប់ក៏ពិតមែន ក៏ប៉ុន្តែពួកគេមានជីវភាពរស់នៅដូចជាប្តីប្រពន្ធស្របច្បាប់ស្ទើរគ្រប់ចំណុច ខុសគ្នាត្រង់ថាពួកគេមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬ គ្មានអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ។

ដោយយោងតាមមាត្រានានា នៃច្បាប់ផ្សេងៗ ដូចបានរៀបរាប់ខាងលើ ចៅក្រមបានធ្វើការបកស្រាយ និង ប្រើប្រាស់ក្រមរដ្ឋប្បវេណីក្នុងករណីបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍របស់អនីតិសង្វាសជន ដោយប្រើប្រាស់នូវគោលការណ៍សមធម៌ ដើម្បីដោះស្រាយបញ្ហាសង្គមដែលបានបញ្ហាប្រឈមកំពុងកើតឡើង ដោយហេតុថាចំណងអនីតិសង្វាសបានក្លាយទៅជាស្ថានភាពទូទៅទៅហើយក្នុងសង្គមបច្ចុប្បន្ន ជាពិសេសនៅតាមបណ្តាខេត្ត និង ទីជនបទនានាទូទាំងប្រទេសកម្ពុជា[150]។ម្យ៉ាងទៀត ប្រសិនបើស្ថាបន័តុលាការមិនអាចដោះស្រាយបណ្តឹង និងបញ្ហាវិវាទរបស់អនីតិសង្វាសនោះ គេក៏មិនឃើញមានស្ថាប័នណាមួយដែលមានសមត្ថកិច្ច អាចដោះស្រាយវិវាទរបស់ពួកគេនោះទេ។

### គ. ករណីមានបណ្តឹងទាមទារឲ្យបំបែកអនីតិសង្វាស

ក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ចំពោះបណ្តឹងដែលទាមទារឲ្យបំបែកអនីតិសង្វាស ចៅក្រមធ្វើការពិចារណាលើករណី២ គឺការបំបែកអនីតិសង្វាសដោយការព្រមព្រៀង និង ការបំបែកអនីតិសង្វាសដោយមិនមានការព្រមព្រៀង។ ចំពោះការបំបែកអនីតិសង្វាសដោយការព្រមព្រៀង តុលាការខេត្តព្រៃវែងបានធ្វើការបកស្រាយប្រដូចទៅនឹង ការលែងលះដោយព្រមព្រៀងរបស់អាពាហ៍ពិពាហ៍ដែរ ដូចមានចែងក្នុងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ក្នុងករណីមានការព្រមព្រៀងគ្នាអំពីការលែងលះដោយភាគីទាំងពីរ។ រីឯការបំបែកអនីតិសង្វាសដោយមិនមានការព្រមព្រៀងវិញ នៅពេលដែលគ្មានការព្រមព្រៀងក្នុងការបំបែកអនីតិសង្វាសពីភាគី ចៅក្រមបានយកបញ្ញត្តិ ស្តីពីមូលហេតុនៃការលែងលះរបស់អាពាហ៍ពិពាហ៍មកធ្វើការពិចារណាក្នុងបណ្តឹងប្រភេទនេះ។ យោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ប្តីប្រពន្ធអាចដាក់ពាក្យបណ្តឹងធ្វើការលែងលះបានដោយមូលហេតុមួយចំនួនដូចជាៈ ភាគីបានប្រព្រឹត្តិអំពើផិតទៅលើសហព័ទ្ធម្ខាងទៀត ការបោះបង់សហព័ទ្ធចោលដោយ

[150] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញៈ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១៩-២០។

គ្មានមូលហេតុត្រឹមត្រូវ ករណីមិនដឹងច្បាស់ថាសហព័ទ្ធម្ខាងទៀតស្លាប់ ឬរស់អស់រយៈពេលជាង ១ ឆ្នាំ ករណីសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ឆ្នាំ ដែលវាផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ពោលគឺការរួមសមគ្គសង្វាសនឹងគ្នា និង ករណីផ្សេងៗទៀតដែលចំណងអាពាហ៍ពិពាហ៍គ្មានសង្ឃឹមថានឹងអាចបដិទាន (សះជា) ឡើងវិញបានជាដើម[151] ។

មានថៅក្រមមួយចំនួនបានបកស្រាយថា ការបំបែកអនីតិសង្វាស គឺមិនមានចែងនៅក្នុងច្បាប់នោះទេ។ ចំពោះករណីនេះ មាត្រា ៧៤ នៃក្រមរដ្ឋប្បវេណីបានចែងថា បណ្តឹងអាចធ្វើឡើងបាន លុះត្រាតែបណ្តឹងនោះមានកម្មវត្ថុវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង អាចដោះស្រាយដោយសាលក្រមបាន។ ក៏ប៉ុន្តែ ប្រសិនជាយើងពិនិត្យមើលទៅលើមាត្រា ៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីវិញ គឺថាក្រមរដ្ឋប្បវេណីអាចយកមកអនុវត្តន៍ជាគោលការណ៍សមធមិបាន ក្នុងករណីអវត្តមាននៃច្បាប់ ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គម មុនកាលបរិច្ឆេតនៃការអនុវត្ត ករណីគ្មានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទំលាប់ជាដើម។ ផ្អែកតាមមាត្រានេះ ថៅក្រមអាចយកក្រមរដ្ឋប្បវេណីមកអនុវត្តដោយផ្អែកតាមគោលការណ៍សមធមិ ដើម្បីយកមកដោះស្រាយបញ្ហាដែលអវត្តមាននៃច្បាប់បាន[152]។

### ៣.២.២.១.២ ការបែងចែកទ្រព្យសម្បត្តិ

#### ក. ករណីមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ

ចំពោះការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ក្នុងករណីមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ តុលាការនឹងធ្វើការពិចារណាទៅលើឆន្ទៈរបស់គូភាគីថាតើមានការព្រៀមព្រៀងគ្នាក្នុងការចែកទ្រព្យសម្បត្តិដែរឬទេ។ ក្នុងករណីគ្មានការព្រមព្រៀងក្នុងការចែកទ្រព្យនោះទេ តុលាការនឹងកំណត់បែងចែកទ្រព្យដោយផ្អែកលើមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណីទាក់ទិននឹងការបែងចែកទ្រព្យសម្បត្តិ និងគោលការណ៍ទ្រព្យរួម និងទ្រព្យដោយឡែកដែលកំនត់ក្នុងច្បាប់[153]។

#### ខ. ករណីគ្មានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ

ដូចមានចែងក្នុងច្បាប់ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាមួយដែលភាគីមិនបានសុំ ឬទាមទារនោះឡើយ ហើយច្បាប់បានកំណត់ថាតុលាការត្រូវចេញសាលក្រមចំពោះតែការទាមទារទាំងឡាយដែលធ្វើឡើងដោយភាគីតែប៉ុណ្ណោះ[154]។ ដូចគ្នានេះដែរ នៅក្នុងការអនុវត្ត

---

[151] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨។

[152] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២១។

[153] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២១។

[154] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២។

ជាក់ស្តែងនៅក្នុងតុលាការខេត្តព្រៃវែង តុលាការនឹងមិនចេញសាលក្រមនោះទេ ក្នុងករណីគ្មានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យសម្បត្តិពីសំណាក់គូភាគី។

### ៣.២.២.១.៣ ការកំណត់អ្នកមានអំណាចមេបា

#### ក. ការសម្រេចសេចក្តីលើបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា

បើយោងតាមកថាខណ្ឌទី២ និងទី៣ នៃមាត្រា ១០៣៨ នៃក្រមដដែល ឪពុកអាចប្រើប្រាស់អំណាចមេបាចំពោះកូនដែលខ្លួនបានទទួលស្គាល់បានលុះត្រាតែមានការយល់ព្រម និង កំណត់យកឪពុកនោះជាអ្នកមានអំណាចមេបាក្រោយការពិភាក្សារបស់ឪពុកម្តាយទាំងសងខាងប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើពុំអាចសម្រេចបាន ឬមិនអាចធ្វើការពិភាក្សាបាន នោះតុលាការត្រូវកំណត់អ្នកមានអំណាចមេបាតាមការទាមទាររបស់ឪពុក ឬម្តាយរបស់កូន។ ដូចនេះក្នុងករណីមានបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបាពីគូភាគីអនីតិសង្វាស នោះតុលាការនឹងធ្វើការសម្រេចកំណត់ពីអ្នកដែលមានអំណាចមេបាទៅលើកូន ដោយធ្វើការពិចារណាផ្អែកទៅលើចំណុចផ្សេងៗ ដូចជាផលប្រយោជន៍របស់កូន រួមមាន សុខភាពរូបរាងកាយ បញ្ហាផ្លូវចិត្តរបស់កូន និងជីវភាព ឬចំណូលរបស់ភាគីទាំងសងខាងជាដើម[155]។

#### ខ. ការសម្រេចសេចក្តីក្នុងករណីគ្មានបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា

នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង រាល់បណ្តឹងពាក់ព័ន្ធនឹងការបំបែកអនីតិសង្វាស គូភាគីដែលមានកូនតែងតែទាមទារ ឬ ស្នើសុំឲ្យតុលាការធ្វើការសម្រេចកំណត់អ្នកមានអំណាចមេបាទៅលើកូនៗរបស់ពួកគេ ពោលគឺកម្រមានករណី គូភាគីដែលមានកូន រួចមិនធ្វើការទាមទារអំណាចមេបាទៅលើកូន នៅពេលមានបណ្តឹងផ្តាច់អនីតិសង្វាសណាស់។ ម្យ៉ាងទៀតតុលាការតែងតែរំលឹកដល់ភាគីលើបញ្ហានេះ ដោយឲ្យភាគីបន្ថែមនូវកម្មវត្ថុក្នុងបណ្តឹង ក្នុងករណីដែល គូភាគីមិនបានទាមទារ ឬ ស្នើសុំតុលាការឲ្យកំណត់ពីអ្នកមានអំណាចមេបា ព្រោះធ្វើដូចនេះបញ្ហារបស់ភាគីត្រូវបានដោះស្រាយបានចប់ចុងចប់ដើម[156]។

### ៣.២.២.២ ការអនុវត្តជាក់ស្តែងលើសេចក្តីសម្រេច

### ៣.២.២.២.១ ការសម្រេចសេចក្តីលើការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស

#### ក. បណ្តឹងទាមទារឲ្យបញ្ឈប់ការរួមរស់ជាអនីតិសង្វាស

នៅក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ចៅក្រមធ្វើការសម្រេចសេចក្តីលើបណ្តឹងទាមទារឲ្យបញ្ឈប់ការរួមរស់ជាអនីតិសង្វាស ដោយធ្វើការពិចារណាលើឆន្ទៈរបស់គូភាគី។

[155] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២២។
[156] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស*. (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២២។

ក្នុងករណីដែលភាគីមានការព្រមព្រៀងគ្នាក្នុងការបញ្ឈប់ការរួមរស់ជាអនីតិសង្វាស នោះចៅក្រមភាគច្រើននឹងចេញសាលក្រមបញ្ឈប់ការរួមរស់ជាអនីតិសង្វាសរបស់ភាគីតាមការព្រមព្រៀង។ ក្នុងករណីគ្មានការព្រមព្រៀងគ្នាក្នុងការបញ្ឈប់ការរួមរស់ជាអនីតិសង្វាសនោះទេ តុលាការនឹងពិនិត្យសំនុំរឿងនេះ ដោយយកបញ្ញត្តិស្តីពីមូលហេតុនៃការលែងលះរបស់អាពាហ៍ពិពាហ៍មកពិនិត្យ រួចតុលាការនឹងចេញសេចក្តីសម្រេចបង្គាប់ឲ្យភាគីបញ្ឈប់ ឬ មិនបញ្ឈប់ការរួមរស់ជាអនីតិសង្វាសរបស់ពួកគេ។

យ៉ាងណាមិញ កម្រនឹងមានសាលក្រមណាមួយដែលសម្រេចមិនឲ្យភាគីបញ្ឈប់ការរួមរស់ជាអនីតិសង្វាសរបស់ពួកគេណាស់ ដោយហេតុថា ចំណងអនីតិសង្វាសត្រូវបានកើតឡើងដោយផ្អែកខ្លាំងទៅលើមនោសញ្ចេតនា និង ឆន្ទៈសេរីរបស់ភាគីទាំងសងខាងនៃអនីតិសង្វាស ដែលជាបញ្ហាដែលតុលាការមិនអាចមើលរំលង។ ពោល គឺតុលាការមិនអាចបង្ខំឲ្យពួកគេនៅបន្តការរស់នៅបែបអនីតិសង្វាសនោះទេ លុះត្រាតែក្នុងករណីការបញ្ឈប់ការរស់នៅបែបអនីតិសង្វាសរបស់ពួកគេអាចបណ្តាលឲ្យមានបញ្ហាប្រឈមដល់ការទ្រទ្រង់ជីវភាពរបស់ភាគីម្ខាងទៀត ឬធ្វើឲ្យកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលមិនអាចទ្រាំទ្របាន ដែលតុលាការនឹងច្រានចោលបណ្តឹងនោះចោលដោយពិចារណាលើស្ថានភាព និងផលវិបាកដូចបានរៀបរាប់ខាងលើ[157] ដូចគ្នានឹងការអនុវត្តចំពោះការលែងលះរបស់អាពាហ៍ពិពាហ៍ផងដែរ។

## ខ. បណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍

តាមការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រៃវែង ចៅក្រមធ្វើការវិនិច្ឆ័យបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍របស់អនីតិសង្វាស ដោយអនុលោមតាមមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានកំណត់បណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលបានបញ្ជាក់ថា ក្រមរដ្ឋប្បវេណីអាចត្រូវយកមកអនុវត្តន៍ជា**គោលការណ៍សមធម៌**បាន ក្នុងករណីអវត្តមាននៃច្បាប់ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គមមុនកាលបរិច្ឆេតនៃការអនុវត្ត ករណីគ្មានបទដ្ឋានគតិយុត្ត ឬ បញ្ញត្តិទំនៀមទំលាប់ មាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំអង្គតុលាការដែលបានបញ្ញត្តិថា តុលាការនៃសាលាដំបូងមានសមត្ថកិច្ចជំនុះជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំងឡាយណាដែលពុំមានបញ្ញត្តិណាមួយប្រគល់សមត្ថកិច្ចឲ្យតុលាការជំនាញផ្សេងៗទៀត ដោយអនុវត្តន៍ទៅតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាដើម មកធ្វើជាមូលដ្ឋាននៅក្នុងការដោះស្រាយបណ្តឹងបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ធ្វើឡើង

[157] ប៊ុនរតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២៣។

ដោយប្តីប្រពន្ធអនីតិសង្វាស[158]។

នៅពេលមានបណ្តឹងទាមទារឲ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ ធ្វើឡើងដោយប្តីប្រពន្ធអនីតិសង្វាសនោះ ចៅក្រមនៃសាលាដំបូងខេត្តព្រៃវែងនឹងធ្វើការពិនិត្យថាតើភាគីបានចុះសំបុត្រអាពាហ៍ពិពាហ៍ដែរឬទេ។ តែប្រសិនបើពិនិត្យឃើញថា គូភាគីពិតជាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ តុលាការនឹងចេញសេចក្តីសម្រេចបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍របស់គូភាគីនៃអនីតិសង្វាស ដោយបង្គាប់ឲ្យភាគីបញ្ឈប់ការរួមរស់ជាអនីតិសង្វាសបន្ថែមក្នុងសេចក្តីសម្រេចរបស់តុលាការ។

មូលហេតុដែលចៅក្រមនៃសាលាដំបូងខេត្តព្រៃវែងធ្វើការសម្រេចបែបនេះ គឺដើម្បីឲ្យភាគីបំបែកលំនៅរបស់ខ្លួន ឬ បញ្ឈប់ការរួមរស់ជាមួយគ្នាតទៅទៀត។ ចំណុចនេះវាក៏ជាតម្រូវការរបស់អាជ្ញាធរមូលដ្ឋានមួយចំនួនផងដែរ ដើម្បីអនុញ្ញាតិឲ្យគូភាគីអាចធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍បាន ប្រសិនបើពួកគេចង់មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នាពេលអនាគត[159]។

ដូចគ្នានេះដែរ ជាការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហានុ ចាប់ពីឆ្នាំ ២០១៣ មក មានការកែតម្រូវកម្មវត្ថុនៃបណ្តឹងពី *ការផ្តាច់អនីតិសង្វាស* ទៅជា *បណ្តឹងសុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍* វិញ។ ចំណែកឯដំណើរការនៃនីតិវិធីនៃការផ្តាច់អនីតិសង្វាស សាលាដំបូងខេត្តព្រះសីហានុធ្វើការសម្រេចសេចក្តីដោយឈរលើច្បាប់ស្តីពីនីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល ដូចគ្នានឹងតុលាការខេត្តព្រៃវែងដែរ ឬ ឈរលើនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដោយការធ្វើនីតិវិធីសម្រាប់ការទាញហេតុផលផ្ទាល់មាត់តាមឆន្ទានុសិទ្ធិរបស់ចៅក្រម បន្ទាប់មកចេញដីការសម្រេចប្រសិនបើភាគីមានការព្រមព្រៀងគ្នាជាដើម[160]។

យ៉ាងណាមិញ មូលដ្ឋានគតិយុត្តរបស់តុលាការខេត្តព្រះសីហានុក្នុងការសម្រេចអំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍របស់អនីតិសង្វាស មិនត្រូវបានបញ្ជាក់នោះទេ ទំនងអាចមានសច្ចធារណ៍តាមផ្លូវតុលាការដែលថា បើគ្មានសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនោះ មានន័យថាវាមាននត្ថិភាពនៃអាពាហ៍ពិពាហ៍[161]។ ដូចគ្នានឹងការអនុវត្តជាក់ស្តែងរបស់តុលាការខេត្តព្រៃវែងផងដែរ គ្រាន់តែថាសេចក្តីសម្រេច ឬ សាលក្រមបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍របស់អនីតិសង្វាសចេញដោយតុលាការខេត្តព្រៃវែង ត្រូវបានបន្ថែមដោយការបង្គាប់ឲ្យភាគីបញ្ឈប់ការរួមរស់ជាអនីតិសង្វាស។

---

[158] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ១៩-២០។

[159] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២៣។

[160] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៥), ៦៦។

[161] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៥), ៦៣។

**គ. ករណីមានបណ្ដឹងទាមទារឲ្យលែងលះ**

ចំពោះករណីមានបណ្ដឹងទាមទារឲ្យលែងលះដែលធ្វើឡើងដោយអនីតិសង្វាសជនវិញ នៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងសាលាដំបូងខេត្តព្រៃវែង ចៅក្រមនឹងធ្វើការសម្រេចសេចក្ដីដូចគ្នាទៅនឹងករណីបណ្ដឹងទាមទារឲ្យបញ្ឈប់ការរួមរស់ជាអនីតិសង្វាសផងដែរ។ មូលហេតុដែលមានការអនុវត្តបែបនេះ ដោយហេតុថាការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរនៅមានកម្រិត ជាពិសេសពលរដ្ឋរស់នៅតាមបណ្ដាខេត្ត និងទីជនបទដាច់ស្រយាល ដោយពួកគាត់យល់ឃើញថាការរស់នៅបែបអនីតិសង្វាសរបស់ពួកគាត់ គឺមានលក្ខណៈជាប្ដីប្រពន្ធដូចជាសហព័ទ្ធស្របច្បាប់ដែរ។ ម្យ៉ាងទៀតប្រជាពលរដ្ឋភាគច្រើនចាត់ទុកថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី គឺធ្វើឲ្យពួកគេក្លាយជាប្ដីប្រពន្ធស្របច្បាប់ ទោះបីគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។ ហេតុដូចនេះ នៅពេលដែលប្ដីប្រពន្ធអនីតិសង្វាសដាក់ពាក្យបណ្ដឹងទៅតុលាការ គឺពួកគេទាមទារឲ្យតុលាការសម្រេចឲ្យពួកគេលែងលះគ្នា ទោះបីខ្លឹមសារទាមទារក្នុងបណ្ដឹងប្រភេទនេះ មិនត្រឹមត្រូវក៏ពិតមែន។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង តុលាការអាចបង្គាប់ឲ្យម្ចាស់បណ្ដឹងធ្វើការកែតម្រូវពាក្យពេចន៍នៃបណ្ដឹងឡើងវិញ ឬ ម្យ៉ាងទៀតតុលាការនឹងធ្វើការសម្រេចសេចក្ដីដោយឆន្ទានុសិទ្ធិ តាមរយៈការចេញសាលក្រមសម្រេចឲ្យភាគីនៃអនីតិសង្វាសបំបែក ឬមិនបំបែកអនីតិសង្វាស[162]។

ផ្ទុយទៅវិញ ចំពោះការអនុវត្តនៅសាលាដំបូងខេត្តព្រះសីហនុវិញ តុលាការតែងតែច្រានចោលរាល់បណ្ដឹងទាមទារឲ្យផ្ដាច់អនីតិសង្វាសរបស់ភាគីបណ្ដឹង ក៏ប៉ុន្តែតុលាការបែជាធ្វើសេចក្ដីសម្រេចលើការកំណត់អំណាចមេបា និងទ្រព្យសម្បត្តិជាដើមទៅវិញ ដោយហេតុថាអនីតិសង្វាសកើតឡើងតាមព្រឹត្តិន័យ ឬកើតឡើងដោយឆន្ទៈសេរីរបស់ភាគី ដូចនេះវាក៏ត្រូវបញ្ចប់ទៅវិញតាមព្រឹត្តិន័យ ឬឆន្ទៈសេរីរបស់ភាគីនៃអនីតិសង្វាសផងដែរ[163]។

រីឯនៅសាលាដំបូងខេត្តបាត់ដំបងវិញ កម្មវត្ថុនៃការទាមទារឲ្យលែងលះក្នុងបណ្ដឹងរបស់ភាគីអនីតិសង្វាសត្រូវបានលើកចោលដោយតុលាការ ដោយអនុលោមតាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រោះកម្មវត្ថុមានលក្ខណៈផ្ទុយនឹងច្បាប់។ យ៉ាងណាមិញតុលាការ នៅតែធ្វើការសម្រេចសេចក្ដីលើការទាមទារកំណត់អំណាចមេបា និង បែងចែកទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធអនីតិសង្វាសដដែល។ ម្យ៉ាងទៀត ទោះបីជាកម្មវត្ថុនៃការសុំលែងលះត្រូវបានលើកចោលដោយតុលាការក៏ដោយ ក៏ប៉ុន្តែតុលាការបានកំណត់ពីសេរីភាពរបស់គូភាគីនៃអនីតិសង្វាសក្នុងការជ្រើសរើសគូស្រករថ្មី និង អាចរៀបអាពាហ៍ពិពាហ៍ស្របទៅតាមលក្ខខណ្ឌដែលមានចែងតាមច្បាប់នៅ

[162] ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២៥។

[163] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៦២។

ក្នុងសាលក្រមរបស់ខ្លួន ដែលប្រៀបដូចជាបានរំលាយចំណងអនីតិសង្វាសរបស់គូភាគីដូចគ្នានេះដែរ ទោះបីគ្មានការកំណត់ជាផ្លូវការដោយផ្ទាល់ក្នុងសេចក្តីសម្រេចក៏ដោយ[164]។

### ៣.២.២.២.២ ការសម្រេចសេចក្ដីលើការបែងចែកទ្រព្យសម្បត្តិ

### ក. ការសម្រេចសេចក្តីករណីមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ

ក្នុងករណីមានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ តុលាការខេត្តព្រៃវែងនឹងធ្វើការពិនិត្យទៅលើ ឆន្ទៈរបស់ភាគី ថាតើមាការព្រមព្រៀងគ្នាដែរឬទេ។ ប្រសិនបើមានការព្រមព្រៀង តុលាការខេត្តព្រៃវែងនឹងធ្វើការសម្រេច ដោយផ្អែកលើការព្រមព្រៀងគ្នារវាងភាគីនៃអនីតិសង្វាសតាមការទាមទារ។ ក៏ប៉ុន្តែ បើសិនជាគ្មានការព្រមព្រៀងគ្នាទេ នោះតុលាការនឹងធ្វើការពិចារណាដោយយកមាត្រានានានៃប្រព័ន្ធទ្រព្យសម្បត្តិយកមកបកស្រាយលើរឿងក្តីអនីតិសង្វាស។ តុលាការនឹងធ្វើការសម្រេចផងដែរ ដោយកំណត់អំពីទ្រព្យសម្បត្តិដែលភាគីនឹងទទួលបាន ឬមានសិទ្ធិទៅលើទ្រព្យទាំងនោះដោយយុត្តិធម៌ អនុលោមតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ពោលគឺភាគីនីមួយៗនៃអនីតិសង្វាសនឹងទទួលបាន៖

- សហព័ទ្ធនីមួយៗនឹងទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ពួកគេ ដូចមានដែលបានកំណត់ក្នុងមាត្រា៩៧២។
- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធទាំងសងខាងមានសិទ្ធិពាក់កណ្តាល ឬ ១ភាគ២ទៅលើទ្រព្យរួមរបស់ពួកគេ។ ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ភាគីណាម្ខាង តុលាការអាចធ្វើការបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនោះ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងអំឡុងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត ផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម។

មិនតែប៉ុណ្ណោះ ការងារផ្ទះ ឬគេហកិច្ចរបស់សហព័ទ្ធម្ខាង ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះផងដែរ នៅពេលគណនាពីតម្លៃនៃទ្រព្យសម្បត្តិដែលភាគីនីមួយៗបានរួមចំណែកទៅក្នុងទ្រព្យរួម កំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។

[164] សាលក្រមរដ្ឋប្បវេណីលេខ ៣៧៤ (ជ) របស់សាលាដំបូងខេត្តបាត់ដំបង ចុះថ្ងៃទី២៨/០៧/២០១៦ នៃសំនុំរឿងរដ្ឋប្បវេណី។
លេខ ១៩៦ ចុះថ្ងៃទី ២៥/០៣/២០១៦។

រីឯនៅសាលាដំបូងខេត្តបាត់ដំបងវិញ ការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាសក៏មានការទទួលស្គាល់ទ្រព្យរួម អនុលោមតាមមាត្រា៩៧៣ ហើយការបែងចែកទ្រព្យទៀតសោតគឺ បានអនុលោមតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណីផងដែរ[165]។ ទោះបីមានការធ្វើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយដើមចោទក្នុងសំនុំរឿងដដែល តុលាការនៅតែធ្វើការសម្រេចសេចក្តីបែងចែកទ្រព្យសម្បត្តិរបស់ អនីតិសង្វាសជនដោយអនុលោមតាមមាត្រា ៩៨០ នេះដដែល[166]។

ដូចគ្នានេះដែរ ក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហនុ ក្នុងករណីការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាស តុលាការក៏បានយកបញ្ញត្តិស្តីពីទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្នុងក្រមរដ្ឋប្បវេណីមកដោះស្រាយផងដែរ[167]។

### ខ. ការសម្រេចសេចក្តីករណីគ្មានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យ

ដូចគ្នានេះដែរ នៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងតុលាការខេត្តព្រៃវែង តុលាការនឹងមិនចេញសាលក្រមនោះទេ ក្នុងករណីគ្មានបណ្តឹងទាមទារឲ្យបែងចែកទ្រព្យសម្បត្តិពីភាគី។ ដូចមានចែងក្នុងច្បាប់ តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាមួយដែលគូភាគីមិនបានសុំ ឬទាមទារនោះឡើយ ហើយច្បាប់បានកំណត់ថាតុលាការត្រូវចេញសាលក្រមចំពោះតែការទាមទារទាំងឡាយដែលធ្វើឡើងដោយភាគីតែប៉ុណ្ណោះ[168]។

### ៣.២.២.២.៣ ការសម្រេចសេចក្តីលើការកំណត់អ្នកមានអំណាចមេបា

### ក. ករណីមានបណ្តឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបា

នៅក្នុងការអនុវត្តរបស់តុលាការ ករណីមានបណ្តឹងទាមទារកំណត់អ្នកមានអំណាចមេបាក្នុងរឿងក្តីអនីតិសង្វាស តុលាការនឹងអនុលោមតាមមាត្រា ១០៣៨ ករណីការទាមទារអ្នកមានអំណាចមេបាលើកូនដែលម្តាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍។ បើយោងតាមកថាខណ្ឌទី២ និងទី ៣ នៃមាត្រាដដែលនេះ ឪពុកអាចប្រើប្រាស់អំណាចមេបាចំពោះកូនដែលខ្លួនបានទទួលស្គាល់បានលុះត្រាតែមានការយល់ព្រម និង កំណត់យកឪពុកនោះជាអ្នកមានអំណាចមេបាក្រោយការពិភាក្សារបស់ឪពុកម្តាយទាំងសងខាង ប៉ុន្តែប្រសិនបើពុំអាចសម្រេចបាន ឬមិនអាចធ្វើការពិភាក្សាបាន នោះតុលាការត្រូវកំណត់អ្នកមានអំណាចមេបាតាមការទាមទាររបស់ឪពុក ឬម្តាយរបស់កូន។

---

[165] សាលក្រមរដ្ឋប្បវេណីលេខ ៣៧៩ (ជ) របស់សាលាដំបូងខេត្តបាត់ដំបង ចុះថ្ងៃទី២៨/០៧/២០១៦ នៃសំនុំរឿងរដ្ឋប្បវេណី។
លេខ ១៩៦ ចុះថ្ងៃទី ២៥/០៣/២០១៦។

[166] សាលដីកាលេខ ០៩ ក្រ III ″ន” របស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៤ /០៧/២០១៧ នៃ សំនុំរឿងរដ្ឋប្បវេណីលេខ ៦៥៨ ចុះថ្ងៃទី ២៨/១២/២០១៦។

[167] ចក សម្បត្តិ, *អនីតិសង្វាស* (ភ្នំពេញ,២០១៤), ៦៨។

[168] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២។

ដូចនេះក្នុងករណីមានបណ្ដឹងទាមទារឲ្យកំណត់អ្នកមានអំណាចមេបាពីភាគី នោះតុលាការនឹងធ្វើការសម្រេចកំណត់អ្នកមានអំណាចមេបា ដោយធ្វើការពិចារណាដោយផ្អែកទៅលើចំណុចផ្សេងៗពាក់ព័ន្ធនឹងផលប្រយោជន៍របស់កូន[169]។

ត្រង់ចំណុចនេះ តុលាការនឹងពិនិត្យទៅលើស្ថានភាពរបស់ឪពុកម្ដាយ និងស្ថានភាពរបស់កូន។ ស្ថានភាពដែលតុលាការនឹងពិនិត្យចំពោះឪពុកម្ដាយ រួមមាន៖ សមត្ថភាពនៃការថែទាំ (អាយុ អត្តចរិត ការអប់រំ ស្ថានភាពសុខភាព) បរិស្ថានគ្រួសារ ផ្នែកសតិអារម្មណ៍ និងផ្នែកសេដ្ឋកិច្ច (បរិស្ថាននៃទ្រព្យសម្បត្តិ ប្រាក់ចំណូល មុខរបរ ការរស់នៅ ជីវភាព) បរិស្ថាននៃលំនៅដ្ឋាន បរិស្ថាននៃការអប់រំ ស្ថានភាព ឬ អតីតភាពនៃការថែទាំកូនកន្លងមក ទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះ ការជួយគាំទ្ររបស់សាច់ញាតិជាដើម។ រីឯស្ថានភាពខាងកូនវិញ តុលាការនឹងធ្វើការពិចារណា នូវអាយុ ភេទ ស្ថានភាពនៃការវិវត្តខាងផ្លូវកាយ និងផ្លូវចិត្តរបស់កូន ស្ថានភាពនៃការបន្សាំនឹងបរិស្ថាន ការបន្សាំនឹងការផ្លាស់ប្ដូរ បរិយាកាស ឆន្ទៈរបស់កូន ទំនាក់ទំនងខាងអារម្មណ៍រវាងឪពុកម្ដាយ និងសាច់ញាតិជាដើម[170]។

ហេតុនេះហើយ ជាការអនុវត្តទូទៅនៅក្នុងតុលាការកម្ពុជា ក្នុងករណីដែលកូនអាចនិយាយបាន និង ដឹងខុសត្រូវត្រឹមកម្រិតមួយដែលចៅក្រមជឿទុកចិត្តបាន នោះចៅក្រមនឹងផ្អែកលើការសម្រេចចិត្តរបស់កូនថាស្ម័គ្រចិត្តរស់នៅជាមួយភាគីម្ដាយ ឬ ឪពុក នេះបើយោងតាមមាត្រា ២២ កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។

### ខ. ករណីគ្មានបណ្ដឹងកំណត់អ្នកមានអំណាចមេបា

បើតាមរបាយការណ៍សិក្សាស្រាវជ្រាវរបស់លោក ប៊ុន រតនៈ ជាសិស្សចៅក្រមជំនាន់ទី៧ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ករណីនេះមិនធ្លាប់កើតមានឡើងក្នុងការអនុវត្តជាក់ស្ដែងក្នុងតុលាការខេត្តព្រៃវែងនោះទេ ដោយហេតុថារាល់បណ្ដឹងទាក់ទិននឹងការបំបែកអនីតិសង្វាស គូភាគីដែលមានកូនតែងតែទាមទារ ឬ ស្នើសុំឲ្យតុលាការធ្វើការសម្រេចកំណត់អ្នកមានអំណាចមេបាទៅលើកូនៗរបស់ពួកគេជានិច្ច។

ម្យ៉ាងទៀត តុលាការតែងតែរំលឹកដល់គូភាគីលើបញ្ហានេះ ដោយឲ្យភាគីបន្ថែមនូវកម្មវត្ថុក្នុងបណ្ដឹង ក្នុងករណីដែលគូភាគិមិនបានទាមទារ ឬស្នើសុំតុលាការឲ្យកំណត់ពីអ្នកមានអំណាចមេបា

---

169 ប៊ុន រតនៈ, *ការសម្រេចសេចក្ដីលើរឿងក្ដីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២៤-២៥។

170 Higashio Kazuyuki, "ការអនុវត្តជាក់ស្ដែងនៃការលែងលះ" (វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីច្បាប់, ១៥ មីនា ២០១៨)។

ព្រោះធ្វើដូចនេះ បញ្ហារបស់ភាគីត្រូវបានដោះស្រាយបានចប់ចុងចប់ដើម [171]។

[171] ប៊ុន រតនៈ, *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* (ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០១៨), ២២។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អនីតិសង្វាសគឺ ស្ថានភាពរបស់បុរសនារីដែលរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធស្របច្បាប់ គ្រាន់តែគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែពួកគេមានឆន្ទៈរៀបអាពាហ៍ពិពាហ៍។ សព្វថ្ងៃ អនីតិសង្វាសនៅតែជាបញ្ហាប្រឈមមួយនៅក្នុងសង្គមកម្ពុជា ដោយសារទំនាក់ទំនងប្រភេទនេះមិនត្រូវបានច្បាប់ទទួលស្គាល់ថាជាប្តីប្រពន្ធស្របច្បាប់។ ក៏ប៉ុន្តែ មិនមានន័យថាចំណងអនីតិសង្វាសត្រូវបានទទួលការរើសអើង ក្នុងការទទួលបានសេវាយុត្តិធម៌ពីតុលាការ ឬមិនត្រូវបានទទួលការយកចិត្តទុកដាក់ពីរដ្ឋនោះទេ។

ការសិក្សាពីអនីតិសង្វាស ជាមួយនឹងសញ្ញាណ លក្ខខណ្ឌ អានុភាព និងការរំលាយអនីតិសង្វាសពិតជាមានសារៈសំខាន់ចំពោះអ្នកច្បាប់ ដោយហេតុថា ទោះបីជាចំណងមួយនេះមិនត្រូវបានទទួលស្គាល់ដោយច្បាប់ ឬ គ្មានវិធានគតិយុត្តគ្រប់គ្រងទំនាក់ទំនងប្រភេទនេះក៏ពិតមែន ក៏ប៉ុន្តែយើងសង្កេតឃើញថា ប្រជាជនកម្ពុជាមួយចំនួនធំនៅតែបន្ត ឬ ជ្រើសយកការរស់នៅបែបអនីតិសង្វាសសម្រាប់ជីវិតគូរបស់ពួកគេ ដោយសារកង្វះខាតការយល់ដឹងផ្នែកច្បាប់ និងមូលហេតុផ្សេងៗ។

ខុសគ្នាពីចំណងអាពាហ៍ពិពាហ៍ដែលច្បាប់បានការពារ និង កំណត់យ៉ាងច្បាស់លាស់នៅក្នុងវិធានគតិយុត្តនានា ដូចជាច្បាប់ឯកពន្ធភាព ក្រមរដ្ឋប្បវេណីជាដើម អនីតិសង្វាសមិនមានវិធានគតិយុត្តណាមួយបានចែង និង គ្រប់គ្រងលើចំណងមួយបែបនេះនោះទេ។ លើសពីនេះទៅទៀត សហព័ទ្ធស្របច្បាប់មិនត្រឹមតែទទួលបានការការពារពីច្បាប់ប៉ុណ្ណោះទេ ក៏ប៉ុន្តែពួកគេបានទទួលនូវសិទ្ធិពិសេសមួយចំនួន (អភ័យឯកសិទ្ធិគ្រួសារ ការអាស្រ័យនូវទ្រព្យសម្បត្តិដោយឡែកជាដើម) ដែលច្បាប់បានផ្តល់ឲ្យ។ រីឯអនីតិសង្វាសវិញមិនទទួលបានសិទ្ធិពិសេសនេះនោះឡើយ។

ជាលទ្ធផល បញ្ហា និង វិវាទគតិយុត្តតែងកើតមានឡើង នៅពេលដែលជីវិតគូនៃប្តីប្រពន្ធអនីតិសង្វាសឈានដល់ទីបញ្ចប់ ឬឈានដល់ការបែកបាក់គ្នា ដោយហេតុថាអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយការលែងលះនៅតុលាការ និងមាននីតិវិធីច្បាស់លាស់ដែលមានចែងនៅក្នុងច្បាប់កម្ពុជា រីឯការលែងលះមិនអាចធ្វើឡើងចំពោះករណីអនីតិសង្វាសនោះទេ ដោយហេតុថាច្បាប់មិនបានកំណត់។ ក៏ប៉ុន្តែពួកគេនៅតែទទួលបានដំណោះស្រាយ និងសម្រេចសេចក្តីដោយឆន្ទានុសិទ្ធិរបស់តុលាការ នៅពេលដែលបណ្តឹងទាមទារឲ្យបញ្ចប់អនីតិសង្វាសត្រូវបានបញ្ជូនដោយគូភាគីអនីតិសង្វាសទៅតុលាការ។

ទោះបីជានៅក្នុងការអនុវត្តជាក់ស្តែង បណ្តឹងរបស់អនីតិសង្វាសនៅតែទទួលបានដំណោះស្រាយពីតុលាការក៏ពិតមែន យ៉ាងណាមិញ យើងសង្កេតឃើញចំណុចរួមពីរ៖ ទី១ គឺការមិនឯកភាព

គ្នាលើការបកស្រាយ ឬ ទទួលស្គាល់ចំណងអនីតិសង្វាសពីសំណាក់ក្រុមអ្នកច្បាប់ និងតុលាការ និង ទី២ គឺការបកស្រាយអានុភាពរបស់អនីតិសង្វាសដូចនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ ឬ ការយកបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍ស្របច្បាប់មកបកស្រាយចំពោះចំណងអនីតិសង្វាស។

ទោះបីជាការធ្វើសេចក្តីសម្រេចដោយតុលាលើរឿងក្តីអនីតិសង្វាស និង ការដោយយកបទបញ្ញត្តិអាពាហ៍ពិពាហ៍មកបកស្រាយលើរឿងក្តីអនីតិសង្វាសត្រូវបានគេមើលឃើញថាខុសពីនីតិវិធីច្បាប់យ៉ាងណាក៏ដោយ ក៏ការដោះស្រាយបណ្តឹងក្នុងរឿងក្តីអនីតិសង្វាស ដោយឈរទៅលើគោលការណ៍សមធម៌របស់ចៅក្រមបានរួមចំណែកដោះស្រាយវិវាទគ្រួសារជាច្រើនដល់ប្តីប្រពន្ធដែលរស់នៅបែបអនីតិសង្វាស ដោយហេតុថាការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋយើងនៅមានកម្រិត ហើយប្រសិទ្ធភាពនៃការចុះបញ្ជីអត្រានុកូលដ្ឋានមិនទាន់ត្រូវបានបញ្ជ្រាបឲ្យទូលំទូលាយជាដើម។

# អនុសាសន៍

តាមរយៈការស្រាវជ្រាវ និងពិភាក្សាលើប្រភពឯកសារផ្សេងៗរួចមក យើងសង្កេតឃើញពីភាពមិនចុះសម្រុងគ្នា ឬ ការមិនឯកភាពគ្នាក្នុងការបកស្រាយ និងទទួលស្គាល់ចំណាងអនីតិសង្វាសពីសំណាក់ក្រុមអ្នកច្បាប់ និងតុលាការបច្ចុប្បន្ន នៅក្នុងស្ថានភាពនៃអវត្តមាននៃវិធានគតិយុត្តស្ដីពីអនីតិសង្វាសនេះ។

ដើម្បីបញ្ចប់នូវវិវាទខាងផ្លូវច្បាប់ ក៏ដូចជាភាពចម្រូងចម្រាស់ក្នុងការអនុវត្តជាក់ស្តែងនៅក្នុងតុលាការ ចំពោះចំណងអនីតិសង្វាស ភាគីពាក់ព័ន្ធគួរតែខិតខំបន្ថែម និងរួមចំណែកក្នុងការធ្វើឲ្យល្អប្រសើរនូវបញ្ហាអនីតិសង្វាសនេះ តាមរយៈ៖

**១. ការបង្កើនការផ្សព្វផ្សាយ និងអប់រំអំពីសារៈសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងផលវិបាកនៃការរស់នៅបែបអនីតិសង្វាស**

ជំរុញឲ្យមានការបង្កើនការផ្សព្វផ្សាយ និង អប់រំឲ្យបានច្រើន និងប្រកបដោយប្រសិទ្ធភាពអំពីសារៈប្រយោជន៍នានានៃការបង្កើតអាពាហ៍ពិពាហ៍ស្របច្បាប់ និងផលវិបាកផ្នែកច្បាប់ក្នុងការរស់នៅបែបអនីតិសង្វាសដល់ប្រជាពលរដ្ឋទូទៅបន្ថែមទៀត ពីលើសកម្មភាពបច្ចុប្បន្ន ជាពិសេសនៅតាមបណ្ដាលខេត្ត និងទីប្រជុំជនដាច់ស្រយាល។

**២. ការពន្លឿននីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជីអត្រានុកូលដ្ឋាននានា**

នីតិវិធីនៃការចុះសំបុត្រអាពាហ៍ពិពាហ៍នៅតែមានលក្ខណៈស្មុគស្មាញចំពោះពលរដ្ឋ ដោយហេតុថាត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួន មុនឈានដល់ការចុះសំបុត្របញ្ជីអាពាហ៍ពិពាហ៍នៅឃុំសង្កាត់។

ការចូលរួមយ៉ាងសកម្មពីមន្ត្រីអត្រានុកូលដ្ឋានក្នុងការពន្លឿនការចុះសំបុត្រអាពាហ៍ពិពាហ៍ជូនពលរដ្ឋ តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលជូនពលរដ្ឋដោយផ្ទាល់នៅរោងការ ឬ កន្លែងប្រារព្ធអាពាហ៍ពិពាហ៍របស់ប្ដីប្រពន្ធថ្មីថ្មោងភ្លាមៗតែម្ដង ជាវិធានការដ៏ល្អដូចបានឃើញកន្លងមក។ ការធ្វើបែបនេះ គឺដើម្បីជៀសវាងការខកខាននៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬការប្រងើយកណ្ដើយរបស់សហាព័ទ្ធក្នុងការមកបំពេញបែបបទនៅសាលាឃុំសង្កាត់។

**៣. ការកំណត់និយមន័យ លក្ខខណ្ឌ អានុភាព និងនីតិវិធីនៃការបញ្ចប់អនីតិសង្វាសឲ្យបានច្បាស់លាស់ក្នុងច្បាប់**

ដោយសារសព្វថ្ងៃនេះ វិវាទផ្លូវច្បាប់ និង ភាពមិនឯកភាពគ្នាក្នុងការបកស្រាយអំពីចំណងអនីតិសង្វាស គឺកំពុងកើតមានឡើងពីសំណាក់អ្នកច្បាប់ និងអ្នកអនុវត្តច្បាប់នៅកម្ពុជា ដោយហេតុថាគ្មានវិធានគតិយុត្តណាមួយកំណត់អំពីបញ្ហាអនីតិសង្វាសឲ្យបានច្បាស់លាស់នោះទេ។ ដូចនេះ

ការកំណត់និយមន័យ លក្ខខណ្ឌ អានុភាព និង នីតិវិធីនៃការបញ្ចប់អនីតិសង្វាសឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ គឺជាការចាំបាច់ និងជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយដែលនាំឲ្យមានការបកស្រាយចំណងអនីតិសង្វាសនេះដោយឈរលើនិយមន័យច្បាប់ និងគោលការណ៍រួម។

**៤. ការប្រើប្រាស់គោលការណ៍ ឬមូលដ្ឋានច្បាស់លាស់រួមគ្នាមួយ ក្នុងការសម្រេចសេចក្ដីក្នុងរឿងក្ដីអនីតិសង្វាស**

តាមរយៈការសិក្សាស្រាវជ្រាវ និង ប្រភពឯកសារដែលបានពិភាក្សា យើងសង្កេតឃើញពីវត្តមាននៃការបកស្រាយ និង សម្រេចសេចក្ដីខុសៗគ្នាពីសំណាក់តុលាការ ឬ ចៅក្រម។ ដូចនេះ ភាគីពាក់ព័ន្ធ គួរពិនិត្យឡើងវិញពីបញ្ហាមួយនេះ តាមរយៈយន្តការ និង បទបញ្ញត្តិផ្សេងៗ ដើម្បីជម្រុញឲ្យមានការសម្រេចសេចក្ដីលើសំណុំរឿងអនីតិសង្វាសនេះ ដោយឈរលើមូលដ្ឋាន និងវិធានគតិយុត្តជាក់លាក់រួមគ្នាណាមួយ ក្នុងការធ្វើសេចក្ដីសម្រេចក្នុងរឿងក្ដីអនីតិសង្វាសនេះ នៅក្នុងស្ថានភាពអវត្តមាននៃវិធានគតិយុត្តស្ដីពីអនីតិសង្វាសនាពេលបច្ចុប្បន្ន។ ការធ្វើដូចនេះ គឺដើម្បីកាត់បន្ថយពីវិវាទក្នុងការដោះស្រាយតាមផ្លូវច្បាប់ និងការភាន់ច្រលំពីសមត្ថកិច្ចរបស់តុលាការ។

**៥. ការចូលរួមពីប្រជាពលរដ្ឋគ្រប់រូប ជាពិសេសនិស្សិតដែលកំពុងសិក្សាផ្នែកច្បាប់ក្នុងការចែករំលែកចំនេះដឹងផ្នែកច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងអនីតិសង្វាស**

ជាចុងក្រោយ ដើម្បីដោះស្រាយនូវបញ្ហាអនីតិសង្វាសនេះ ការចូលរួមតែពីអាជ្ញាធរពាក់ព័ន្ធ និង ស្ថាប័នរដ្ឋតែមួយ មិនអាចនាំមកនូវដំណោះស្រាយដ៏វិជ្ជមាន និងជោគជ័យនោះទេ ដោយហេតុថា វាទាមទារឲ្យមានការចូលរួម និងសហការគ្នាពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំង អ្នកច្បាប់ និងនិស្សិតច្បាប់ផងដែរ ក្នុងការបញ្ជ្រាប និងផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ដល់អ្នកនៅជុំវិញខ្លួនតាមដែលអាចធ្វើទៅបាន ដូចជាការពន្យល់ណែនាំសមាជិកគ្រួសារ មិត្តភក្ដិ និងការបង្កើតកម្មវិធី ឬឯកសារអប់រំក្នុងបណ្ដាញទំនាក់ទំនងសង្គមដល់ប្រជាពលរដ្ឋទូទៅជាដើម។ បន្ថែមពីនេះទៅទៀត ប្រជាពលរដ្ឋទូទៅ គួរព្យាយាម និងឆ្លៀតពេលវេលា ស្វែងយល់ពីបញ្ហាទាំងនេះដោយខ្លួនផងដែរ តាមរយៈការចូលរួមកម្មវិធីអប់រំផ្នែកច្បាប់ និងការណែនាំនានាពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ឬស្វះស្វែងសួរនាំនូវព័ត៌មានផ្នែកច្បាប់ពីអ្នកដែលយល់ដឹងលើបញ្ហានេះ ឬ ការសួរនាំពីអាជ្ញាធរឃុំសង្កាត់ដោយផ្ទាល់ជាដើម។ ដោយមានការចូលរួម និង សហការទាំងអស់គ្នាពីគ្រប់ភាគី ទើបបញ្ហាអនីតិសង្វាសអាចត្រូវបានដោះស្រាយដោយប្រសិទ្ធភាព ឬ កាត់បន្ថយក្នុងកម្រិតអតិបរមាបាន។

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ក្រមពហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ច្បាប់ស្តីពីការរៀបចំអង្គតុលាការ, លេខ នស/រក/ម០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។
- នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ កយ.ប្រក/១៣, ០៩ សីហា ២០១៣។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រក/ម០៦១០/០០៨, ០៨ មិថុនា ២០១០។
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ឆ្នាំ២០០០។
- អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣, លេខ ៦០ អនក្រ.បក, ២៤ មិថុនា ឆ្នាំ២០០០។
- អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៥៩ថ្មីនៃអនុក្រឹត្យលេខ ៦០, លេខ ១៧ អនក្រ.បក, ១៤ មិថុនា ២០០៤។
- អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ ថ្មីស្ទួននៃអនុក្រឹត្យលេខ ១៧, លេខ ១០៦ អនក្រ.បក, ២៣ សីហា ២០០៥។
- អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ ថ្មីស្ទួននៃអនុក្រឹត្យលេខ ១០៦, លេខ ៨៩ អនក្រ.បក, ៣០ សីហា ២០០៦។
- សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឲ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត, លេខ ០០៨ សណន, ១៨ ឧសភា ឆ្នាំ២០០៧។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥: គន្លឹះទី៧, ០៦ ឧសភា ២០១០។

- សាលដីកាតុលាការខ្មែរក្រហម, សំណុំរឿងកាំងហ្កេចអ៊ាវ ហៅឌុច, ចុះថ្ងៃទី30/03/2012, 328-333។

## សៀវភៅ និងអត្ថបទផ្សេងៗ

- ចក សម្បត្តិ. ២០១៤. *អនីតិសង្វាស.* ភ្នំពេញ។
- ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ. ២០១១. *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, បោះពុម្ពលើកទី៥. ភ្នំពេញ។
- បាន លក្ខិណា និង រ៉ាត់ រ៉ាទី. ២០១៧. *ទំនាក់ទំនងទ្រព្យសម្បត្តិនៃសហព័ទ្ធ និងអនីតិសង្វាស*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ប៊ុនរតនៈ. ២០១៨. *ការសម្រេចសេចក្តីលើរឿងក្តីអនីតិសង្វាស.* ភ្នំពេញ៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។
- រុន ពុណ្ណារិទ្ធ. មេរៀនចងក្រង នីតិគ្រួសារ សម្រាប់ឆ្នាំសិក្សា ២០១៤ ដល់ ២០១៥។
- អ៊ីវ ប៉ូលី និង ចៅ ប៊ុនហួន. ២០១៥. *អនីតិសង្វាស.* កិច្ចប្រជុំក្រុមការងារចម្រុះរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, គ្រួសារឥន្ទធនូនៅកម្ពុជា (ភ្នំពេញ, ២០១៧)។
- ស៊ូ សោភា និង ទិត្យ ស៊ីដែត. ការរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ( ភ្នំពេញ៖ វិទ្យាស្ថានសភាកម្ពុជា, ២០១៥), ៤។
- សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនិស្សលីកាដូ. បើគ្មានការផ្តន្ទាទោស គឺគ្មានការការពារះការឆ្លើយតបអំពើហឹង្សាក្នុងគ្រួសារនៅកម្ពុជា (ភ្នំពេញ, ២០១៧), ១៤។
- សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរភាគទី២ (យ-អ),* (ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតកម្ពុជា, លេខ១៦៥, បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៨), ទំព័រទី ១២៧៤។
- Code Civil Francais, (DALLOZ, 2014), article 518-8.
- Géralg Cornu, Association Henri Capitant, Vocabulaire Juridique (7éme Édition puf, 2005), page 927, le mot "Union".
- Higashio Kazuyuki. ២០១៨. ការអនុវត្តជាក់ស្តែងនៃការលែងលះ. វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីច្បាប់, ១៥ មីនា។
- Sara. ២០១៦. លែងលះប្តីប្រពន្ធក្នុងសេវាសម្របសម្រួលក្រៅតុលាការវិវាទរួម៧០០៦ករណី សម្រេចលែងលះចំនួន៤៤៥ករណី. *កោះសន្តិភាព*, ៣០ ធ្នូ, https://kohsantepheapdaily.com.kh/article/111984.html?fbclid=IwAR11FK__ug8qG9kJr_uh8XROc0X4s-sg0HJLonDfxkbgozFvEo3sQL-GKg8 (បានចូលមើលចុងក្រោយ ១៣ មិថុនា ឆ្នាំ២០១៩)

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តបាត់ដំបង**

សំណុំរឿងរដ្ឋប្បវេណី
លេខ:១៩៦ ចុះថ្ងៃទី២៥ ខែ
មិនា ឆ្នាំ២០១៦
សាលក្រមរដ្ឋប្បវេណី
លេខ:៣៧៥ (ជ)
ចុះថ្ងៃទី២៨.០៧.២០១៦

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ។
-សាលក្រមប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

រវាង ដើមចោទឈ្មោះ **A** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ កក មានទីលំនៅក្រុមទី ១ ភូមិ ១ ឃុំ ១ ស្រុក ១ ខេត្តបាត់ដំបង។ ឪពុកឈ្មោះ **C** ម្តាយឈ្មោះ **D** (ស្លាប់) ប្រពន្ធឈ្មោះ **B** មានកូនចំនួន០២នាក់។

ចុងចម្លើយឈ្មោះ **B** ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរ ខខ មានទីលំនៅក្រុមទី ១ ភូមិ ១ ឃុំ ១ ស្រុក ១ ខេត្តបាត់ដំបង។ ឪពុកឈ្មោ **E** (ស្លាប់) ម្តាយឈ្មោះ **F** (រស់) ប្តីឈ្មោះ **A** មានកូនចំនួន០២នាក់។

<u>កម្មវត្ថុបណ្តឹង</u>៖ប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម៖
១- ឲ្យខ្លួនបានលែងលះពីចុងចម្លើយឈ្មោះ **B** ។
២.ឲ្យចុងចម្លើយ ជាអ្នកមានអំណាចមេបាលើកូន:
- ឈ្មោះ **G** ភេទស្រី កើតថ្ងៃទី ១ ខែ ១ ឆ្នាំ ១ ។
៣. បែងចែកទ្រព្យសម្បត្តិរួមនៃគ្រួសារមាន ដីធ្លីលំនៅដ្ឋាន និងដីស្រែ។
៤. ឲ្យ ខ្លួនជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

នាពេលធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

- ការអះអាងរបស់ដើមចោទ **A** ..........................................................................................
  ភស្តុតាងបញ្ជាក់ការទាមទារ ៖ ..........................................................................................
- ការអះអាងរបស់ចុងចម្លើយ **B** ..........................................................................................

សំអាងហេតុ

១.ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីខ្មែរកាលពីឆ្នាំ១៩៩៧ ប្រាកដមែន ប៉ុន្តែពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ។ការណ៍ដែលគូភាគីពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់បែបនេះគឺមានន័យថា គូភាគីពុំមានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ទេ គឺរស់នៅជាមួយគ្នាតាមបែបអនីតិសង្វាសប៉ុណ្ណោះ ដូច្នេះការប្តឹងសុំរបស់ដើមចោទត្រង់ចំណុចទី១ នៃពាក្យបណ្តឹងសុំលែងលះ គឺជាបណ្តឹងមិនស្របច្បាប់គប្បីតុលាការ សម្រេចលើកចោល តាមបទប្បញ្ញត្តិ មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

ដោយគូភាគីមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដូច្នេះគូភាគីមានសិទ្ធិពេញលេញក្នុងការរៀបអាពាហ៍ ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ដោយគ្មានការជំទាស់ពីភាគីម្ខាងទៀតឡើយ។

២. ................................................
៣. ................................................
៤. ................................................
៥. ................................................
៦. ................................................

## សេចក្តីសម្រេចបញ្ចប់

១. លើកចោលចំណុចទី១ នៃកម្មវត្ថុបណ្តឹងរបស់ដើមចោទ តាមបញ្ញត្តិមាត្រា ៨១ ក្រមនីតិវិធីរដ្ឋប្បវេណី ។ គូភាគីមានសេរីភាពជ្រើស រើសគូស្រករ និងអាចរៀបអាពាហ៍ពិពាហ៍ តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់។

២. ក. កំណត់យកឈ្មោះ **B** ជាម្តាយជាអ្នកមានអំណាចមេបាលើកូនឈ្មោះ **G** ភេទស្រី កើតថ្ងៃទី ១ ខែ ១ ឆ្នាំ ១ ។ តាមការព្រមព្រៀង។

ខ.ឲ្យដើមចោទចេញសោហ៊ុយចាំបាច់សម្រាប់ទទួលបន្ទុកគ្រប់គ្រងថែរក្សាកូនមួយនាក់នេះចំនួន XXXXXX រៀល ( XXXXXX ) ក្នុងមួយខែ រហូតដល់កូនមាននីតិភាពតាមការព្រមព្រៀង។

ឪពុកដែលមិនមានអំណាចមេបាក្រោយពេលលែងលះមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ រីឯភាគី ដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត។

យោងបទប្បញ្ញត្តិមាត្រា ១០៣៧ និងមាត្រា ១០៤០ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៣.ក/ប្រគល់ទ្រព្យសម្បត្តិរួមឲ្យទៅដើមចោទឈ្មោះ **A** មាន:

-ដីលំនៅដ្ឋានទំហំ XXXXXX នៅភូមិ....................។

បាត់ដំបង។

-ដីស្រែចំនួន XXXXXX នៅភូមិ....................។

តាមសំណូមពររបស់ដើមចោទ។

ខ/ ប្រគល់ទ្រព្យរួមឲ្យទៅចុងចម្លើយឈ្មោះ **B** មាន:

-ដីទំហំ XXXXXX និងផ្ទះសង់លើដី XXXXXX នៅភូមិ....................។

-ដីស្រែចំនួន XXXXXX នៅភូមិ....................។

តាមសំណូមពររបស់ដើមចោទ។

គ/ ប្រគល់ដីស្រែចំនួន XXXX ឲ្យកូនបង្កើតឈ្មោះ **H** ភេទស្រី អាយុ១៨ឆ្នាំ និងឈ្មោះ **G** ភេទស្រី កើតថ្ងៃទី ១ ខែ ១ ឆ្នាំ ១ ទទួលជាកម្មសិទ្ធិស្របច្បាប់តាមសំណូមពររបស់ដើមចោទ ដែលដីស្រែទាំងនោះស្ថិតនៅ:

-ភូមិ ..............................................។
-ភូមិ ..............................................។
-ភូមិ ..............................................។

យោងតាមបទប្បញ្ញត្តិមាត្រា ៩៧៣ មាត្រា ៩៨០ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៣. បង្គាប់ឲ្យដើមចោទទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

យោងតាមបទបញ្ញត្តិមាត្រា៦៩ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

៤. សាលក្រមនេះឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ចៅក្រម

ហត្ថលេខា និងត្រា

បានចម្លងត្រឹមត្រូវចេញពីមូលសាលក្រម
បាត់ដំបង,ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦
ក្រឡាបញ្ជី

បានឃើញ

បាត់ដំបង,ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦

ចៅក្រម

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី
លេខ: ៦៥៨
ចុះថ្ងៃទី២៨-១២-២០១៦
សាលដីកា
លេខ:០៩ ក្រIII "ធ"
ចុះថ្ងៃទី០៥-០៧-២០១៧

តាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

**សមាសភាពក្រុមប្រឹក្សា**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោកស្រី [redacted] ជាក្រឡាបញ្ជី

១/អត្តសញ្ញាណរបស់គូភាគី

-ដើមចោទ **A** ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ កក
មានទីលំនៅក្រុមទី ១ ភូមិ ១ ឃុំ ១ ស្រុក ១ ខេត្តបាត់ដំបង ។ (ចុងបណ្តឹងឧទ្ធរណ៍)

-ចុងចម្លើយឈ្មោះ **B** ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ ខខ
មានទីលំនៅក្រុមទី ១ ភូមិ ១ ឃុំ ១ ស្រុក ១ ខេត្តបាត់ដំបង ។ (ដើមបណ្តឹងឧទ្ធរណ៍)

២/ខ្លឹមសារនៃការទាមទារ

ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម:

១.ឱ្យខ្លួនបានលែងលះពីចុងចម្លើយឈ្មោះ **B** ។

២.ឱ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូន៖

-ឈ្មោះ **F** ភេទស្រី កើតថ្ងៃទី ១ ខែ ១ ឆ្នាំ ១ ។

៣.បែងចែកទ្រព្យសម្បត្តិរួមនៃគ្រួសារមានដីធ្លីលំនៅដ្ឋាន និងដីស្រែ ។

៤.ឱ្យខ្លួនជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

## ៣./ អំពីអង្គហេតុ

- ……………………………………………
- ……………………………………………

## នាពេលទាញហេតុផលផ្ទាល់មាត់

- ……………………………………
- ……………………………………

## សំអាងហេតុ

១-……………………………………………
២-……………………………………………

៣-ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ភាគី និងភស្តុតាងក្នុងសំណុំរឿងឃើញថា៖ ដើមចោទ និងចុងចម្លើយបានរស់នៅជាមួយគ្នាជាអនីតិសង្វាស ។ ក្នុងការរស់នៅជាអនីតិសង្វាសនេះ ដើមចោទ និងចុងចម្លើយមានកូន០២នាក់ កូនទី១ឈ្មោះ ……………………………………………………………………………………………………………………………………………………………………………………………………………………។

៤-ចុងចម្លើយទទួលស្គាល់ថា៖ ទ្រព្យសម្បត្តិដែលមានដូចការអះអាងក្នុងពាក្យបណ្តឹងរបស់ដើមចោទគឺជាទ្រព្យរួម និងសុំឱ្យក្រុមប្រឹក្សាសម្រេចប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឱ្យទៅកូនទាំងពីរនាក់ ។

៥-ចំណុចវិវាទគឺ ចុងចម្លើយសុំឱ្យប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឱ្យទៅកូនទាំងពីរនាក់ ។ ដើមចោទសុំឱ្យក្រុមប្រឹក្សាសម្រេចបែងចែកទ្រព្យសម្បត្តិរួមដូចក្នុងសាលក្រមរបស់សាលាដំបូង ។

៦-មាត្រា ៩៨០ កថាខណ្ឌទី២ ចំណុចខ នៃក្រមរដ្ឋប្បវេណីបានចែងថា “*បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ភាគ២(មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើតទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍ ។*” ហេតុនេះការអះអាងរបស់ចុងចម្លើយ សុំឱ្យសភារដ្ឋប្បវេណីនៃសាលាឧទ្ធរណ៍ ធ្វើការបែងចែកដោយប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឱ្យទៅកូននោះ ជាការពុំត្រឹមត្រូវទេ ព្រោះផ្ទុយនឹងមាត្រា ៩៨០ កថាខណ្ឌទី២ ចំណុចខ នៃក្រមរដ្ឋប្បវេណី ។

៧-……………………………………………។
៨-……………………………………………។
៩-……………………………………………។

# សេចក្តីសម្រេចបញ្ចប់

១.ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ របស់ចុងចម្លើយឈ្មោះ សោ ហៀត ។

២.តម្កល់សាលក្រមរដ្ឋប្បវេណីលេខ: ៣៧៤ (ជ) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

៣-ប្រាក់ប្រដាប់ក្តីនៅសាលាឧទ្ធរណ៍ ជាបន្ទុករបស់ចុងចម្លើយ ។

សាលដីកានេះបានប្រកាសជាសាធារណ: នៅថ្ងៃទី០៤-០៧-២០១៧ ។

សាមីភាគីមានសិទ្ធិប្តឹងសាទុក្ខរយៈពេល ១ខែគិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៧

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សា